# ការស្រេកឃ្លានខាងវិញ្ញាណ

លោកប្លែស៍ ប៉ាស្កាល់(Blaise Pascal) ដែលជាគណិតវិទូ និងទស្សនវិទូជនជាតិបារាំង បានមានប្រសាសន៍ថា នៅក្នុងចិត្តរបស់មនុស្សម្នាក់ៗ គឺមានភាពចន្លោះប្រហោងមួយ ដែលព្រះបានបង្កើតមក។ មុនសម័យរបស់លោកប៉ាស្កាល់ ជាច្រើនសតវត្សរ៍ មានបុរសម្នាក់ឈ្មោះ អូគូស្ទីន(Augustine) បានព្យាយាមស្វែងរកវិធីបំពេញភាពចន្លោះប្រហោង ដ៏ស្រេកឃ្លាន នៅក្នុងជីវិតគាត់។ បន្ទាប់ពីគាត់បានរកឃើញថា ខ្លួនកំពុងខ្វះអ្វីហើយ គាត់ក៏បានសរសេរបទអធិស្ឋានមួយ ដែលក្នុងនោះគាត់បានទូលទៅព្រះថា "ព្រះអង្គបានបង្កើតយើងខ្ញុំមក សម្រាប់ព្រះអង្គទ្រង់ ហើយចិត្តរបស់យើងខ្ញុំមិនបានសម្រាកឡើយ បើសិនជាយើងខ្ញុំមិនបានរកឃើញការសម្រាកនៅក្នុងទ្រង់ទេនោះ"(ការទទួលស្គាល់)។

អ្នកប្រាជ្ញទាំងពីររូបនេះ បានបង្ហាញអំពីការអ្វី ដែលយើងម្នាក់ៗបានដឹង នៅក្នុងពេលស្ងប់ស្ងាត់ និងក្នុងពេលជញ្ជឹងគិត។ ក្នុងចិត្តរបស់យើងម្នាក់ៗ គឺមានសេចក្តីប៉ងប្រាថ្នាដែលមិនចេះស្រាកស្រាន្ត ដែលជាការប្រាថ្នាចង់ស្គាល់អ្នកដែលបានបង្កើតខ្លួនមក។ យើងចង់ដឹង ថាហេតុអ្វីបានជាទ្រង់បង្កើតយើងមក នៅក្នុងសកលលោកដ៏ធំល្វឹងល្វើយនេះ។ យើងប្រាថ្នាចង់ស្វែងរកសន្តិភាពនៅក្នុងលោកិយមួយ ដែលកំពុងតែបាក់បែក ដោយសារជម្លោះរវាងគ្រួសារនឹងគ្រួសារ ដោយសង្គ្រាមរវាងជាតិសាសន៍ ដោយក្រុមសកម្មប្រយុទ្ធដើម្បីសាសនា ដោយភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និងដោយការញៀនដែលបំផ្លាញខ្លួនឯង។ល។

មានពេលខ្លះ យើងប្រហែលជាព្យាយាមគ្របសង្កត់ចិត្តដែលស្រេកឃ្លាននោះ។ យើងប្រហែលជាព្យាយាមបំពេញភាពចន្លោះប្រហោងនោះ ដោយការជាប់រវល់ធ្វើនេះធ្វើនោះ នៅក្នុងជីវិត ដូចជា ការបម្រើដល់សហគមន៍ ការខិតខំសម្រេចជោគជ័យក្នុងអាជីព ការទំនាក់ទំនងបែបរ៉ូមិនទិច ឬដោយព្យាយាមគ្របសង្កត់ចិត្តស្រេកឃ្លាននេះ ដោយថ្នាំញៀន ឬគ្រឿងស្រវឹងជាដើម។ ទោះបីជាយើងព្យាយាមគ្របសង្កត់ ឬបដិសេធចិត្តស្រេកឃ្លាន ដែលមានក្នុងយើងយ៉ាងណាក៏ដោយ ក៏វានឹងនៅតែលេចឡើង មកវិញម្តងហើយម្តងទៀតជានិច្ច។

ហេតុនេះហើយបានជាយើងខ្ញុំផលិតកូនសៀវភៅនេះមក។ កូនសៀវភៅនេះគឺសម្រាប់ឲ្យលោកអ្នកអានជារៀងរាល់ថ្ងៃ ក្នុងរយៈពេល៤សប្តាហ៍ ហើយយើងខ្ញុំបានរៀបចំមក ដើម្បីជួយឲ្យអ្នកស្វែងរកឃើញសេចក្តីអំណរ នៅក្នុងការប្រកបទាក់ទងផ្ទាល់ខ្លួនជាមួយព្រះ។ ចម្លើយទាំងនោះ គឺមានប្រភពនៅក្នុងសៀវភៅដ៏ពិសិដ្ឋមួយក្បាល ដែលព្រះបានប្រទានដល់យើង គឺព្រះគម្ពីរបរិសុទ្ធ។ ពេលដែលអ្នកប្រើកូនសៀវភៅនេះជារៀងរាល់ថ្ងៃ អ្នកនឹងបានទទួលការលើក

ទឹកចិត្ត ឲ្យធ្វើការស្វែងយល់ផ្ទាល់ខ្លួន អំពីសេចក្ដីដែលព្រះគម្ពីរបានចែងអំពីព្រះ និងអំពីបញ្ហាដែលកើតមានជាក់ស្ដែង ក្នុងជីវិតរបស់អ្នក។

ដូចនេះ សូមអានកូនសៀវភៅនេះតាំងពីទំព័រដំបូង ដល់ចប់។ វានឹងផ្ដល់អាហារ សម្រាប់ចម្អែតវិញ្ញាណរបស់អ្នក។ អ្នកនឹងបានសិក្សាអំពីប្រធានបទផ្សេងៗ តាមរយៈអត្ថបទខ្លីៗ ដែលមានជាប្រចាំថ្ងៃ ហើយទំព័រចុងសប្ដាហ៍ពិសេស និងជួយដាស់គំនិតរបស់លោកអ្នក ឲ្យបានយល់ដឹងអំពីការស្វែងរកភាពស្កប់ស្កល់ នៅក្នុងចិត្ត និងគំនិតរបស់អ្នក។ យើងខ្ញុំសូមអធិស្ឋាន សូមឲ្យព្រះបន្ទូលដែលមានក្នុងទំព័រដែលមានជាបន្តបន្ទាប់នេះ បាននិយាយដោយផ្ទាល់ អំពីបញ្ហាដ៏ស៊ីជម្រៅបំផុតនៃជីវិតអ្នក ដោយជួយចង្អុលបង្ហាញនូវចម្លើយដែលធ្វើឲ្យមានភាពស្កប់ស្កល់អស់កល្បជានិច្ច ដល់ចិត្តដែលស្រេកឃ្លានរបស់អ្នក។

> “ព្រះអង្គបានបង្កើតយើងខ្ញុំមក សម្រាប់ព្រះអង្គទ្រង់ ហើយចិត្តរបស់យើងខ្ញុំមិនបានសម្រាកឡើយ បើសិនជាយើងខ្ញុំមិនបានរកឃើញការសម្រាកនៅក្នុងទ្រង់ទេនោះ”។
>
> -អូគូស្ទីន ( Augustine )

ដូចនេះ សូមបើកទំព័រសៀវភៅដែលមានជាបន្តបន្ទាប់ ហើយចាប់ផ្ដើមចម្អែតវិញ្ញាណរបស់អ្នកចុះ។

សប្តាហ៍ទី១ ថ្ងៃច័ន្ទ

## បើចង់បានមិត្តភ័ក្រ ចូរធ្វើខ្លួនជាមិត្តភ័ក្រ

សូមអាន
យ៉ូហាន ១៥:៩-១៧

មានមិត្រសំឡាញ់ម្យ៉ាង ដែលនៅជាប់ជាងបងប្អូនទៅទៀត ។
- សុភាសិត ១៨:២៤

យើងម្នាក់ៗត្រូវការមិត្តជិតស្និទ្ធ យ៉ាងហោចណាស់ចំនួនម្នាក់ ឬពីរនាក់។ ក្មេងប្រុសតូចល្អិតម្នាក់បានឲ្យនិយមន័យថា មិត្តភ័ក្រគឺជា "អ្នកដែលដឹងអំពីអ្វីៗគ្រប់យ៉ាងរបស់អ្នក ហើយនៅតែស្រឡាញ់អ្នក ទោះបានដឹងអំពីការទាំងអស់នោះក៏ដោយ"។ លោករ៉ាព វ៉លដូ អេមើ-សិន(Ralp Waldo Emerson) បានមានប្រសាសន៍ថា "មិត្តសំឡាញ់យល់ថា សំឡាញ់ខ្លួនជាស្នាព្រះហស្តល្អបំផុតនៅក្នុងធម្មជាតិ"។ លោកហេនរី ឌូបានវីល(Henry Dur-banville) បានមានប្រសាសន៍ថា "មិត្តសំឡាញ់គឺជាអ្នកដែលចូលមករកយើងមុនគេ នៅពេលយើងស្ថិតក្នុងសភាពអស់សង្ឃឹមបំផុត"។

យ៉ាងណាមិញ ស្តេចសាឡូម៉ូនបានចែងនៅក្នុងព្រះគម្ពីរសុភាសិត ១៧:១៧ ថា "មិត្តសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់ពេលវេលា"។ យើងមិនអាចបន្ថែមបន្ថយអត្ថន័យនៃពាក្យមិត្តសំឡាញ់ ដែលមានក្នុងបទគម្ពីរនេះបានឡើយ។ ការដែលមានអ្នកស្មោះត្រង់ចំពោះយើង នៅគ្រប់កាលៈទេសៈទាំងអស់ គឺជាព្រះពរដែលគួរឲ្យចង់បានបំផុត ក្នុងមួយជីវិតនេះ។ យើងត្រូវការជំនួយ និងការលើកទឹកចិត្តពីមិត្តជិតស្និទ្ធបំផុត ជាពិសេសនៅពេលដែលយើងកំពុងទទួលរងបន្ទុកដ៏ធ្ងន់នៃជីវិត។ ជាការពិតណាស់ ព្រះយេស៊ូវទ្រង់ជាមិត្តជិតស្និទ្ធបំផុត ព្រោះទ្រង់បានលះបង់ព្រះជន្ម ដើម្បីមិត្តសំឡាញ់ទ្រង់(យ៉ូហាន ១៥:១៣)។

បទគម្ពីរសុភាសិត ១៨:២៤ បានលើកឡើងនូវចំណុចដ៏សំខាន់មួយ ហើយពន្យល់យ៉ាងច្បាស់លាស់ អំពីអត្ថន័យនៃពាក្យមិត្តសំឡាញ់។ ខនេះបានរៀបរាប់ថា "អ្នកដែលមានមិត្តសំឡាញ់ ត្រូវមានលក្ខណៈរួសរាយរាក់ទាក់"។ ជាការពិតណាស់ ភាពចៅរ៉ាវត្រូវចាប់ផ្តើមពីខ្លួនយើងមុន។ នៅក្នុងការកសាងទំនាក់ទំនងជាមួយអ្នកដទៃ យើងត្រូវធ្វើជាអ្នកចាប់ផ្តើមទំនាក់ទំនងមុន។ បើយើងចង់ឲ្យគេធ្វើចំពោះយើងបែបយ៉ាងណា នោះចូរយើងធ្វើចំពោះគេបែបយ៉ាងនោះជាមុនសិន។ នៅក្នុងមិត្តភាព យើងត្រូវធ្វើខ្លួនជាមិត្តសំឡាញ់ បើយើងចង់ឲ្យគេធ្វើជាមិត្តសំឡាញ់របស់យើងនោះ។ -Richard De Haan

*ខ្ញុំបានចេញទៅក្នុងលោកិយ ដើម្បីស្វែងរកមិត្តសំឡាញ់*
*ប៉ុន្តែ មិនអាចរកបានសូម្បីតែមួយ*
*ខ្ញុំបានចេញទៅក្នុងលោកិយ ដើម្បីធ្វើខ្លួនជាមិត្តសំឡាញ់*
*នោះខ្ញុំរកបានមិត្តសំឡាញ់ នៅគ្រប់ទីកន្លែងទាំងអស់! –Anon*

---

**គេមិនងាយនឹងរកបានមិត្តភ័ក្រឡើយ**
**ប៉ុន្តែ គេអាចបង្កើតមិត្តភាពបាន។** - Wentworth

# បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ - យ៉ូហាន ១៥:៩-១៧

៩ ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចជាព្រះវរ
បិតា ទ្រង់ស្រឡាញ់ខ្ញុំដែរ ចូរនៅជាប់ក្នុងសេច
ក្តីស្រឡាញ់របស់ខ្ញុំចុះ ១០ បើអ្នករាល់គ្នាកាន់
តាមបញ្ញត្តខ្ញុំ នោះនឹងនៅជាប់ក្នុងសេចក្តី
ស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្ត
នៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្តី
ស្រឡាញ់របស់ទ្រង់ដែរ ១១ ខ្ញុំបាននិយាយ សេ
ចក្តីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីឲ្យសេ
ចក្តីអំណររបស់ខ្ញុំ បាននៅជាប់ក្នុងអ្នករាល់គ្នា
ហើយឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបាន
ពោរពេញផង ១២ នេះជាសេចក្តីបញ្ញត្ត របស់ខ្ញុំ
គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅ
មក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ
១៣ គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាង
នេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំ
ឡាញ់របស់ខ្លួននោះទេ ១៤ បើអ្នករាល់គ្នាធ្វើ
តាមសេចក្តីដែលខ្ញុំបង្គាប់ នោះអ្នករាល់គ្នាជា
ពួកសំឡាញ់ខ្ញុំហើយ ១៥ ខ្ញុំមិនហៅជាអ្នក បំរើ
ទៀត ពីព្រោះអ្នកបំរើគេមិនដឹងថាជាចៅហ្វាយ
ធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ
ពីព្រោះខ្ញុំបានឲ្យអ្នករាល់គ្នាដឹងគ្រប់ការទាំង
អស់ ដែលខ្ញុំឮពីព្រះវរបិតាខ្ញុំមក ១៦ មិនមែន
អ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែល
រើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឲ្យទៅ
បង្កើតផល ហើយឲ្យផលអ្នករាល់គ្នាបាននៅ
ជាប់ផង ដើម្បីឲ្យព្រះវរបិតាបានប្រោសប្រទាន
ឲ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់
ដោយនូវឈ្មោះខ្ញុំ ១៧ ខ្ញុំបង្គាប់សេចក្តីនេះដល់
អ្នករាល់គ្នា គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមក
ចុះ។

## ការស្វែងយល់

បទគម្ពីរខាងលើង គឺជាព្រះបន្ទូលព្រះយេស៊ូវដែលទ្រង់បានមាន នៅក្នុងពិធីលៀងព្រះអម្ចាស់ នៅក្នុងបន្ទប់ខាងលើ ជាមួយពួកសិស្សរបស់ទ្រង់ ដោយទ្រង់បានជ្រាបថា ទ្រង់នឹងយាងទៅឯឈើឆ្កាង ក្នុងថ្ងៃបន្ទាប់។ ការនេះបានផ្តល់ឲ្យនូវសេចក្តីបង្រៀនដ៏សំខាន់ អំពីការត្រាស់ហៅឲ្យស្តាប់បង្គាប់ទ្រង់ ព្រោះបទគម្ពីរភីលីព ២:៨ បានចែងថា "ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង"។ ពេលដែលទ្រង់ត្រាសហៅយើង ឲ្យស្តាប់បង្គាប់ទ្រង់ នោះទ្រង់បានជ្រាបយ៉ាងច្បាស់ អំពីការលះបង់ដែលយើងត្រូវមាន។ ទ្រង់ជ្រាបថា ការធ្វើតាមបំណងព្រះទ័យព្រះវរបិតា នឹងបណ្តាលឲ្យទ្រង់លះបង់ព្រះជន្មនៅលើឈើឆ្កាង តែទោះបីជាយ៉ាងណាក៏ដោយ ទ្រង់នៅតែស្តាប់បង្គាប់ព្រះវរបិតា។

សប្ដាហ៍ទី១ ថ្ងៃអង្គារ

# តើខ្ញុំអាចអត់ទោសឲ្យអ្នកដទៃដោយរបៀបណា?

សូមអាន
ម៉ាថាយ ១៨:២១-៣៥

---

តែបើអ្នករាល់គ្នាមិន អត់ទោស ចំពោះការរំលងច្បាប់ឲ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិន អត់ទោស ចំពោះការរំលងច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ។
- ម៉ាថាយ ៦:១៥

---

អ្នកខ្លះបានជួបប្រទះនឹងការឈឺចាប់យ៉ាងខ្លាំងក្រៃលែងក្នុងជីវិត បានជាអ្នកនោះហាក់ដូចជាមិនអាចអត់ឱនឲ្យអ្នកដែលបានបង្ករការឈឺចាប់នោះបានទេ។ តែព្រះយេស៊ូវមានបន្ទូលថា យើងនឹងមិនអាចពិសោធនឹងការអត់ទោសបាបរបស់ទ្រង់ឡើយ បើយើងមិនមានវិញ្ញាណដែលអត់ទោសទេនោះ។

នៅក្នុងសង្គ្រាមលោកលើកទីពីរ អ្នកស្រី ខូរី ថែន ប៊ូម (Corrie Ten Boom) និងបងប្អូនស្រីរបស់គាត់គឺ បេតស៊ី (Betsie) ត្រូវបានគេចាប់ខ្លួន ពីបទជួយលាក់បំពួនជនជាតិយូដា ហើយត្រូវបានគេបញ្ជូនទៅជំរុំឃុំឃាំងខ្លួនរបស់ប្រទេសអាឡឺម៉ង់។ អ្នកស្រីបេស៊ីបានស្លាប់បាត់បង់ជីវិតយ៉ាងយឺតៗ និងវេទនាបំផុត ដោយសារតែអំពើដ៏សាហាវយង់ឃ្នងក្នុងជំរុំនោះ។

ក្រោយមក នៅឆ្នាំ ១៩៤៧ អ្នកស្រីខូរី បានចែកចាយអំពីការអត់ទោសបាបរបស់ព្រះ នៅក្នុងព្រះវិហារមួយ នៅក្រុងមុយនិច(Munich)។ បន្ទាប់មក មានបុរសម្នាក់បានមកជួបគាត់។ គាត់នៅចាំថា បុរសម្នាក់នោះធ្លាប់នៅក្នុងចំណោមពួកឆ្មាំគុក ដែលបានធ្វើបាបគាត់ និងបេស៊ី។ បុរសនោះបានប្រាប់ថា ខ្លួនបានក្លាយជាគ្រីស្ទបរិស័ទហើយ ហើយក៏បានលើកដៃសុំការអត់ឱនទោសពីគាត់។ អ្នកស្រីខូរីមានអារម្មណ៍ដែលពិបាកទ្រាំយ៉ាងខ្លាំង តែពេលដែលគាត់បាននឹកចាំព្រះបន្ទូលរបស់ព្រះយេស៊ូវ នៅក្នុងព្រះគម្ពីរម៉ាថាយ ៦:១៥ គាត់ក៏បានដឹងថា ខ្លួនត្រូវតែអត់ទោសឲ្យ។ គាត់ក៏បានអធិស្ឋានយ៉ាងស្ងាត់ស្ងៀមថា "ឱព្រះយេស៊ូវអើយ សូមជួយទូលបង្គំផង!" ហើយគាត់ក៏បានទៅចាប់ដៃរបស់អ្នក ដែលបានធ្វើទារុណកម្មមកលើគាត់កាលពីសម័យមុននោះ។

មានគេនិយាយថា "ការអត់ទោសបាប មិនមែនជាការបាត់ការចងចាំដ៏បរិសុទ្ធ ដែលបានធ្វើឲ្យយើងលែងនឹកចាំពីអតីតកាលនោះទេ។ ផ្ទុយទៅវិញ វាគឺជាការពិសោធន៍នឹងការប្រោសឲ្យជា ដែលបានដកថ្នាំពុលចេញពីស្នាមរបួស"។ ព្រះទ្រង់បានបង្គាប់ឲ្យយើងប្រព្រឹត្តចំពោះអ្នកដទៃ នូវការអ្វីដែលទ្រង់បានធ្វើសម្រាប់យើង តាមរយៈព្រះយេស៊ូវគ្រីស្ទ។ ទ្រង់នឹងប្រទានឲ្យយើងមានកម្លាំង ដើម្បីឲ្យយើងអាចអត់ទោសឲ្យអ្នកដទៃ។ - Dennis De Haan

*ឱព្រះអម្ចាស់យេស៊ូវអើយ សូមប្រទានព្រះគុណទ្រង់ ដល់យើងខ្ញុំជារៀងរាល់ថ្ងៃ*
*ដើម្បីឲ្យទូលបង្គំយើងខ្ញុំបានដើរតាមផ្លូវទ្រង់*
*ជាពិសេស នៅពេលដែលវិញ្ញាណដែលមិនបានទទួលសេចក្ដីស្រឡាញ់*
*ត្រូវការការអត់ទោសពីយើងខ្ញុំ ដើម្បីឲ្យមានសេរីភាព។ - D. De Haan*

---

**ដោយសារយើងគ្រប់គ្នាសុទ្ធតែត្រូវការការអត់ទោសបាប**
**នោះយើងគួរតែអត់ទោសឲ្យអ្នកដែលធ្វើខុសនឹងយើងជានិច្ច។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ម៉ាថាយ ១៨:២១-៣៥

២១ ខណៈនោះ ពេត្រុសក៏មកឯទ្រង់ទូលថា
ព្រះអម្ចាស់អើយ បើបងប្អូនធ្វើបាបនឹងខ្ញុំ
នោះត្រូវឲ្យខ្ញុំអត់ទោសឲ្យគេដល់ប៉ុន្មានដង តើ
ដល់៧ដងឬអី ២២ ព្រះយេស៊ូវទ្រង់មានព្រះ
បន្ទូលតបថា ខ្ញុំមិនថា ឲ្យអ្នកអត់ទោសត្រឹមតែ
៧ដងទេ គឺដល់៧ចិតសិបដងទៅទៀត
២៣ ដូច្នេះ នគរស្ថានសួគ៌ត្រូវប្រៀបដូចជាស្ដេ
ច១អង្គដែលចង់គិតបញ្ជីនឹងពួកបាវព្រាវ
២៤ កាលទ្រង់ចាប់តាំងគិត នោះគេនាំកូន
បំណុលម្នាក់មក ដែលជំពាក់ប្រាក់២កោដិ
២៥ តែដោយព្រោះអ្នកនោះ គ្មានអ្វីនឹងសង
បានជាចៅហ្វាយបង្គាប់ឲ្យលក់ខ្លួនវា ព្រមទាំង
ប្រពន្ធកូន និងរបស់ទាំងអស់ ដើម្បីនឹងសង
បំណុលនោះ ២៦ ហេតុដូច្នេះ បាវនោះបានទំ
លាក់ខ្លួនក្រាបចុះថ្វាយបង្គំទូលថា បពិត្រព្រះ
ករុណា សូមទ្រង់មេត្តាបង្អង់ឲ្យទូលបង្គំសិន
ទូលបង្គំនឹងសងថ្វាយទ្រង់គ្រប់ចំនួន ២៧ ឯ
ចៅហ្វាយរបស់បាវនោះ មានព្រះទ័យក្តួល
អាណិត ក៏លែងវាឲ្យទៅ ព្រមទាំងលែងទារ
បំណុលផង ២៨ តែកាលបាវនោះបានចេញ
ទៅហើយ ក៏ជួបប្រទះនឹងគូកនម្នាក់ ដែល
ជំពាក់ខ្លួន២០រៀល នោះវាចាប់ច្របាច់កអ្នក
នោះ ដោយពាក្យថា ចូរសងប្រាក់ដែលជំពាក់
អញនោះមក ២៩ អ្នកនោះក៏ទំលាក់ខ្លួន ក្រាប
ចុះនៅទៀបជើង សូមអង្វរថា សូមមេត្តាបង្អង់
ឲ្យខ្ញុំសិន ខ្ញុំនឹងសងជូនអ្នក ៣០ តែវាមិនព្រម
ទេ ត្រឡប់ជាបានចាប់អ្នកនោះ នាំទៅដាក់
គុកវិញ ទាល់តែបានសងបំណុលរួច ៣១ កាល
ពួកគូកនគេបានឃើញការនោះ គេមានចិត្ត
ឈឺឆ្អាលណាស់ ក៏នាំគ្នាទៅទូលដល់
ចៅហ្វាយ ពីការទាំងប៉ុន្មានដែលកើតមក
៣២ ចៅហ្វាយក៏ឲ្យគេហៅ បាវនោះមក រួចមាន
ព្រះបន្ទូលថា នែ អាបំរើអាក្រក់ អញបានលែង
ទារបំណុលឯងទាំងអស់ហើយតើ ពីព្រោះឯង
បានអង្វរដល់អញ ៣៣ ដូច្នេះ តើមិនគួរឲ្យឯង
អាណិតមេត្តាដល់គូកនឯង ដូចជាអញបាន
អាណិតមេត្តាដល់ឯងដែរទេឬអី ៣៤ ចៅហ្វាយ
ក៏មានសេចក្តីក្រោធ ហើយបញ្ជូនវាទៅឯមេភូ
ឃុំ ទាល់តែបានសងបំណុលនោះគ្រប់ចំនួន
៣៥ យ៉ាងនោះ បើអ្នករាល់គ្នាមិនអត់ទោសការ
រំលងរបស់បងប្អូន ដោយស្ម័គ្រពីចិត្តទេ នោះ
ព្រះវរបិតានៃខ្ញុំ ដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏
នឹងប្រព្រឹត្តនឹងអ្នករាល់គ្នាដូច្នោះដែរ។

សប្តាហ៍ទី១ ថ្ងៃពុធ

# ទ្រង់ស្គាល់ឈ្មោះអ្នក

សូមអាន
ទំនុកតម្កើង ១៤៧:១-៩

ទ្រង់ប្រោសអស់អ្នកដែលមានចិត្តសង្រេងឲ្យបានជា ក៏រុំរបួសឲ្យគេផង ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយ ក៏ហៅបានតាមឈ្មោះទាំងអស់ ។
- ទំនុកតម្កើង ១៤៧:៣-៤

តើមានផ្កាយប៉ុន្មាននៅលើមេឃ? ពួកតារាវិទូមិនដឹងថា មានចំនួនប៉ុន្មានទេ។ ពួកគេគ្រាន់តែបញ្ជាក់ឲ្យយើងដឹងថា នៅក្នុងកូស្មូស(លំហរអាកាស) មានផ្កាយច្រើនរាប់មិនអស់។ ប្រហែលជាមានរាប់ពាន់លាន ឬរាប់សែនកោតក៏មិនដឹង! ចំនួនដ៏ច្រើនដូចនេះ គឺមិនអាចឲ្យយើងរាប់បានទេ។ សូម្បីតែចំនួនមួយលាន ក៏ជាចំនួនច្រើនលើសលប់ទៅហើយ។ បើសិនជាអ្នកត្រូវរាប់ក្រដាសប្រាក់១ដុល្លា ចំនួន១លានសន្លឹក ក្នុងល្បឿន៦០សន្លឹកក្នុងមួយនាទី ៨ម៉ោងក្នុងមួយថ្ងៃ ហើយ៥ថ្ងៃក្នុងមួយសប្តាហ៍ នោះអ្នកត្រូវចំណាយពេលជិត៧សប្តាហ៍ ដើម្បីរាប់ក្រដាសប្រាក់ទាំងនោះឲ្យអស់។ ហើយបើអ្នករាប់ក្រដាសប្រាក់១ដុល្លាក្នុងល្បឿនដដែលនេះ នោះអ្នកត្រូវចំណាយពេល១៣៣ឆ្នាំ ដើម្បីរាប់ឲ្យអស់១ពាន់លានសន្លឹក។

ព្រះគម្ពីរបានប្រកាសថា ព្រះដែលបានបង្កើតថ្ងៃ និងព្រះច័ន្ទ ទ្រង់ក៏បាន "បង្កើតផ្កាយផងដែរ"(លោកុប្បត្តិ ១:១៦)។ ព្រះគម្ពីរក៏បានចែងផងដែរថា "ចូរងើយភ្នែកឯងមើលទៅលើ ហើយពិចារណាពីអ្នកណាដែលបានបង្កើតរបស់ទាំងនេះ ដែលនាំឲ្យពួកពលបរិវារចេញមកតាមចំនួនដូច្នេះ ទ្រង់ក៏ហៅរបស់ទាំងនោះតាមឈ្មោះរៀងរាល់តួ ដោយព្រះចេស្តាដ៏ធំរបស់ទ្រង់ ហើយគ្មានណាមួយខានឡើយ ដោយព្រោះតេជានុភាពដ៏ខ្លាំងក្លាដែរ"(អេសាយ ៤០:២៦)។

ដូចនេះ បើសិនជាយើងឆ្ងល់ ថាតើព្រះទ្រង់អាចទទួលបន្ទុករបស់យើងដែរឬទេ នោះសូមចាំថា ទ្រង់មានអំណាចគ្រប់គ្រងផ្កាយទាំងឡាយ។ ជាការពិតណាស់ ព្រះដែលជាអ្នកគ្រប់គ្រងនៃហ្គាឡាក់ស៊ីទាំងឡាយ ទ្រង់អាចដោះស្រាយស្ថានភាពរបស់យើងបាន។

បើយប់នេះ មានផ្ទៃមេឃស្រឡះ សូមមើលទៅលើ ហើយអរព្រះគុណព្រះ ដែលបានទ្រង់បានហៅផ្កាយ តាមឈ្មោះរៀងៗខ្លួន ទ្រង់ស្គាល់យើង ទ្រង់ស្រឡាញ់យើង និងយកព្រះទ័យទុកដាក់ចំពោះយើង។- Vernon Grounds

*ខ្ញុំច្រៀងអំពីប្រាជ្ញារបស់ព្រះ ដែលបានចាត់តាំង*
*ឲ្យព្រះអាទិត្យបញ្ចេញពន្លឺនៅពេលថ្ងៃ*
*ព្រះច័ន្ទមានរស្មីពេញវង់ តាមព្រះរាជបញ្ជាទ្រង់*
*ហើយផ្កាយទាំងអស់ក៏ស្តាប់បង្គាប់តាមទ្រង់។ - Watts*

---

**ព្រះដែលទ្រទ្រង់សកលលោកទាំងមូល**
**ទ្រង់នឹងមិនដែលបំភ្លេចអ្នកឡើយ។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ទំនុកដំកើង១៤៧:១-៩

១ ចូរសរសើរដល់ព្រះយេហូវ៉ា ដ្បិតការដែល
ច្រៀងសរសើរ ដល់ព្រះនៃយើងខ្ញុំ នោះជាការ
សំណំហើយ ក៏ពីរោះផង សេចក្ដីសរសើរជា
ការគួរគប្បី ២ ព្រះយេហូវ៉ាទ្រង់កំពុងតែសង់
ក្រុងយេរូសាឡិមឡើង ទ្រង់កំពុងតែប្រមូល
ពួកសាសន៍អ៊ីស្រាអែល ដែលត្រូវបំបរទៅជា
ឈ្លើយមកវិញ ៣ ទ្រង់ប្រោសអស់អ្នកដែល
មានចិត្តសង្រេងឲ្យបានជា ក៏រុំរបួសឲ្យគេផង
៤ ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយ ក៏ហៅបាន
តាមទាំងអស់ ៥ ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំ
ប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង ឯ
ប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់
៦ ព្រះយេហូវ៉ាទ្រង់ទប់ទល់មនុស្សរាបសា តែប
ង្គ្រាបពួកមនុស្សអាក្រក់ចុះដល់ដីវិញ ៧ ចូរ
ច្រៀងថ្វាយព្រះយេហូវ៉ា ដោយពាក្យអរព្រះ
គុណ ចូរច្រៀងបទសរសើរដល់ព្រះនៃយើងខ្ញុំ
ដោយចាប់ស៊ុង ៨ ទ្រង់បាំងមេឃដោយពពក
ក៏ចាត់ចែងភ្លៀងសំរាប់ផែនដី ហើយធ្វើឲ្យមាន
ស្មៅដុះឡើងនៅលើភ្នំ ៩ ទ្រង់ប្រទានអាហារ
ដល់សត្វទាំងប៉ុន្មានព្រមទាំងដល់កូនក្អែក
ដែលយំផង។

### ការស្វែងយល់

បទគម្ពីរទំនុកតម្កើង ១៤៧:១-៩ បានថែងអំពីភាពខុសប្លែកគ្នាមួយចំនួន។ បទគម្ពីរនេះ មិនគ្រាន់តែបានពិពណ៌នាអំពីវិសាលភាព នៃសមត្ថភាពរបស់ព្រះប៉ុណ្ណោះទេ តែថែមទាំងបានបកស្រាយអំពីភាពជិតស្និទ្ធ នៃការយកព្រះទ័យទុកដាក់របស់ទ្រង់ផងដែរ។ ព្រះអម្ចាស់ទ្រង់មិនគ្រាន់តែបានយកព្រះទ័យទុកដាក់ចំពោះជាតិសាសន៍ទាំងឡាយប៉ុណ្ណោះទេ(ខ.២) តែថែមទាំងបានយកព្រះទ័យទុកដាក់ចំពោះអ្នកដែលមានចិត្តខ្ទេចខ្ទាំ និងចំពោះស្នាមរបួសដែលពួកគេមានផងដែរ(ខ.៣)។ ទ្រង់បានដាក់ពពក នៅលើផ្ទៃមេឃ(ខ.៨) តែទ្រង់នៅតែយកព្រះទ័យទុកដាក់ចំពោះស្នាព្រះហស្តដ៏តូចបំផុតរបស់ទ្រង់(ខ.៩)។ តើយើងមានការលើកទឹកចិត្តខ្លាំងប៉ុណ្ណានៅពេលបានដឹងថា ព្រះដែលបានបង្កើតសកលោក និងគ្រប់គ្រងជាតិសាសន៍ទាំងឡាយ ទ្រង់យកព្រះទ័យទុកដាក់យ៉ាងខ្លាំងចំពោះយើង !

សប្ដាហ៍ទី១ ថ្ងៃព្រហស្បត្តិ៍

# ផ្កាយនៅលើបង្អួច

សូមអាន
អេភេសូរ ២:១-១០

ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១។
- យ៉ូហាន ៣:១៦

ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ នៅសហរដ្ឋអាមេរិក តាមទំនៀមទម្លាប់ គ្រួសារដែលមានកូនប្រុសចូលបម្រើកងទ័ព ត្រូវព្យួររូបផ្កាយមួយ នៅមាត់បង្អួចខាងមុខ នៃផ្ទះរបស់ពួកគេ។ ប៉ុន្តែ ផ្កាយពណ៌មាស គឺជានិមិត្តរូបបញ្ជាក់ថា កូនប្រុសរបស់គ្រួសារនោះ បានពលីជីវិតដើម្បីបុព្វហេតុនៃប្រទេសជាតិរបស់ខ្លួនហើយ។

ជាច្រើនឆ្នាំកន្លងទៅ លោកហារី ឡូឌ័រ(Sir Harry Lauder)បានចែកចាយអំពីរឿងដ៏ប៉ះពាល់ចិត្តមួយ ដែលទាក់ទងនឹងទំនៀមទម្លាប់នេះ។ គាត់បានមានប្រសាសន៍ថា នៅពេលយប់មួយ មានបុរសម្នាក់បានដើរតាមផ្លូវទីក្រុងញូយ៉ក ជាមួយនឹងកូនប្រុសរបស់គាត់ អាយុ៥ឆ្នាំ។ ក្មេងតូចម្នាក់នេះ មានការចាប់អារម្មណ៍ចំពោះបង្អួចផ្ទះទាំងឡាយ ដែលគេបានដាក់ពន្លឺចែងចាំង ហើយវាចង់ដឹងអំពីមូលហេតុ ដែលផ្ទះខ្លះមានរូបផ្កាយដាក់តាំងនៅលើបង្អួច។ បុរសជាឪពុកក៏បានពន្យល់ថា គ្រួសារដែលនៅក្នុងផ្ទះទាំងនោះ មានកូនប្រុស ដែលបានពលីជីវិតនៅក្នុងសមរភូមិ។ ក្មេងតូចនេះវាក៏ទះដៃ នៅពេលដែលវាបានឃើញរូបផ្កាយ នៅលើបង្អួចផ្ទះមួយទៀត ហើយវាស្រែកសួរថា "ប៉ា មើលហ្ន៎ គ្រួសារមួយនោះ ក៏បានលះបង់កូនប្រុសរបស់ខ្លួន ដើម្បីប្រទេសជាតិដែរ"។

នៅទីបំផុតពួកគេក៏បានដើរទៅដល់ទីធ្លាទទេមួយ នៅចន្លោះនៃជួរផ្ទះទាំងឡាយ។ នៅតាមចន្លោះនោះ គេអាចមើលឃើញផ្កាយមួយ រះនៅលើមេឃយ៉ាងភ្លឺចិញ្ចែង។ ក្មេងតូចនេះក៏បានដកដង្ហើមធំ ហើយនិយាយថា "ប៉ា មើលហ្ន៎ មានផ្កាយមួយនៅលើបង្អួចនៃនគរស្ថានសួគ៌! ព្រះទ្រង់ប្រាកដជាបានលះបង់ព្រះបុត្រារបស់ទ្រង់ដែរហើយ"។

ជាការពិតណាស់ មានផ្កាយមួយ នៅមាត់បង្អួចរបស់ព្រះមែន។ តើអ្នកបានដឹងថាទ្រង់បានធ្វើអ្វីដើម្បីអ្នក? ដោយសារសេចក្ដីស្រឡាញ់ដែលទ្រង់មានចំពោះយើង ទ្រង់ប្រទានព្រះរាជបុត្រាទ្រង់(អេភេសូ ២:៤)។ តើអ្នកបានអរព្រះគុណទ្រង់ហើយឬនៅ?–M. R. De Haan

*ដ្បិតព្រះស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់*
*ឲ្យមកសុគតនៅលើឈើឆ្កាងនៅកាល់វ៉ារី ដើម្បីលោះខ្ញុំឲ្យរួចពីបាប*
*ថ្ងៃណាមួយ ទ្រង់នឹងយាងមកវិញ ដោយសិរីល្អ!*
*សេចក្ដីស្រឡាញ់ទ្រង់ពិតជាអស្ចារ្យណាស់។ - Townsend*

**មានមនុស្សជាច្រើនបានលះបង់ជីវិត ដើម្បីប្រទេសជាតិរបស់ខ្លួន**
**តែព្រះយេស៊ូវបានលះបង់ជីវិត ដើម្បីលោកិយទាំងមូល។**

# បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ អេភេសូ ២:១-១០

១ ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង
ហើយក្នុងអំពើបាបដែរ ២ ជាការដែលអ្នករាល់
គ្នាបានប្រព្រឹត្ត តាមរបៀបលោកីយ៍នេះ គឺ
តាមមេគ្រប់គ្រងរាជ្យលើអាកាស ជាវិញ្ញាណ
ដែលសព្វថ្ងៃនេះ បណ្តាលមកក្នុងពួកមនុស្ស
រឹងចចេស ៣ យើងរាល់គ្នាទាំងអស់ ក៏បាន
ប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្តី
ប៉ងប្រាថ្នារបស់សាច់ឈាមយើង ទាំងប្រព្រឹត្ត
សេចក្តីដែលសាច់ឈាម និងគំនិតយើងចង់
បានផង ហើយតាមកំណើតយើង នោះយើង
ជាមនុស្សជាប់ក្នុងសេចក្តីខ្ញាល់ ដូចជាមនុស្ស
ឯទៀតដែរ ៤ ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តី
មេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តី
ស្រឡាញ់ជាខ្លាំង ដែលទ្រង់មានដល់យើង
រាល់គ្នា ៥ ក្នុងកាលដែលយើងនៅ ស្លាប់ក្នុង
ការរំលងនៅឡើយ នោះទ្រង់បានប្រោសឲ្យ
យើងរាល់គ្នាបានរស់ ជាមួយនឹងព្រះគ្រីស្ទ គឺ
ដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ
៦ ហើយទ្រង់បានប្រោសឲ្យយើងរស់ឡើងវិញ
ក៏ឲ្យយើងអង្គុយជាមួយនឹងព្រះគ្រីស្ទ នៅ
ស្ថានដ៏ខ្ពស់ដែរ ៧ ដើម្បីឲ្យទ្រង់បាន សំដែង
ឲ្យអស់ទាំងកល្បខាងមុខ បានឃើញព្រះ
គុណដ៏ធ្ងន់លើសលប់របស់ទ្រង់ ដោយសេចក្តី
សប្បុរស ដែលទ្រង់ផ្តល់មកយើង ក្នុងព្រះគ្រី
ស្ទយេស៊ូវ ៨ ដ្បិតគឺដោយព្រះគុណ ដែលអ្នក
រាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ
ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នា
ដែរ គឺជាអំណោយទានរបស់ព្រះវិញ ៩ ក៏មិន
មែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួត
ខ្លួន ១០ ដ្បិតយើងរាល់គ្នាជា ស្នាដៃ ដែលទ្រង់
បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែល
ព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្ត
តាម។

## ការស្វែងយល់

បទគម្ពីរ **អេភេសូ ២:៨** បានចែងថា យើងបានសង្គ្រោះ គឺដោយសារ "ព្រះគុណ"។ នៅក្នុងព្រះគម្ពីរ ពាក្យ "ព្រះគុណ" មានន័យថា "ការប្រទាននូវអ្វីដែលយើងមិនសមនឹងទទួល" ឬអំណោយដែលយើងមិនអាចខិតខំធ្វើអំពើល្អ ដើម្បីឲ្យបានទទួល ឬខំស្វែងរកឲ្យបាននោះទេ។ យើងប្រហែលជាជឿថា យើងត្រូវខំធ្វើបុណ្យតាមសាសនា ដើម្បីឲ្យព្រះសព្វព្រះទ័យហើយ។ ទោះជាយ៉ាងណាក៏ដោយ បទគម្ពីរនេះ បានបញ្ជាក់យ៉ាងច្បាស់ថា យើងមិនអាចខំធ្វើល្អ ដើម្បីឲ្យបានទទួលសេចក្តីសង្គ្រោះនោះទេ។ ការអត់ទោសបាប និងជីវិតអស់កល្បជានិច្ច គឺជាអំណោយនៃព្រះគុណ ដែលព្រះបានប្រោសប្រទានដល់យើងទេ ហើយទ្រង់អាចប្រទានដល់យើងបាន តាមរយៈសេចក្តីសប្បុរស ដែលទ្រង់បានបង្ហាញដល់យើង នៅក្នុងព្រះយេស៊ូវគ្រីស្ទ(ខ.៧)។

សប្ដាហ៍ទី១ ថ្ងៃសុក្រ

# តើធ្វើដូចម្ដេច ឲ្យយើងដឹងថាព្រះមានមែន

សូមអាន
ហេព្រើ ១១:១-៧

អ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់ ។
- ហេព្រើ ១១:៦

មានអ្នកមិនជឿព្រះម្នាក់ បាននិយាយមកកាន់គ្រីស្ទបរិស័ទថា "តើអ្នកធ្លាប់ឃើញព្រះទេ? តើអ្នកធ្លាប់ប៉ះព្រះទេ? តើអ្នកធ្លាប់ធុំក្លិនព្រះទេ? បើអ្នកនិយាយថា ព្រះមានមែននោះ!"

បន្ទាប់ពីបានស្ងាត់មាត់ អស់មួយរយៈពេលវែង គ្រីស្ទបរិស័ទរូបនោះក៏បានឆ្លើយថា "ចុះ តើអ្នកធ្លាប់ឃើញខួរក្បាលខ្លួនឯងទេ? តើអ្នកធ្លាប់ប៉ះខួរក្បាលខ្លួនឯងទេ? តើអ្នកធ្លាប់ធុំក្លិនខួរក្បាលខ្លួនឯងទេ? បើអ្នកថា ខ្លួនឯងមានខួរក្បាលមែននោះ!"

មានមនុស្សតិចតួចណាស់ ដែលមិនជឿថាមានព្រះ ហើយពិតជាបានគិតយ៉ាងល្អិតល្អន់អំពីជីវិត ហើយសន្និដ្ឋានថា គ្មានព្រះទេ។ មានមនុស្សចំនួនច្រើនជាងនេះ ដែលមិនដឹង ថាតើព្រះមានមែនឬក៏អត់ទេ គឺពួកអ្នកដែលនឹងនិយាយថា "ខ្ញុំមិនដឹងទេ"។ ទោះជាយ៉ាងណាក៏ដោយ មានមនុស្សភាគច្រើនលើសលប់ ដែលជឿថា ព្រះមានមែន គឺយ៉ាងហោចណាស់ ពួកគេជឿ ដោយផ្អែកលើប្រាជ្ញាខ្លួន។

បទគម្ពីរហេព្រើ ១១:៦ បានចែងឲ្យយើងដឹងថា ការទទួលស្គាល់ថា ព្រះមានមែន គឺជាការបោះជំហានទីមួយ ឆ្ពោះទៅរកការស្គាល់ទ្រង់ ដោយផ្ទាល់ខ្លួន។ បន្ទាប់មក យើងត្រូវស្វែងរកទ្រង់ និងជឿថា ទ្រង់នឹងប្រទានពរដល់យើង នៅពេលយើងស្វែងរក ឲ្យបានស្គាល់ទ្រង់។

ការស្វែងរករបស់យើង នឹងនាំឲ្យយើងពិចារណាអំពីព្រះយេស៊ូវ នៅទីបញ្ចប់។ ទ្រង់បានប្រកាសថា "ខ្ញុំហើយ និងព្រះវរបិតា គឺតែ១ព្រះអង្គទេ"(យ៉ូហាន ១០:៣០)។ ទ្រង់ក៏បានមានបន្ទូលថា អ្នកដែលមានចិត្តចង់ស្ដាប់បង្គាប់ព្រះ នោះនឹងបានដឹងថា ព្រះយេស៊ូវទ្រង់ ពិតជាបានមានបន្ទូលអំពីការពិតមែន(យ៉ូហាន ៧:១៧)។

អ្នក ឬមនុស្សដែលអ្នកបានស្គាល់ អាចស្ថិតនៅក្នុងជំហានទីមួយ គឺៈ ការទទួលស្គាល់ថា ព្រះមានមែន។ សូមចាំថា ព្រះអម្ចាស់ទ្រង់ប្រទានរង្វាន់ដល់អ្នក ដែលស្វែងរកឲ្យបានស្គាល់ទ្រង់ ។ ហើយទំនាក់ទំនងជាមួយទ្រង់ អាចកើតមាន តែតាមរយៈសេចក្ដីជំនឿលើព្រះគ្រីស្ទប៉ុណ្ណោះ។ - Dennis De Haan

*ខ្ញុំបានខិតខំស្វែងរក អស់ពីចិត្តរបស់ខ្ញុំ ដើម្បីឲ្យបានដឹង*
*ថាព្រះមានមែនឬទេ*
*ទ្រង់បានបង្ហាញព្រះអង្គទ្រង់ ដោយព្រះគុណទ្រង់*
*សេចក្ដីមេត្តា សេចក្ដីស្រឡាញ់ និងព្រះទ័យទុកដាក់របស់ទ្រង់។ - Cetas*

---

**បើអ្នកកំពុងស្វែងរកព្រះ**
**នោះអ្នកនឹងរកឃើញទ្រង់ នៅក្នុងព្រះគ្រីស្ទ។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ហេព្រើ ១១:១-៧

១ រីឯសេចក្ដីជំនឿ នោះគឺជាចិត្តដែលដឹងជាក់
ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែល
មើលមិនឃើញ ២ ព្រះទ្រង់បានធ្វើបន្ទាល់ពី
មនុស្សចាស់បុរាណ ដោយព្រោះគេមានសេច
ក្ដីជំនឿនោះឯង ៣ យើងរាល់គ្នាក៏យល់
ដោយសារសេចក្ដីជំនឿនោះថា លោកីយ៍បាន
កើតមក ដោយសារព្រះបន្ទូលនៃព្រះ បានជា
របស់ដែលមើលឃើញទាំងប៉ុន្មាន នោះមិន
មែនកើតអំពីរបស់ដែលមើលឃើញទេ។
៤ ដោយសារ សេចក្ដីជំនឿ នោះអេបិលបាន
ថ្វាយយញ្ញបូជាដល់ព្រះ ដែលប្រសើរជាងដ
ង្វាយរបស់កាអ៊ីន ហើយមានសេចក្ដីបន្ទាល់ពី
គាត់ ដោយព្រោះយញ្ញបូជានោះថា គាត់
សុចរិត ទាំងមានព្រះធ្វើបន្ទាល់ពីដង្វាយគាត់
ផង បានជាទោះបើគាត់ស្លាប់ក៏ដោយ គង់តែ
នៅមាននិយាយទៅទៀត ដោយសារដង្វាយ
នោះឯង។
៥ ដោយសារ សេចក្ដីជំនឿ នោះហេណុកបាន
ឡើងទៅលើ មិនបានឃើញសេចក្ដីស្លាប់
ឡើយ ហើយគេរកគាត់មិនឃើញទៀត ពី
ព្រោះព្រះបានយកគាត់ទៅ ដ្បិតកាលមុន
ដែលលើកយកគាត់ទៅ នោះមានសេចក្ដី
បន្ទាល់ពីគាត់ថា ព្រះទ្រង់សព្វព្រះហឫទ័យ
នឹងគាត់ណាស់ ៦ តែបើឥតមានសេចក្ដី ជំនឿ
ទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះ
បានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ
នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់
ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់។
៧ ដោយសារ សេចក្ដីជំនឿ នោះព្រះបានមាន
ព្រះបន្ទូលពន្យល់លោកណូអេ ពីការដែល
មើលមិនទាន់ឃើញនៅឡើយ ហើយដោយ
លោកមានសេចក្ដីកោតខ្លាច បានជាលោកធ្វើ
ទូក១យ៉ាងធំសំរាប់នឹងជួយសង្គ្រោះដល់ពួក
គ្រួសារ របស់លោក ហើយលោកបានកាត់
ទោសលោកីយ៍ដោយការនោះ ក៏ត្រឡប់ជាអ្នក
គ្រងសេចក្ដីសុចរិត ដែលត្រូវខាងសេចក្ដីជំនឿ
ទុកជាមរដកដែរ។

### ការស្វែងយល់

បទគម្ពីរខាងលើនេះ បានប្រាប់យើងអំពីជីវិតពិត និងប្រាប់ឲ្យយើងដឹងថា ការមានជំនឿ ជាកត្តាដ៏សំខាន់។ ជាញឹកញាប់ យើងបានឮមនុស្សនិយាយអំពីសេចក្ដីជំនឿ តែយើងមិនអាចដឹងច្បាស់ថា អ្នកទាំងនោះមានជំនឿលើអ្វីទេ។ យើងមិនអាចគ្រាន់តែ "ជឿលើសេចក្ដីជំនឿ"បានទេ ពោលគឺមិនអាចគ្រាន់តែមានគំនិតវិជ្ជមាន ដោយគ្រាន់តែជឿថា អ្វីៗគ្រប់យ៉ាងនឹងមានភាពល្អប្រសើរនោះឡើយ។ យើងត្រូវមានជំនឿទៅលើអ្វីមួយ ហើយបទគម្ពីរហេព្រើជំពូក១១ បានលើកទឹកចិត្តយើងឲ្យយល់ថា សេចក្ដីជំនឿរបស់យើងមានន័យ តែនៅពេលដែលយើងជឿលើព្រះដ៏ពិត និងមានព្រះជន្មរស់ប៉ុណ្ណោះ។

# មូលហេតុទាំង១០យ៉ាង ដែលត្រូវជឿថា ព្រះពិតជាមានមែន

## ១. មនុស្សជៀសមិនរួចពីការមានជំនឿឡើយ

មនុស្សម្នាក់ៗសុទ្ធតែជឿលើអ្វីមួយ។ អ្នកដែលមិនជឿព្រះមិនអាចបង្ហាញថា គ្មានព្រះបានឡើយ។ ពួកគេមិនអាចជៀសផុតពីការមានជំនឿបានទេ ទោះបីជាពួកគេបានសម្រេចចិត្តជឿតែលើខ្លួនឯងក៏ដោយ។

## ២. លទ្ធភាពរបស់វិទ្យាសាស្ត្រ គឺមានកំណត់

វិធីស្រាវជ្រាវតាមវិទ្យាសាស្ត្រ គ្រាន់តែអាចជួយឲ្យមនុស្សសិក្សា អំពីអ្វីដែលគេអាចវាស់ស្ទង់បាន និងកើតមានម្តងទៀតប៉ុណ្ណោះ។ មានន័យថា គេមិនអាចប្រើវិធីសាស្ត្រនេះ ដើម្បីបកស្រាយអំពីប្រភពដើមដំបូងបំផុតនៃជីវិត អត្ថន័យនៃជីវិត និងសីលធម៌បានទេ។ វិទ្យាសាស្ត្រមិនបានផ្តល់ឲ្យនូវការបង្រៀនអំពីសីលធម៌ និងតម្លៃនៃសីលធម៌ ដើម្បីជួយដល់ការរស់នៅរបស់យើងឡើយ។ និយាយរួមវិទ្យាសាស្ត្រគ្រាន់តែអាចបង្ហាញឲ្យយើងដឹង អំពីរបៀបដែលច្បាស់ធម្មជាតិដំណើរការ តែមិនអាចប្រាប់ឲ្យយើងដឹងអំពីប្រភពដើមនៃច្បាប់ធម្មជាតិទេ។

## ៣. បញ្ហានៃការវិវឌ្ឍន៍

ការពន្យល់អំពីការវិវត្តន៍នៃជីវិត មិនអាចធ្វើឲ្យព្រះគ្មានសារៈសំខាន់ឡើយ។ ទោះបីជាយើងសន្និដ្ឋានថា ថ្ងៃណាមួយ អ្នកវិទ្យាសាស្ត្រនឹងស្វែងរកឃើញ "ការជាប់ទាក់ទង ដែលបានបាត់" ដើម្បីបញ្ជាក់ថា ជីវិតបានលេចមានឡើង និងវិវត្តបន្តិចម្តងៗ អស់រយៈពេលដ៏យូរក្រៃលែងក៏ដោយ ក៏ច្បាប់នៃភាពដែលអាចកើតមាន នឹងនៅតែបង្ហាញថា របស់សព្វសារពើមិនអាចកើតមានបានឡើយ បើគ្មានព្រះអទិករបង្កើតវាមកទេនោះ។ សកលលោកទាំងមូលដ៏ធំល្វឹងល្វើយ និងពោរពេញដោយភាពស្មុគ្រស្មាញ គឺមិនកើតមានឡើង ដោយឯកឯងឡើយ។ អ្នកវិទ្យាសាស្ត្រខាងការវិវត្តន៍ជាច្រើន បានទទួលស្គាល់ភាពដែលអាចមាន ឬទទួលស្គាល់ថា ទំនងជាមានអ្នករៀបចំដ៏មានប្រាជ្ញាម្នាក់ ដែលបានបង្កើតរបស់សព្វសារពើមក។

## ៤. ទម្លាប់នៃចិត្តមនុស្ស

គេបានពិពណ៌នាថា មនុស្សជាតិមិនអាចឈប់មានជំនឿសាសនាបានទេ។ ពួកគេគិត ឬនិយាយទៅរកព្រះ ដោយមិនដឹងខ្លួន នៅពេលពួកគេមានរឿងអសន្ទ ឬការភ្ញាក់ផ្អើល ក៏ដូចជានៅក្នុងពេលអធិស្ឋាន ឬក៏នៅក្នុងពេលប្រើពាក្យប្រមាថព្រះផងដែរ។ ការដែលមនុស្សយើងបដិសេធន៍ថាព្រះមិនមានវត្តមាន មិនបានធ្វើឲ្យពួកគេឈប់ប្រាថ្នាចង់បានអ្វីមួយ បន្ទាប់ពីពួកគេបានស្លាប់ឡើយ(សាស្តា ៣:១១)។ សូម្បីតែនៅពេលយើងខឹងនឹងព្រះ ដែលបានអនុញ្ញាតឲ្យមានភាពអយុត្តិធម៌ និងការឈឺចាប់កើតមានឡើង ក៏យើងនៅតែងាកទៅរកក្រមសីលធម៌ដើម្បីលើកហេតុផលថា ជីវិតរបស់មនុស្សមិនបានប្រព្រឹត្តទៅ តាមការគួរទេ(រ៉ូម ២:១៤-១៥)។ ដូចនេះ យើងមានទំនោរទៅរកការអ្វី ដែលខ្ពង់ខ្ពស់ជាងខ្លួនយើង ជាជាងងាកទៅរកអ្វីដែលតូចទាបជាងខ្លួនយើង។

## ៥. ប្រវត្តិនៃលោកុប្បត្តិ

ព្រះគម្ពីរបានចាប់ផ្តើមដោយពាក្យថា "កាលដើមដំបូងឡើយ ព្រះ..."(លោកុប្បត្តិ ១:១) ដែលនេះជាពាក្យសន្មត់ថា ព្រះមានមែន។ ព្រះគម្ពីរលោកុប្បត្តិត្រូវបាននិពន្ធឡើង នៅក្នុងសម័យកាលមួយ ក្នុងប្រវត្តិសាស្ត្រ។ ពួកអ៊ីស្រាអែលបានភាសខ្លួនចេញពីនគរអេស៊ីព្ទ ហើយពួកសាសន៍យូដា និងសាសន៍អេស៊ីព្ទរាប់លាននាក់បានឃើញការអស្ចារ្យជាច្រើនកើតឡើងនៅពេលនោះ។ ចាប់តាំងពីសម័យដែលពួកគេភាសខ្លួន រហូតមកដល់សម័យដែលព្រះម៉ែស៊ីយាងមក ព្រះនៃព្រះគម្ពីរ បានធ្វើការអស្ចារ្យជាច្រើន ដែលមនុស្សជាច្រើនបានឃើញផ្ទាល់ភ្នែក នៅក្នុងពេលវេលា និងទីកន្លែងដ៏ជាក់លាក់។ អ្នកដែលសង្ស័យថា គ្មានព្រះ អាចទៅទស្សនាទីកន្លែង និងមនុស្សពិតៗ ដើម្បីស្វែងរកភ័ស្តុតាងដោយខ្លួនឯង។

## ៦. ជនជាតិអ៊ីស្រាអែល

មនុស្សជាច្រើនពិបាកនឹងជឿថា ក្នុងពិភពលោកនេះ មានព្រះដែលមានភាពលំអៀងទៅលើជនជាតិអ៊ីស្រាអែល ដែលជា "រាស្ត្រជ្រើសតាំងរបស់ទ្រង់"។ ហើយពួកគេកាន់តែពិបាកនឹងជឿថា មានព្រះ ដែលមិនបានការពារ "រាស្ត្រជ្រើសតាំងរបស់ទ្រង់" ឲ្យជៀសផុតពីសោកនាដកម្មនៃសង្គ្រាមលោកលើកទីពីរ។ តែព្រះគម្ពីរបានចែងទុកជាមុន អំពីអនាគតនៃសាសន៍អ៊ីស្រាអែលចាប់តាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រនៃគ្រាសញ្ញាចាស់ម្ល៉េះ។ លោកម៉ូសេ និងពួកហោរាដទៃទៀត មិនគ្រាន់តែបានថ្លែងទំនាយថា ពួកអ៊ីស្រាអែលនឹងបានចូលទៅចាប់យកទឹកដីសន្យាប៉ុណ្ណោះទេ តែថែមទាំងបានថ្លែងទំនាយអំពីទុក្ខវេទនាដ៏ធ្ងន់ធ្ងរបំផុត និងការសាត់ព្រាត់របស់

ជនជាតិមួយនេះ នៅទូទាំងពិភពលោក និងអំពីការប្រែចិត្តដែលពួកគេនឹងមាន ហើយអំពីការស្តាងឡើងវិញនៃជនជាតិនេះ នៅគ្រាចុងក្រោយ(ចោទិយកថា ២៨-៣៤ អេសាយ ២:១-៥ អេសេគាល ៣៧-៣៨)។

## ៧. ការអះអាងរបស់ព្រះគ្រីស្ទ

អ្នកខ្លះនិយាយថា "បើព្រះទ្រង់សព្វព្រះទ័យឲ្យយើងជឿលើទ្រង់ នោះទ្រង់បង្ហាញឲ្យយើងឃើញព្រះអង្គទ្រង់ហើយ"។ តាមព្រះគម្ពីរ យើងអាចដឹងថា ព្រះទ្រង់បានបង្ហាញឲ្យមនុស្សឃើញព្រះអង្គទ្រង់មែន។ ព្រះទ្រង់បានយាងមកយកកំណើតជាមនុស្ស ដែលមានព្រះនាមថា យេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវបានមានបន្ទូលថា "ខ្ញុំហើយ និងព្រះវរបិតា គឺតែ១ព្រះអង្គទេ"(យ៉ូហាន ១០:៣០) "អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ"(យ៉ូហាន ១៤:៩)។

## ៨. ភស្តុតាងនៃការអស្ចារ្យ

បើសិនជាសមុទ្រក្រហមមិនបានញែកចេញពីគ្នា ដូចដែលលោកម៉ូសេបានចែងក្នុងព្រះគម្ពីរទេ នោះព្រះគម្ពីរសញ្ញាចាស់មិនមានអំណាចអ្វី នៅក្នុងការចែងអំពីព្រះទេ។ ការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើ ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទី៣ គឺបញ្ជាក់ថា ព្រះយេស៊ូវគឺពិតជាព្រះមែស៊ី ដូចដែលទ្រង់បានអះអាងមែន។

## ៩. ភាពលម្អិតនៃធម្មជាតិ

មានមនុស្សដែលបានលើកហេតុផលថា ព្រះដែលមានភាពអស្ចារ្យល្មមនឹងអាចបង្កើតសកលោកបាន ទ្រង់ធំពេកហើយ គឺមិនអាចខ្វល់អំពីយើងដែលជាស្នាព្រះហស្តដ៏តូចទេ។ ទោះជាយ៉ាងណាក៏ដោយព្រះយេស៊ូវបានបង្ហាញថា ព្រះទ្រង់ធំល្មមនឹងអាចយកព្រះទ័យទុកដាក់ចំពោះផ្នែកដ៏តូចល្អិតបំផុតនៃជីវិតរបស់យើង។ ព្រះទ្រង់មិនគ្រាន់តែបានជ្រាបអំពីចលនានីមួយៗ ដែលយើងមានប៉ុណ្ណោះទេ តែថែមទាំងបានបណ្តាលចិត្ត និងពិចារណាអំពីចិត្តរបស់យើងផងដែរ។ ព្រះទ្រង់ជ្រាបអំពីចំនួនសក់ដែលមាននៅលើក្បាលយើង ការព្រួយបារម្ភដែលមានក្នុងចិត្តយើង និងសូម្បីតែចាបមួយដែលបានធ្លាក់ចុះ ក៏ទ្រង់ជ្រាបដែរ(ទំនុកតម្កើង ១៣៩ ម៉ាថាយ ១០:២៩)។

## ១០. បទពិសោធន៍

ព្រះគម្ពីរបានចែងថា ព្រះទ្រង់បានរៀបចំកាលៈទេសៈក្នុងជីវិតរបស់យើង តាមរបៀបដែលនាំឲ្យយើងស្វែងរកទ្រង់(កិច្ចការ ១៧:២៦-២៧)។ ចំពោះអ្នកដែលស្វែងរកទ្រង់ ព្រះគម្ពីរក៏

បានចែងផងដែរថា ទ្រង់គង់ជិតល្មមនឹងឲ្យយើងរកឃើញទ្រង់(កិច្ចការ ១៧:២៧-២៨)។

ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានចែងច្បាស់ថា យើងត្រូវឈោងទៅរកទ្រង់ តាមវិធីរបស់ទ្រង់ គឺមិនមែនតាមមធ្យោបាយរបស់យើងទេ។ ទ្រង់សន្យាថា យើងនឹងរកឃើញទ្រង់ តែមិនមែនមនុស្សគ្រប់រូបសុទ្ធតែរកឃើញទ្រង់នោះទេ គឺមានតែអ្នកដែលបានទទួលស្គាល់ថា ខ្លួនត្រូវការទ្រង់ ហើយព្រមទុកចិត្តលើទ្រង់ ជាជាងទុកចិត្តលើខ្លួនឯងប៉ុណ្ណោះ ដែលអាចរកទ្រង់ឃើញ។

## មិនមែនមានតែអ្នកទេដែលមានបញ្ហានេះ

បើសិនជាអ្នកបើកចំហរចិត្តជឿថា មានព្រះ តែមិនបានដឹងច្បាស់ ថាតើអ្នកអាចទទួលស្គាល់ការអះអាងរបស់ព្រះយេស៊ូវថា ទ្រង់ជា "ព្រះដែលបានយកកំណើតជាសាច់ឈាម"ឬក៏អត់ នោះមិនមែនមានតែអ្នកទេដែលមានបញ្ហានេះ។ គ្រូបង្រៀនដែលមកពីស្រុកណាសារ៉ែតរូបនេះ បានសន្យាថា នឹងជួយដល់អ្នកដែលចង់ស្គាល់ព្រះ ហើយចង់ធ្វើតាមព្រះទ័យទ្រង់។ ទ្រង់មានបន្ទូលថា " បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ"(យ៉ូហាន ៧:១៧)។

បើអ្នកពិតជាបានឃើញភស្ដុតាង ដែលបានបញ្ជាក់អំពីព្រះដែលបានបង្ហាញព្រះអង្គទ្រង់ដល់យើង តាមរយៈព្រះរាជបុត្រាទ្រង់ នោះសូមចងចាំថា ព្រះគម្ពីរបានចែងថា ព្រះគ្រីស្ទបានសុគត ដើម្បីបង់ថ្លៃលោះបាបយើង ហើយអស់អ្នកដែលជឿលើទ្រង់ នឹងបានទទួលអំណោយដែលជាសេចក្ដីសង្គ្រោះ និងជីវិតអស់កល្បជានិច្ច។ សេចក្ដីសង្គ្រោះដែលព្រះគ្រីស្ទប្រទាន គឺមិនមែនជារង្វាន់ សម្រាប់ការប្រឹងប្រែងរបស់យើងនោះទេ តែជាអំណោយដល់អស់អ្នក ដែលបានជឿទ្រង់ ដោយផ្អែកលើភស្ដុតា(យ៉ូហាន ៥:២៤ រ៉ូម ៤:៥ អេភេសូ ២:៨-១០)។

សម្រាប់ការអានបន្ថែម សូមរកមើលសៀវភៅ :

**តើធ្វើដូចម្ដេចឲ្យខ្ញុំដឹងថា មានព្រះមួយអង្គ?**

សប្ដាហ៍ទី២ ថ្ងៃច័ន្ទ

# ចូរកុំចាំដល់ពេលដែលអ្នកលែងមានឱកាសធ្វើការល្អ

សូមអាន
រ៉ូម ១២:៩-១៦

---

ខាងឯសេចក្ដីស្រឡាញ់ជាបងជាប្អូន នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅមកចុះ ខាងឯសេចក្ដីរាប់អាន នោះឲ្យខំរាប់អានគេជាមុនៗ - រ៉ូម ១២:១០

---

ចំពោះអ្នកដែលបានធ្វើការល្អសម្រាប់អ្នក តើអ្នកដឹងថាត្រូវនិយាយពាក្យអ្វីទៅកាន់អ្នកនោះ ដោយគិតយ៉ាងល្អិតល្អន់ជាមុនឬទេ? ឬចំពោះមិត្តភក្រដែលហាក់ដូចជាបាក់ទឹកចិត្ត តើអ្នកដឹងអំពីពាក្យដែលត្រូវសរសេរលើកទឹកចិត្ត ដល់គាត់ឬទេ? អ្នកប្រហែលជាត្រូវធ្វើនូវកិច្ចការដ៏សប្បុរសនេះ នៅពេលឥឡូវនេះ ព្រោះអ្នកមិនអាចដឹងជាមុន ថាតើអ្នកនឹងមានឱកាសនៅពេលក្រោយទៀតឬក៏អត់ទេ។

ពេលដែលយើងគិតអំពីការប្រព្រឹត្ត តាមបំណងចិត្តដ៏សប្បុរសរបស់ខ្លួន នោះយើងអាចរៀនសូត្រពីគំរូរបស់លោក ឆាល អ ហេនវើស ជូនា(Charles R. Haynsworth Jr) ដែលជាអ្នកធ្វើជំនួញម្នាក់ ដែលបានលើកទឹកចិត្តបុគ្គលិករបស់ខ្លួន យ៉ាងទាន់ពេលវេលា។

ទោះបីជាតាមធម្មតា លោក ហេអ៊ិនវើស មិនទទួលបន្ទុកចុះហត្ថលេខាលើវិក័យប័ត្រប្រាក់ខែ របស់បុគ្គលិកក៏ដោយ ក៏នៅខែកញ្ញា ឆ្នាំ ១៩៩៤ គាត់ក៏បានធ្វើកិច្ចការមួយនេះ។ អ្នកដែលទទួលបន្ទុកចុះហត្ថលេខាមិនមានវត្តមាន នៅការិយាល័យទេ ដូចនេះ គាត់ក៏បានធ្វើជំនួសពួកគេ។ ពេលដែលលោកហេនវើសបានចុះហត្ថលេខាលើវិក័យប័ត្រហើយ គាត់ក៏បានភ្ជាប់ពីលើវិក័យប័ត្រនោះ ដោយកូនក្រដាស់មួយ ដោយសរសេរពាក្យថ្លែងអំណរគុណ ដល់បុគ្គលិករបស់គាត់ ចំពោះកិច្ចការរបស់ពួកគេ។

នៅថ្ងៃបន្ទាប់ លោកឆាល ហេនវើស ក៏បានលាចាកលោកទៅ ដោយមិននឹកស្មានដល់ តែការបាត់បង់ជីវិតរបស់គាត់ មិនមែនដោយសារការនិយាយពាក្យថ្លែងអំណរគុណចុងក្រោយនៅក្នុងកូនក្រដាស សម្រាប់បុគ្គលិកនីមួយៗរបស់គាត់នោះទេ។

សេចក្ដីសប្បុរសដែលយើងមានចំពោះអ្នកដទៃ គឺជាភស្តុតាងបញ្ជាក់អំពីសេចក្ដីជំនឿដែលយើងមានចំពោះព្រះគ្រីស្ទ(យ៉ូហាន ១៣:៣៥ រ៉ូម ១២:១០)។ នៅថ្ងៃនេះ សូមចំណាយពេលសរសេរពាក្យថ្លែងអំណរគុណ ឬធ្វើនូវកិច្ចការដ៏សប្បុរសជាពិសេស ដល់អ្នកជាទីស្រឡាញ់របស់អ្នកចុះ។ សូមកុំរង់ចាំ ដល់ពេលដែលអ្នកលែងមានឱកាសឡើយ។ - Dave Branon

*សូមឲ្យយើងធ្វើខ្លួនជាសិស្សដ៏ពិតរបស់ព្រះគ្រីស្ទ*
*ដោយបំពេញសេចក្ដីត្រូវការឲ្យគ្នាទៅវិញទៅមក*
*ដោយពង្រៀបផ្លូវដែលរដេបរដុប*
*ដោយពាក្យដ៏ស្រទន់ និងដោយធ្វើការល្អ។ - Thorson*

---

**ការឆាប់ធ្វើល្អ គឺមិនខុសទេ**
**តែមិនត្រូវចាំទាល់តែយឺតពេលពេកឡើយ។**

# បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ រ៉ូម ១២:៩-១៦

៩ចូរឲ្យមានសេចក្តីស្រឡាញ់ឥតពុតមាយា
ទាំងខ្ពើមសេចក្តីអាក្រក់ ហើយកាន់ខ្ជាប់ខាង
សេចក្តីល្អវិញ ១០ ខាងឯសេចក្តីស្រឡាញ់ ជា
បងជាប្អូន នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅ
មកចុះ ខាងឯសេចក្តីរាប់អាន នោះឲ្យខំរាប់
អានគេជាមុន ១១ ខាងឯសេចក្តីឧស្សាហ៍ នោះ
កុំឲ្យខ្ជិលឡើយ ខាងឯវិញ្ញាណ នោះក៏ចូរ
ព្យាយាមចុះ ដោយខំប្រឹងបំរើព្រះអម្ចាស់
១២ ចូរអរសប្បាយ ដោយមានសង្ឃឹម ចូរអត់
ធន់ក្នុងសេចក្តីទុក្ខលំបាក ចូរឲ្យខ្ជាប់ខ្ជួនក្នុង
សេចក្តីអធិស្ឋាន ១៣ ខាងសេចក្តីខ្វះខាតរបស់
ពួកបរិសុទ្ធ នោះក៏ចូរផ្គត់ផ្គង់ឲ្យ ទាំងខំប្រឹងឲ្យ
មានសេចក្តីចៅរ៉ៅផងចុះ ១៤ ចូរសូមពរឲ្យដល់
អ្នកណាដែលបៀតបៀនអ្នក ចូរសូមពរចុះ កុំ
ឲ្យប្រទេចផ្តាសាឡើយ ១៥ ចូរអរសប្បាយ ជា
មួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជា
មួយនឹងអ្នកណាដែលយំផង ១៦ ចូរឲ្យមាន
គំនិតព្រម ព្រៀងគ្នាទៅវិញទៅមក កុំឲ្យមាន
គំនិតឆ្មើងឆ្មៃសោះឡើយ គឺត្រូវភប់ប្រសព្វនឹង
មនុស្សរាបសាវិញ កុំឲ្យទុកចិត្តនឹងខ្លួន ថាមាន
ប្រាជ្ញាឲ្យសោះ។

## ការស្វែងយល់

ក្នុងការរស់នៅរបស់យើង មានទំនាក់ទំនងជាច្រើន គឺទំនាក់ទំនងជាមួយព្រះ និងជាមួយអ្នកដទៃ។ នៅក្នុងបទគម្ពីររ៉ូម ជំពូក ១២ លោកប៉ុលបានបកស្រាយថា ទំនាក់ទំនងដែលគ្រីស្ទបរិស័ទមានជាមួយព្រះ គឺត្រូវបង្ហាញចេញតាមរយៈទំនាក់ទំនងរបស់ពួកគេ ជាមួយអ្នកដទៃ។ សូមកត់សំគាល់អំពីគោលការណ៍ ដែលសាវ័កប៉ុលបានលើកទឹកចិត្តឲ្យយើងប្រើ នៅក្នុងទំនាក់ទំនងរបស់យើង ដូចជា ការគ្មានពត់មាយា(ខ.៩) ការបន្ទាបខ្លួន(ខ.១០) ភាពសប្បុរស(ខ.១៣) សេចក្តីស្រឡាញ់ចំពោះខ្មាំងសត្រូវរបស់យើង(ខ.១៤) ការអាណិត(ខ.១៥) ការបើកចំហរចិត្តចំពោះអ្នកដទៃ និងចំពោះក្តីបារម្ភរបស់ពួកគេ(ខ.១៦)។ គោលការណ៍នេះអាចជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងដ៏រឹងមាំ បើយើងបន្តអនុវត្តតាមឥតឈប់ឈរ។

សប្ដាហ៍ទី២ ថ្ងៃអង្គារ

# សេចក្ដីស្រឡាញ់ ធ្វើឲ្យឈឺចាប់

សូមអាន
១យ៉ូហាន ៤:៧-១៦

នេះជាសេចក្ដីបញ្ញត្ត របស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។
- យ៉ូហាន ១៥:១២

ជួនកាល សេចក្ដីស្រឡាញ់ពិតជានាំឲ្យមានការឈឺចាប់មែន!" នេះជាពាក្យដែលឪពុកម្ដាយបានប្រើ ដើម្បីបង្ហាញពីការលំបាក និងការឈឺចិត្ត នៅក្នុងការអប់រំកូនៗរបស់ខ្លួន ដែលកំពុងឆ្លងកាត់វ័យជំទង់។ បុរសជាឪពុកក៏និយាយបន្ថែមទៀតថា "បើយើងមិនសូវស្រឡាញ់ពួកវាខ្លាំងពេកទេ នោះយើងក៏ប្រហែលមិនសូវមានការលំបាកដែរ"។

សេចក្ដីស្រឡាញ់អាចនាំឲ្យមានការឈឺចាប់ និងទុក្ខព្រួយ ប៉ុន្តែ បើយើងគ្មានសេចក្ដីស្រឡាញ់សោះទេ តើជីវិតរបស់យើងនឹងទៅជាយ៉ាងណា? លោកស៊ី អេស លូវីស (C. S. Lewis) ដែលជាអ្នកនិពន្ធសៀវភៅ "*សេចក្ដីស្រឡាញ់ទាំងបួន*" បានសរសេរនៅក្នុងសៀវភៅនេះថា ៖

"សេចក្ដីស្រលាញ់នាំឲ្យយើងងាយរងគ្រោះ។ ចូរស្រឡាញ់អ្វីៗដោយមិនរើសមុខចុះ នោះអ្នកនឹងឈឺចាប់ ហើយអាចខូចចិត្តផង។ បើអ្នកមិនចង់ឲ្យចិត្តប្រេះស្រាំទេ នោះចូរកុំប្រគល់ចិត្តឲ្យទៅនរណាម្នាក់ ឬឲ្យទៅសត្វណាមួយឡើយ។ ចូរហុំព័ទ្ធចិត្តរបស់អ្នកយ៉ាងប្រុងប្រយ័ត្ន ដោយការកម្សាន្តសប្បាយ និងភាពធើតឆាយបន្តិចបន្តួច ចូរជៀសវាងភាពស្មុគ្រស្មាញ ហើយចូរចាក់សោរចិត្តរបស់អ្នកទុក នៅក្នុងហិប ឬក្ដាមឈូសនៃភាពអាត្មានិយមរបស់អ្នកចុះ ... ក្រៅពីនគរស្ថានសួគ៌ មានតែស្ថាននរកទេ ដែលជាកន្លែងដែលអ្នកនឹងមិនទទួលរងគ្រោះថ្នាក់ ដោយសារសេចក្ដីស្រឡាញ់សោះឡើយ"។

ការស្រឡាញ់ គឺជាការប្រថុយ ដោយបើកចំហរចិត្តរបស់យើង។ ជួនកាលយើងឈឺចាប់! ដោយសារសេចក្ដីស្រឡាញ់ព្រះយេស៊ូវបានរងការឈឺចាប់ តែទ្រង់នៅតែស្រឡាញ់ ទោះជាទ្រង់ត្រូវសុគតក៏ដោយ។ ហើយទ្រង់បានបង្គាប់យើងថា "ចូរអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"(យ៉ូហាន ១៥:១២)។

កាលណាយើងពិតជាស្រឡាញ់ប្ដីឬប្រពន្ធរបស់យើង ក្មេងជំទង់នោះ អ្នកជិតខាងនោះ ឬមិត្តរួមការងារនោះ នោះមានន័យថា យើងមានលក្ខណៈដូចព្រះគ្រីស្ទហើយ ហើយការធ្វើដូចនេះប្រសើរជាងការចាក់សោរចិត្តរបស់អ្នក នៅក្នុងក្ដាមឈូសនៃភាពអាត្មានិយម។ - Dave Egner

*សូមគិតឡើងវិញ*
*តើអ្នកធ្លាប់ឈឺចាប់ដោយសារអ្នកដែលខ្លួនខំស្រឡាញ់ឬទេ?*
*តើអ្នកធ្លាប់ត្រូវបានល្បួង ឲ្យលែងផ្ដល់*
*សេចក្ដីស្រឡាញ់ដល់អ្នកនោះ ដោយសារការឈឺចាប់នោះឬទេ?*

---

**គ្មានអ្វីដែលនាំឲ្យមានការលះបង់ខ្លាំង ដូចសេចក្ដីស្រឡាញ់ទេ**
**តែការគ្មានសេចក្ដីស្រឡាញ់នាំឲ្យមានការខាតបង់ខ្លាំងបំផុត។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១យ៉ូហាន ៤:៧-១៦

៧ ពួកស្ងួនភ្ងាអើយ យើងត្រូវស្រឡាញ់គ្នាទៅ
វិញទៅមក ដ្បិតសេចក្ដីស្រឡាញ់មកពីព្រះ ឯ
អស់អ្នកណាដែលមានសេចក្ដីស្រឡាញ់ នោះ
ឈ្មោះថាមកពីព្រះ ហើយក៏ស្គាល់ទ្រង់ដែរ
៨ តែអ្នកណាដែលគ្មានសេចក្ដីស្រឡាញ់ នោះ
មិនស្គាល់ព្រះវិញ ពីព្រោះព្រះទ្រង់ជាសេចក្ដី
ស្រឡាញ់នោះឯង ៩ សេចក្ដីស្រឡាញ់របស់
ព្រះបានសំដែងមក ឲ្យយើងខ្ញុំស្គាល់ ដោយ
ទ្រង់ចាត់ព្រះរាជបុត្រាទ្រង់តែ១ ឲ្យមកក្នុង
លោកីយ៍ ដើម្បីឲ្យយើងរាល់គ្នាបានរស់
ដោយសារទ្រង់ ១០ នេះហើយជាសេចក្ដី
ស្រឡាញ់ មិនមែនជាយើងបានស្រឡាញ់ព្រះ
នោះទេ គឺទ្រង់បានស្រឡាញ់យើងវិញទេតើ
ហើយបានចាត់ព្រះរាជបុត្រាទ្រង់មក ទុកជាដ
ង្វាយឲ្យធួននឹងបាបយើងរាល់គ្នាផង ១១ ពួក
ស្ងួនភ្ងាអើយ បើព្រះបានស្រឡាញ់យើងរាល់
គ្នាជាខ្លាំងទាំងម្ល៉េះ នោះត្រូវឲ្យយើងស្រឡាញ់
គ្នាទៅវិញទៅមកដែរ ១២ គ្មានអ្នកណាដែល
ឃើញព្រះឡើយ តែបើយើងស្រឡាញ់គ្នាទៅ
វិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង
ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ បានពេញ
ខ្នាតក្នុងយើងដែរ ១៣ គឺយ៉ាងនោះឯងដែល
យើង ដឹងថា យើងនៅជាប់ក្នុងទ្រង់ ហើយ
ទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បាន
ប្រទានព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា
១៤ ហើយយើងបានឃើញ ក៏ធ្វើបន្ទាល់ថា ព្រះ
វរបិតាបានចាត់ព្រះរាជបុត្រាមក ធ្វើជាព្រះអង្គ
សង្គ្រោះនៃមនុស្សលោក។
១៥ អ្នកណា ដែលយល់ព្រមថា ព្រះយេស៊ូវ ជា
ព្រះរាជបុត្រានៃព្រះ អ្នកនោះឈ្មោះថា មាន
ព្រះគង់នៅក្នុងខ្លួនពិត ហើយខ្លួនក៏នៅក្នុងព្រះ
ដែរ ១៦ យើងរាល់គ្នាបាន ស្គាល់ ហើយក៏ជឿ
ចំពោះសេចក្ដីស្រឡាញ់ ដែលព្រះទ្រង់មាន
ដល់យើង ព្រះទ្រង់ជាតួសេចក្ដីស្រឡាញ់ ឯ
អ្នកណាដែលនៅជាប់ក្នុងសេចក្ដីស្រឡាញ់
នោះក៏បាននៅជាប់ក្នុងព្រះ ហើយព្រះទ្រង់គង់
នៅក្នុងអ្នកនោះដែរ។

## ការស្វែងយល់

ក្នុងខ.១០ យើងបានឃើញពាក្យ *ដង្វាយឲ្យធួននឹងបាប។* ពាក្យនេះ គឺជាពាក្យគន្លឹះនៅក្នុងទេវវិជ្ជា ដែលត្រូវបានប្រើ ដើម្បីពិពណ៌នាអំពីការអ្វីដែលព្រះគ្រីស្ទបានធ្វើនៅលើឈើឆ្កាង។ គឺមានន័យថា ទ្រង់បានធ្វើឲ្យព្រះលែងមានសេចក្ដីក្រោធ(ដ៏សុចរិត) ចំពោះអំពើបាបរបស់មនុស្ស។ ការនេះបានបង្ហាញឲ្យយើងដឹង ថាព្រះគ្រីស្ទទ្រង់ស្រឡាញ់យើង យ៉ាងជ្រាលជ្រៅប៉ុណ្ណា បានជាទ្រង់បានធ្វើឲ្យព្រះលែងមានសេចក្ដីក្រោធចំពោះអំពើបាបរបស់យើង ដើម្បីឲ្យយើងអាចពិសោធនឹងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យ ដ៏សម្បើមរបស់ព្រះវិញ។

សប្តាហ៍ទី២ ថ្ងៃពុធ

# អ្វីដែលអ្នកមិនស្គាល់

សូមអាន
២ធីម៉ូថេ ១:៨-១៤

ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម។ - ២ធីម៉ូថេ ១:១២

តើអ្នកដឹងថា *ក្បាលខ្សែស្បែកជើង* និង*ដងកាំបិត* ខុសគ្នាដូចម្តេចទេ? បើអ្នកបានដើរជាន់*កម្ទេចឈើពុកផុយ* តើអ្នកដឹងថា នោះជាកម្ទេចឈើពុកផុយឬទេ?

ដើម្បីឲ្យអ្នកមានជោគជ័យនៅក្នុងជីវិត អ្នកមិនចាំបាច់ស្គាល់ពាក្យទាំងអស់នេះក៏បាន។ បើអ្នកមិនដឹងថា *ក្បាលខ្សែស្បែកជើង* គឺជា "ស្រោមដែលរុំចុងខ្សែស្បែកជើង" ឬមិនបានដឹងថា*ដងកាំបិត* គឺជា "ផ្នែកដែលសម្រាប់កាន់នៃកាំបិត" ឬក៏មិនដឹងថា *ឈើពុកផុយ* គឺជា "សារជាតុពុកផុយ ដែលឃើញមាននៅលើដីក្នុងព្រៃ" នោះក៏មិនអីដែរ ព្រោះអ្នកអាចស្វែងយល់អំពីពាក្យទាំងអស់នេះ នៅពេលណាក៏បាន។

វាជាការគួរឲ្យរីករាយ ដែលយើងមិនចាំបាច់ត្រូវដឹងអំពីអ្វីៗគ្រប់យ៉ាង ដើម្បីឲ្យអាចរស់នៅក្នុងលោកិយនេះបាន។ ជាញឹកញាប់ យើងអាចពឹងផ្អែកទៅលើចំណេះដឹងរបស់អ្នកដទៃក៏បាន។ ឧទាហរណ៍ ខ្ញុំមិនចេះជួសជុលហ្វ្រាំងឡានរបស់ខ្ញុំទេ តែខ្ញុំមិនមានបញ្ហាអ្វីទេ ដរាបណាមាននរណាម្នាក់ចេះជួសជុលនោះ។

ទោះជាយ៉ាងណាក៏ដោយ យើងម្នាក់ៗមានការទទួលខុសត្រូវ ចំពោះចំណេះដឹងមួយ បើសិនជាយើងចង់ចូលនគរស្ថានសួគ៌។ ដែលខ្ញុំនិយាយនេះ គឺចង់សំដៅទៅលើការស្គាល់ព្រះគ្រីស្ទ ដោយផ្ទាល់ខ្លួនម្នាក់ៗ។ ការស្វែងយល់អំពីទ្រង់ និងការមានទំនាក់ទំនងផ្ទាល់ខ្លួន ជាមួយទ្រង់ គឺជាវិធីតែមួយ សម្រាប់ឲ្យយើងរស់នៅដោយប្រាជ្ញា និងត្រៀមខ្លួនជួបទ្រង់។ សាវ័កប៉ុលបានដឹងអំពី សេចក្តីនេះ ពេលដែលគាត់មានប្រសាសន៍ថា "ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម"(២ធីម៉ូថេ ២:១២)។

តើអ្នកស្គាល់ព្រះមួយអង្គដែលបានសុគតជួសអ្នក ហើយអាចអត់ទោសបាបឲ្យអ្នកឬទេ? បើអ្នកមិនបានស្គាល់ទ្រង់ទេ នោះការយល់ដឹងដទៃទៀតរបស់អ្នក គឺសុទ្ធតែគ្មានប្រយោជន៍ទាំងអស់។ - Dave Branon

*ជីវិតអស់កល្បជានិច្ច គឺជាការស្គាល់ព្រះ*
*តាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រាតែមួយរបស់ទ្រង់*
*ការស្គាល់ទ្រង់ គឺជាការសំខាន់បំផុត ដែលយើងរកឲ្យបានក្នុងមួយជីវិត*
*បើមិនបានស្គាល់ទ្រង់ទេ នោះជីវិតមិនអាចចាប់ផ្តើមឡើយ។ - D. De Haan*

**ការស្គាល់ព្រះគ្រីស្ទ គឺជាចំណេះដឹងដ៏អស្ចារ្យបំផុត។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ២ធីម៉ូថេ ១:៨-១៤

៨ដូច្នេះ មិនត្រូវឲ្យអ្នកមានសេចក្ដីខ្មាស ចំពោះ
ការធ្វើបន្ទាល់ពីព្រះអម្ចាស់នៃយើង ឬដោយ
ព្រោះខ្ញុំ ជាសិស្សរបស់ទ្រង់ដែលជាប់គុកនោះ
ឡើយ ចូរទ្រាំទុក្ខលំបាកជាមួយនឹងខ្ញុំ ក្នុង
ដំណឹងល្អ តាមព្រះចេស្ដានៃព្រះចុះ ៩ ដែល
ទ្រង់បានជួយ សង្គ្រោះយើង ហើយបានហៅ
យើងមកក្នុងការងារបរិសុទ្ធ មិនមែនដោយការ
ដែលយើងធ្វើទេ គឺដោយដំរិះ និងព្រះគុណនៃ
ទ្រង់វិញ ដែលបានផ្ដល់មកយើងក្នុងព្រះគ្រីស្ទ
យេស៊ូវ មុនអស់ទាំងកល្ប ១០ តែឥឡូវនេះ
ទើបនឹងសំដែងមក ដោយដំណើរព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ទ្រង់លេច
មក ដែលទ្រង់បានបំផ្លាញសេចក្ដីស្លាប់ ហើយ
បានយកជីវិត និងសេចក្ដីមិនចេះស្លាប់ មក
ដាក់នៅពន្លឺ ដោយសារដំណឹងល្អវិញ
១១ ហើយទ្រង់បានតាំងខ្ញុំ ឲ្យធ្វើជាអ្នកប្រកាស
ប្រាប់ដំណឹងល្អនោះ និងជាសាវ័ក ហើយជាគ្រូ
បង្រៀនដល់សាសន៍ដទៃ ១២ គឺដោយហេតុ
នោះ បានជាខ្ញុំរងទុក្ខទាំងនេះ តែខ្ញុំមិនខ្មាស
ទេ ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម
ហើយខ្ញុំជឿពិតថា ទ្រង់អាចនឹងថែរក្សាបញ្ញើ
ដែលខ្ញុំបានផ្ញើទុកនឹងទ្រង់ ដរាបដល់ថ្ងៃនោះ
ឯង ១៣ ចូរនឹកចាំពីអស់ ទាំងពាក្យត្រឹមត្រូវ
ដែលអ្នកបានឮពីខ្ញុំ ទុកជាគំរូពីសេចក្ដីជំនឿ
និងសេចក្ដីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទ
យេស៊ូវ ១៤ ចូររក្សាបញ្ញើល្អដែលផ្ញើទុកនឹងអ្នក
ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិត
នៅក្នុងយើង។

### ការស្វែងយល់

សាវ័កប៉ុលបានសរសេរនូវពាក្យដ៏មានអំណាចខាងលើនេះ ក្នុងដែលគាត់កំពុងជាប់នៅក្នុងមន្ទីឃុំឃាំង ដោយសារគាត់បានផ្សាយដំណឹងល្អអំពីព្រះគ្រីស្ទ។ ទោះជាយ៉ាងណាក៏ដោយ សូមកត់ចំណាំថា ការនេះមិនបាននាំឲ្យគាត់មានភាពល្វីងជូរចត់នៅក្នុងចិត្តទេ តែគាត់មានការយកចិត្តទុកដាក់។ គាត់ចង់ឲ្យសិស្សវ័យក្មេងរបស់គាត់ម្នាក់ គឺលោកធីម៉ូថេ នៅតែមានចិត្តស្មោះត្រង់ ពិតត្រង់ចំពោះដំណឹងល្អ និងមានការប្ដេជ្ញាចិត្តចំពោះព្រះអម្ចាស់។ គាត់ពិតជាមានការទុកចិត្តលើព្រះមែន បានជាគាត់នៅតែយកចិត្តទុកដាក់ចំពោះអ្នកដទៃ គឺមិនបានខ្វល់អំពីខ្លួនឯងទេ ទោះបីជាគាត់កំពុងប្រឈមមុខនឹងសេចក្ដីស្លាប់ក៏ដោយ។

សប្តាហ៍ទី២ ថ្ងៃព្រហស្បតិ៍

# ពេលកំណត់ចុងក្រោយ

សូមអាន
លូកា ១២:១៦-២១

ចូររៀបចំ ដើម្បីជួបនឹងព្រះនៃខ្លួនចុះ។ - អេម៉ុស ៤:១២

យើងគ្រប់គ្នាសុទ្ធតែប្រឈមមុខនឹងថ្ងៃកំណត់! យើងត្រូវដល់ពេលបង់ថ្លៃទឹកថ្លៃភ្លើង ត្រូវធ្វើបណ្ណអនុញ្ញាតឡើងវិញ ត្រូវបង់ពន្ធនេះពន្ធនោះ ហើយមានការជាច្រើនរាប់មិនអស់ទៀត ដែលយើងត្រូវធ្វើ នៅមុខថ្ងៃកំណត់ណាមួយ។

ទោះជាយ៉ាងណាក៏ដោយ មានថ្ងៃកំណត់មួយ ដែលសំខាន់បំផុត ដែលយើងរាល់គ្នានឹងជួប។ ព្រះគម្ពីរបានចែងថា "ដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជំរះ"(ហេព្រើ ៩:២៧)។

មនុស្សគ្រប់គ្នានឹងត្រូវស្លាប់ គឺលើកលែងតែគ្រីស្ទបរិស័ទ ដែលកំពុងរស់នៅក្នុងពេលដែលព្រះទ្រង់យាងមកវិញប៉ុណ្ណោះ(១ថែស្សាឡូនិច ៤:១៦-១៧)។ ហើយមនុស្សទាំងអស់ ដែលបានចាប់កំណើតក្នុងលោកិយនេះ ចាប់តាំងពីសម័យដំបូងមក នឹងត្រូវឈរនៅចំពោះព្រះ ដើម្បីទទួលការជំនុំជម្រះ។ ការធ្វើព្រងើយកន្តើយ ដោយមិនបានត្រៀមខ្លួនសម្រាប់ថ្ងៃកំណត់ដែលនឹងមកដល់ គឺជាទង្វើដែលល្ងង់ណាស់ !

ក្នុងព្រះគម្ពីរលូកា ជំពូក ១២ ព្រះយេស៊ូវបានមានបន្ទូលជាពាក្យប្រៀបប្រដូច អំពីបុរសអ្នកមានម្នាក់ ដែលមានគម្រោងសង់ជង្រុករបស់ខ្លួន ឲ្យបានធំជាងមុន ហើយប្រមូលទ្រព្យសម្បត្តិខាងលោកិយរបស់ខ្លួនទាំងអស់ដាក់ក្នុងនោះ សម្រាប់ឲ្យខ្លួនអាចអរសប្បាយ និងឈប់សម្រាក។ តែព្រះបានមានបន្ទូលថា "ឱមនុស្សល្ងីល្ងើអើយ នៅវេលាយប់នេះឯង អញនឹងដកយកព្រលឹងឯងទៅវិញ ដូច្នេះ តើទ្រព្យសម្បត្តិទាំងប៉ុន្មានដែលឯងបានប្រមូលទុកនេះ នឹងទៅជារបស់អ្នកណាវិញ"(លូកា ១២:២០)។ ថ្ងៃកំណត់នៃជីវិតរបស់អ្នកនោះត្រូវមកដល់។

តើអ្នកបានត្រៀមខ្លួនជួបព្រះហើយឬនៅ? បើអ្នកមិនទាន់បានទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះទេ នោះចូរទទួលទ្រង់ចុះ កុំរង់ចាំដល់ពេលក្រោយឡើយ ! ចូរជឿថា ទ្រង់បានខ្ចាយព្រះលោហិតទ្រង់ នៅលើឈើឆ្កាង ដើម្បីអត់ទោសបាបឲ្យអ្នក ហើយទ្រង់បានឈ្នះអំពើបាប ដោយមានព្រះជន្មរស់ឡើង វិញ។ ចូរទូលសូមឲ្យទ្រង់សង្គ្រោះអ្នក។ បន្ទាប់មក ពេលថ្ងៃកំណត់របស់ទ្រង់មកដល់ អ្នកអាចជួបទ្រង់ដោយគ្មានការភិតភ័យអ្វីឡើយ។ - Richard De Haan

*ជីវិតគឺមិនទៀងទាត់*
*តែសេចក្តីស្លាប់គឺទៀតទាត់ណាស់*
*អំពើបាបគឺជាដើមហេតុ*
*តែព្រះគ្រីស្ទទ្រង់ជាដំណោះស្រាយ។ - Anon*

---

**ចូរកុំរង់ចាំប្រែចិត្ត នៅម៉ោង១១ឡើយ ព្រោះអ្នកអាចស្លាប់នៅម៉ោង ១០:៣០!**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ លូកា ១២:១៦-២១

១៦ ទ្រង់ក៏មានព្រះបន្ទូលជាពាក្យប្រៀបធៀប
ទៅគេថា មានស្រែចំការរបស់អ្នកមានម្នាក់
បានកើតផលចំរើនជាបរិបូរ ១៧ ហើយអ្នកនោះ
រិះគិតក្នុងចិត្តថា តើត្រូវឲ្យអញធ្វើដូចម្តេច ដ្បិត
អញគ្មានកន្លែងណានឹងដាក់ផលរបស់អញ
ទាំងនេះទេ ១៨ ទើបយល់ថា អញត្រូវធ្វើយ៉ាង
នេះ គឺអញនឹងរុះជង្រុកអញ ពង្រីកឲ្យធំជាង
ទៅទៀត រួចប្រមូលផល នឹងទ្រព្យសម្បត្តិទៅ
ផ្ទុកនៅទីនោះ ១៩ នោះអញនឹងប្រាប់ដល់ ចិត្ត
ថា ចិត្តអើយ ឯងមានទ្រព្យសម្បត្តិជាច្រើន
ល្មមទុកសំរាប់ជាយូរឆ្នាំទៅមុខទៀតបាន
ហើយ ចូរឯងឈប់សំរាកទៅ ហើយស៊ីផឹក
សប្បាយចុះ ២០ ប៉ុន្តែព្រះទ្រង់មាន ព្រះបន្ទូល
ទៅអ្នកនោះថា ឱមនុស្សល្ងីល្ងើអើយ នៅវេលា
យប់នេះឯង អញនឹងដកយកព្រលឹងឯងទៅ
វិញ ដូច្នេះ តើទ្រព្យសម្បត្តិទាំងប៉ុន្មានដែលឯង
បានប្រមូលទុកនេះ នឹងទៅជារបស់អ្នកណា
វិញ ២១ អ្នកណាដែលប្រមូលទ្រព្យសម្បត្តិ ទុក
បំរុងតែខ្លួនឯង តែឥតមានខាងឯព្រះសោះ
នោះក៏ដូច្នោះដែរ។

## ការស្វែងយល់

ពេលដែលព្រះយេស៊ូវបង្រៀន ជាញឹកញាប់ ទ្រង់បានប្រើពាក្យប្រៀបប្រដូច(ដូចនៅក្នុងលូកា ១២ជាដើម)។ មានពាក្យមួយពោលថា រឿងប្រៀបប្រដូច គឺជារឿងអំពីលោកិយ តែមានអត្ថន័យបែបនគរស្ថានសួគ៌។ នៅក្នុងការមានបន្ទូលជារឿងប្រៀបប្រដូចនេះ ព្រះយេស៊ូវបានដកស្រង់ចេញពីបរិយាកាសសង្គម ដែលអ្នកស្តាប់របស់ទ្រង់ងាយយល់ ដោយសាររឿងនោះនិយាយទាក់ទងនឹងជីវិត ដែលរស់នៅក្នុងសម័យបុរាណ ដែលមនុស្សនិយមធ្វើកសិកម្ម។ រឿងប្រៀបប្រដូចទាំងនេះ នៅតែមានសារៈសំខាន់រហូតមកដល់សព្វថ្ងៃនេះ ទោះបីជាបច្ចុប្បន្ន ពិភពលោកយើងមានបច្ចេកវិទ្យាទំនើបយ៉ាងណាក៏ដោយ ព្រោះគោលការណ៍ដែលមាននៅក្នុងរឿងទាំងនេះ អាចយកមកអនុវត្ត នៅក្នុងគ្រប់សម័យកាលទាំងអស់។

សប្តាហ៍ទី២ ថ្ងៃសុក្រ

# អង់តែនដែលត្រូវមាន

សូមអាន
១យ៉ូហាន ១:១-៤

ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទីបន្ទាល់ ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច ...។
-១យ៉ូហាន ១:២

តើអ្នកនឹងឆ្លើយយ៉ាងដូចម្តេច ចំពោះសំណួរថា "តើអ្វីជាអត្ថន័យនៃជីវិត?" លោកយ៉ូណាថាន ហ្គាបេយ (Jona-than Gabay) ជាជនជាតិអង់គ្លេសម្នាក់ ដែលបានបោះពុម្ពសៀវភៅមួយ ដែលផ្ទុកទៅដោយចម្លើយរបស់ជនល្បីៗជាច្រើន ចំពោះសំណួរមួយនេះ។ ក្នុងចំណោមអ្នកទាំងនោះ មានអ្នកដឹកនាំពួកជំនុំម្នាក់ បានផ្តល់ឲ្យនូវទីបន្ទាល់មួយ ដែលលើកទឹកចិត្ត។ គាត់បានមានប្រសាសន៍ថា កាលពីក្មេង គាត់បានមើលទូរទស្សន៍សខ្មៅរបស់ក្រុមគ្រួសារគាត់ ដោយប្រាថ្នាសូមឲ្យទូរទស្សន៍នោះមានរូបភាពច្បាស់ល្អជាងនោះ។ ទោះជាយ៉ាងណាក៏ដោយ គាត់ក៏បានអសប្បាយ នៅពេលបានដឹងថា គេមានទូរទស្សន៍ដែលច្បាស់ជាងនោះ។

បន្ទាប់មក ក្រុមគ្រួសាររបស់គាត់ក៏បានរកឃើញថា ពួកគេត្រូវការដាក់អង់តែនមួយ នៅខាងក្រៅផ្ទះទើបបាន។ គាត់ក៏បាននិយាយថា "ភ្លាមៗនោះ យើងក៏ឃើញថា យើងទទួលបាននូវរូបភាពច្បាស់។ យើងក៏មានចិត្តសប្បាយរីករាយឡើង"។ បន្ទាប់មក តាមរយៈបទពិសោធនេះ គាត់ក៏បានធ្វើការប្រៀបធៀបថា "ជីវិតដែលគ្មានទំនាក់ទំនងជាមួយព្រះ តាមរយៈព្រះគ្រីស្ទ គឺដូចជាទូរទស្សន៍ដែលគ្មានអង់តែន"។

បើសិនជាយើងមិនបានស្គាល់ព្រះ និងបំណងព្រះទ័យទ្រង់ ដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ នៅក្នុងព្រះគ្រីស្ទទេ នោះមនុស្សយើងគ្រាន់តែអាចទទួលបាននូវរូបភាពព្រាលៗ របស់ព្រះអទិករដ៏បរិសុទ្ធ ដែលយើងមិនអាចមើលឃើញនឹងភ្នែកបាន។ តែពេលដែលយើងចាប់កាន់ព្រះគម្ពីរ ហើយចំណាយពេលជាមួយព្រះយេស៊ូវគ្រីស្ទ ដែលជាមនុស្ស ដែលជាព្រះដែលបានយកកំណើតជាសាច់ឈាម នោះភាពព្រាលៗនោះ ក៏រលាយបាត់អស់។ គឺដូចដែលព្រះយេស៊ូវទ្រង់បានប្រកាសថា "អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ"(យ៉ូហាន ១៤:៩)។

តើអ្នកធ្លាប់ព្យាយាមស្វែងយល់អំពីអត្ថន័យនៃជីវិតឬទេ? អ្នកត្រូវមានអង់តែនរបស់ព្រះដើម្បីឲ្យអាចឃើញរូបភាពច្បាស់បាន។ - Vernon Grounds

*សូមពិចារណាឡើងវិញចុះ*
*បើគ្មានរឿងអំពីព្រះយេស៊ូវគ្រីស្ទ នៅក្នុង*
*ព្រះបន្ទូលព្រះទេ នោះយើងនឹងគ្មានអង់តែន*
*សម្រាប់ជួយឲ្យយើងយល់អំពីពិភពរបស់ព្រះបានឡើយ។*

**ដើម្បីមើលឃើញព្រះច្បាស់**
**នោះចូរមើលទៅឯព្រះយេស៊ូវគ្រីស្ទចុះ។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១យ៉ូហាន ១:១-៤

១ឯសេចក្ដីដែលមានតាំងពីដើមមក ដែលយើង
ខ្ញុំបានឮ ហើយភ្នែកបានឃើញ ក៏បានមើល
ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលនៃ
ជីវិត ២ (ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមក
ហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទី
បន្ទាល់ ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់
នៅអស់កល្បជានិច្ចដែលពីដើមស្ថិតនៅនឹង
ព្រះវរបិតា ហើយបានលេចមកឲ្យយើងខ្ញុំ
ឃើញ) ៣ ដូច្នេះ សេចក្ដីដែលយើងខ្ញុំបាន
ឃើញ ហើយឮនោះ យើងខ្ញុំប្រាប់មកអ្នករាល់
គ្នា ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្ដីប្រកបនឹង
យើងខ្ញុំដែរ រីឯសេចក្ដីប្រកបរបស់យើងខ្ញុំ នោះ
គឺប្រកបនឹងព្រះវរបិតា ហើយនិងព្រះយេស៊ូវ
គ្រីស្ទ ជាព្រះរាជបុត្រាទ្រង់ ៤ យើងខ្ញុំក៏សរសេរ
សេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដើម្បីឲ្យ
សេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញ
ឡើង។

### ការស្វែងយល់

ពេលដែលលោកយ៉ូហានចាប់ផ្ដើមសរសេរសំបុត្រដ៏ខ្លីមួយនេះ គាត់បានពន្យល់អ្នកអានរបស់គាត់ អំពីគោលបំណងដែលគាត់សរសេរសំបុត្រនេះ។ តើគាត់មានគោលដៅអ្វី? គាត់ចង់ឲ្យពួកគេបានស្គាល់ ភាពពោរពេញនៃក្ដីអំណរ ដែលគេអាចទទួលបានតាមរយៈទំនាក់ទំនងជាមួយព្រះប៉ុណ្ណោះ។ គេចាំបាច់ត្រូវយល់ថា *សេចក្ដីអំណរ* គឺខុសពី *ការសប្បាយ។* ភាគច្រើន ការសប្បាយគឺផ្អែកទៅលើអារម្មណ៍ ហើយអាស្រ័យទៅលើស្ថានភាពនៃជីវិតយើង។ ទោះជាយ៉ាងណាក៏ដោយ សេចក្ដីអំណរគឺជាការពេញចិត្តដ៏ជ្រាលជ្រៅ ដែលកើតមាន ពេលដែលយើងបានធ្វើត្រូវនឹងព្រះទ័យព្រះ។ សេចក្ដីអំណររបស់យើងមានភាពពេញលេញ តែនៅពេលនោះឯង។

ថ្ងៃសៅរ៍ពិសេស ឬទំព័រពិសេសនៅថ្ងៃអាទិត្យ

# មូលហេតុទាំង១០យ៉ាង ដែលត្រូវជឿលើព្រះគម្ពីរ

## ១. ភាពស្មោះត្រង់នៃព្រះគម្ពីរ

ព្រះគម្ពីរមានភាពស្មោះត្រង់យ៉ាងខ្លាំង។ ព្រះគម្ពីរបានបង្ហាញថា លោកយ៉ាកុប ដែលជាពួយុ-កោនៃរាស្ត្រជ្រើសតាំង គឺជាមនុស្សបោកប្រាស់។ ព្រះគម្ពីរក៏បានបង្ហាញថា ស្តេចដាវីឌ ដែលជាស្តេចជាទីស្រឡាញ់បំផុត និងជាអ្នកដឹកនាំរបស់រាស្ត្រអ៊ីស្រាអែល ជាមនុស្សកំផិត ជាជនផ្សំគំនិតធ្វើការអាក្រក់ និងជាឃាតករ។ ព្រះគម្ពីរបានបញ្ជាក់ឲ្យយើងដឹងថា មនុស្សជាតិមានលក្ខណៈដែលទាស់ប្រឆាំងនឹងព្រះ។ ព្រះគម្ពីរបានថ្លែងទំនាយអំពីពេលអនាគត ដែលនឹងមានការអាក្រក់ជាច្រើនកើតឡើង។ ព្រះគម្ពីរបង្រៀនថា ផ្លូវទៅនគរស្ថានសួគ៌គឺតូចចង្អៀត រីឯផ្លូវទៅស្ថាននរកវិញ គឺធំទូលាយ។ ព្រះគម្ពីរមិនត្រូវបាននិពន្ធមក សម្រាប់អ្នកដែលគ្រាន់តែចង់បានចម្លើយសាមញ្ញៗ ឬចង់បានសាសនាដែលងាយអនុវត្តតាមនោះឡើយ។

## ២. ការអភិរក្សនៃព្រះគម្ពីរ

គេបានរកឃើញក្រាំងដែលមានចំណាស់ពីរពាន់ឆ្នាំ ក្នុងរូងភ្នំនៅក្បែសមុទ្រស្លាប់។ ក្រាំងទាំងនោះ ត្រូវបានគេចម្លងចេញ ពីក្រាំងដើម ដែលហោរាអេសាយបាននិពន្ធ ហើយក្រាំងទាំងនោះ មាន សំណេរដូចព្រះគម្ពីរអេសាយ ដែលមានក្នុងព្រះគម្ពីរដែលយើងប្រើសព្វថ្ងៃ។ ព្រះទ្រង់បានអភិរក្សព្រះបន្ទូលទ្រង់ ឲ្យនៅតែគ្មានកំហុស។

## ៣. ព្រះគម្ពីរមានការអះអាងអំពីខ្លួនឯង

បើអ្នកនិពន្ធព្រះគម្ពីរមិនបានអះអាងថា ព្រះជាអ្នកបណ្តាលឲ្យពួកគេសរសេរព្រះគម្ពីរទេ នោះយើងមិនអាចអះអាងថា ព្រះជាអ្នកបណ្តាលឲ្យពួកគេតែងព្រះគម្ពីរបានឡើយ ហើយព្រះគម្ពីរគឺគ្រាន់តែជាការប្រមូលផ្តុំនៃអាថ៌កំបាំងដែលគ្មានការបកស្រាយ នៅក្នុងស្នាដៃអក្សរសាស្ត្របែបប្រវត្តិសាស្ត្រ និងសីលធម៌។ ប៉ុន្តែ អ្នកនិពន្ធព្រះគម្ពីរ ពិតជាបានអះអាងថា ព្រះបានបណ្តាលឲ្យពួកគេនិពន្ធមែន។ ដោយសារមនុស្សរាប់លាននាក់ បានរស់នៅក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគតដ៏អស់កល្បជានិច្ច ដោយផ្អែកទៅលើការអះអាងនេះឯង ព្រះគម្ពីរមិនអាចជាសៀវភៅដ៏ល្អមួយក្បាលបានឡើយ បើអ្នកនិពន្ធនៃព្រះគម្ពីរបាននិយាយកុហក់អំពីប្រភព នៃពត៌មានដែលមាននៅក្នុងព្រះគម្ពីរនោះ។

## ៤. ការអស្ចារ្យនៃព្រះគម្ពីរ

បើសមុទ្រក្រហមមិនបានញែក ដូចដែលលោកម៉ូសេបានប្រាប់នៅក្នុងព្រះគម្ពីរទេ នោះព្រះគម្ពីរសញ្ញាចាស់ មិនមានអំណាចអ្វី ក្នុងការអះអាងថា ព្រះបានបណ្ដាលឲ្យតែងព្រះគម្ពីរឡើយ។ បើព្រះកាយរបស់ព្រះយេស៊ូវមិនបានមានព្រះជន្មរស់ឡើងវិញទេ នោះសាវ័កប៉ុលមុខជាបានទទួលស្គាល់ថា សេចក្ដីជំនឿរបស់គ្រីស្ទបរិស័ទគឺបានផ្អែកទៅលើការកុហក់ហើយ(១កូរិនថូស ១៥:១៤- ១៧)។ ព្រះគម្ពីរបានប្រាប់ឈ្មោះសាក្សីដែលបានឃើញព្រះគ្រីស្ទ បន្ទាប់ពីទ្រង់បានមានព្រះជន្មឡើងវិញ ហើយបានប្រាប់ឈ្មោះអ្នកទាំងនោះ នៅក្នុងអំឡុងពេលមួយដែលអាចឲ្យគេមានឱកាសធ្វើការស៊ើបអង្កេត អំពីការមានព្រះជន្មរស់ឡើងវិញនោះ(១កូរិនថូស ១៥:១-៨)។ មានសាក្សីជាច្រើនត្រូវបានគេបៀតបៀន ដោយសារពួកគេបានអះអាងថាព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ។ មានពួកគេជាច្រើននាក់ ត្រូវបានគេសម្លាប់ដោយសារសេចក្ដីអ្វី ដែលពួកគេជឿថាជាសេចក្ដីពិត។ ប៉ុន្តែ តាមធម្មតា មនុស្សយើងមិនសុខចិត្តស្លាប់ ដោយសារសេចក្ដីអ្វី ដែលខ្លួនបានដឹងថាជាការកុហក់ឡើយ។ ការមានព្រះជន្មរស់ឡើងវិញ គឺជាភស្តុតាងដ៏មានអំណាច ដែលបញ្ជាក់ថា ព្រះគម្ពីរជាសេចក្ដីពិត។

## ៥. ការរួបរួមនៃព្រះគម្ពីរ

មានអ្នកនិពន្ធចំនួន៤០នាក់ ដែលបាននិពន្ធកណ្ឌទាំង៦៦ នៃព្រះគម្ពីរ ក្នុងអំឡុងពេល ១៦០០ឆ្នាំ។ តែកណ្ឌទាំង៣៩នៃព្រះគម្ពីរសញ្ញាចាស់ និងកណ្ឌទាំង២៧នៃព្រះគម្ពីរសញ្ញាថ្មីសុទ្ធតែបានចែងអំពីរឿងមួយ ដែលជាការបើកសម្ដែងនៃផែនការប្រោសលោះរបស់ព្រះ ។ កណ្ឌទាំងអស់នេះផ្ដល់ឲ្យនូវចម្លើយដ៏សំខាន់ៗបំផុត ចំពោះសំណួររបស់យើង ដែលមានដូចជា ៖ ហេតុអ្វីបានជាយើងមានវត្តមាននៅក្នុងលោកិយនេះ ? តើយើងអាចស្គាល់ព្រះដោយរបៀបណា? តើយើងត្រូវធ្វើដូចម្ដេច ដើម្បីផ្សះផ្សាឲ្យជានឹងព្រះដែលបានបង្កើតយើងមក?

## ៦. ភាពត្រឹមត្រូវផ្នែកប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនៃព្រះគម្ពីរ

មានមនុស្សជាច្រើនបានសង្ស័យអំពីភាពត្រឹមត្រូវផ្នែកប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនៃព្រះគម្ពីរ។ តែបុរាណវត្ថុវិទូនៅសម័យទំនើបបានធ្វើកំណាយរកឃើញភស្តុតាងជាច្រើន ដែលបញ្ជាក់អំពីមនុស្ស ទីកន្លែង និងវប្បធម៌ ដែលត្រូវបានរៀបរាប់នៅក្នុងព្រះគម្ពីរ។ មានពេលជាច្រើនដងហើយ ដែលគេបានរកឃើញថា ការពិពណ៌នានៅក្នុងការកត់ត្រានៃព្រះគម្ពីរ មានភាពគួរឲ្យទុកចិត្ត លើសពីការរំពឹងទុកនៃអ្នកប្រាជ្ញទាំងនោះទៅទៀត។

## ៧. ការបញ្ជាក់របស់ព្រះគ្រីស្ទ

ព្រះគ្រីស្ទមិនគ្រាន់តែបានធ្វើការបញ្ជាក់អំពីព្រះគម្ពីរ ដោយព្រះបន្ទូលទ្រង់ប៉ុណ្ណោះឡើយ តែថែមទាំងបញ្ជាក់ដោយព្រះជន្មរបស់ទ្រង់ផងដែរ។ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់ជឿ

លើព្រះគម្ពីរសញ្ញាចាស់(ម៉ាថាយ ៤:១-១១ ៥:១៧-១៩)។ ទ្រង់ជឿថា ព្រះគម្ពីរគឺជាសៀវភៅមួយក្បាល ដែលចែងអំពីព្រះអង្គទ្រង់។ ទ្រង់មានបន្ទូលថា "អ្នករាល់គ្នាស្ទង់មើលគម្ពីរ ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ តែអ្នករាល់គ្នាមិនសុខចិត្តមកឯខ្ញុំ ឲ្យបានជីវិតទេ(យ៉ូហាន ៥:៣៩-៤០)។"

### ៨. ភាពត្រឹមត្រូវនៃបទទំនាយក្នុងព្រះគម្ពីរ

ចាប់តាំងពីសម័យលោកម៉ូសេរៀងមក ព្រះគម្ពីរបានថ្លែងទំនាយអំពីហេតុការណ៍ ដែលគ្មាននរណាម្នាក់ចង់ជឿឡើយ។ មុនពេលសាសន៍អ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យា លោកម៉ូសេបានថ្លែងទំនាយថា ពួកអ៊ីស្រាអែលនឹងមិនមានភាពស្មោះត្រង់ ដែលជាហេតុបណ្ដាលឲ្យជាតិសាសន៍នេះត្រូវបាត់បង់ទឹកដីដែលព្រះប្រទានពួកគេ ហើយត្រូវទៅរស់នៅរប៉ាត់រប៉ាយ នៅទូទាំងពិភពលោក។ ពួកគេក៏បានប្រមូលផ្ដុំគ្នាឡើងវិញ ហើយក៏ត្រូវបានស្អាងឡើងវិញ(ចោទិយកថា ២៨-៣១)។ ហេតុការណ៍ទាំងនោះក៏បានកើតឡើង ដូចបទទំនាញមែន។ ចំណុចសំខាន់បំផុតនៃបទទំនាយក្នុងព្រះគម្ពីរសញ្ញាចាស់ គឺសេចក្ដីសន្យាថា ព្រះម៉ែស៊ីទ្រង់នឹងយាងមកសង្គ្រោះរាស្ត្ររបស់ទ្រង់ ឲ្យរួចពីបាប ហើយនៅទីបញ្ចប់ទ្រង់នឹងជំនុំជម្រះលោកិយ ហើយនាំមកនូវសេចក្ដីសុខសាន្តជារៀងរហូត។

### ៩. ភាពគង់វង្សនៃព្រះគម្ពីរ

ព្រះគម្ពីរមានវត្តមានអស់រយៈពេល២ពាន់ឆ្នាំហើយ។ ក្នុងអំឡុងពេលនៃប្រវត្តិសាស្ត្រដ៏វែងនេះ គ្មានសៀវភៅណា ដែលត្រូវបានគេស្រឡាញ់ និងស្អប់ខ្លាំង ដូចព្រះគម្ពីរទេ។ គ្មានសៀវភៅណា ដែលត្រូវបានគេទិញប្រើ សិក្សា និងដកស្រង់បានញឹកញាប់ ដូចព្រះគម្ពីរឡើយ។ ព្រះគម្ពីរគឺជាសៀវភៅ ដែលគេបានប្រើសម្រាប់វាស់ស្ទង់សៀវភៅដទៃទៀត។

### ១០. អំណាចនៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ

ប្រវត្តិសាស្ត្រត្រូវបានគូសចំណាំ ដោយអ្នកដែលបានជឿលើព្រះគម្ពីរ និងមានជីវិតផ្លាស់ប្រែ ឲ្យល្អប្រសើរជាងមុន ដោយសារព្រះគម្ពីរ។ ក្រឹត្យវិន័យទាំង១០ប្រការ គឺជាប្រភពនៃទិសដៅផ្នែកសីលធម៌សម្រាប់មនុស្សជាច្រើនរាប់មិនអស់។ បទទំនុកតម្កើងរបស់ស្ដេចដាវីឌបានកម្សាន្តចិត្តមនុស្សជាច្រើន នៅក្នុងពេលមានបញ្ហា និងជួបការបាត់បង់។ សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវនៅលើទីទួល បានផ្ដល់ឲ្យនូវខ្នាតគំរូសម្រាប់ការរស់នៅដ៏ត្រឹមត្រូវ ដល់មនុស្សរាប់លាននាក់។ ការពិពណ៌នារបស់សាវ័ក ប៉ុល ក្នុង១កូរិនថូស ជំពូក១៣ បានបន្ទន់ចិត្តមនុស្សជាច្រើននាក់ ដែលមានកំហឹង។

### មិនមែនមានតែអ្នកទេដែលមានបញ្ហានេះ

អ្នកមិននៅឯកកោទេ បើសិនជាអ្នកមានសំណួរ អំពីភាពអាចទុកចិត្តបាននៃព្រះគម្ពីរ

នោះ។ ព្រះគម្ពីរមានទៅដោយសេចក្ដីអាថ៌កំបាំងជាច្រើន តែលោកិយដែលនៅជុំវិញខ្លួនយើងទេ ក៏មានសេចក្ដីអាថ៌កំបាំងច្រើនណាស់ដែរ។ បើសិនជាការអះអាងរបស់ព្រះគម្ពីរ គឺជាការពិតមែន នោះអ្នកមិនចាំបាច់ត្រូវព្យាយាមស្វែងរកភស្តុតាងដោយខ្លួនឯងឡើយ។ ព្រះដែលជាអ្នកនិពន្ធនៃព្រះគម្ពីរនឹងជួយឲ្យអ្នកទទួលបាននូវចម្លើយជាទីគាប់ចិត្ត ចំពោះសំណួររបស់អ្នក។

គន្លឹះដ៏សំខាន់មួយដែលយើងត្រូវដឹង នៅក្នុងការស្វែងយល់អំពីព្រះគម្ពីរគឺ : ព្រះគម្ពីរមិនគ្រាន់តែត្រូវបាននិពន្ធមក សម្រាប់នាំយើងឲ្យចូលមករកព្រះគម្ពីរប៉ុណ្ណោះឡើយ។ គោលការណ៍នីមួយៗនៃព្រះគម្ពីរបានបង្ហាញឲ្យយើងដឹងថា យើងត្រូវការការអត់ទោសបាបដែលព្រះគ្រីស្ទបានប្រទាន តាមរយៈការសុគតជួសយើងរាល់គ្នា។ ព្រះគម្ពីរបង្ហាញឲ្យយើងដឹងអំពីមូលហេតុ ដែលយើងចាំបាច់ត្រូវអនុញ្ញាតឲ្យព្រះវិញ្ញាណនៃព្រះគង់នៅក្នុងយើងរាល់គ្នា។ ព្រះគម្ពីរត្រូវបាននិពន្ធមកសម្រាប់ឲ្យយើងមានទំនាក់ទំនង ដូចនេះឯង។

**សម្រាប់ការអានជាបន្ថែម: សូមអានសៀវភៅ**

តើខ្ញុំពិតជាអាចទុកចិត្តលើព្រះគម្ពីរឬ?

សប្តាហ៍ទី៣ ថ្ងៃច័ន្ទ

# ទឹកភ្នែកដែលជួយរំលែកទុក្ខ

សូមអាន
យ៉ូហាន ១១:១៤-៣៦

ចូរអរសប្បាយ ជាមួយនឹងអ្នកណា ដែលអរសប្បាយ ហើយយំជាមួយនឹងអ្នកណាដែលយំផង។ - រ៉ូម ១២:១៥

មានរឿងមួយបានដំណាលអំពីក្មេងប្រុសតូចម្នាក់ ដែលមានក្តីស្រឡាញ់ច្រើន។ អ្នកជិតខាងរបស់វាគឺជាបុរសដែលមានវ័យចំណាស់ម្នាក់ ដែលភរិយារបស់គាត់បានស្លាប់កាលពីពេលថ្មីៗនេះ។ ពេលដែលក្មេងតូចនេះបានឃើញបុរសវ័យចំណាស់រូបនេះកំពុងយំ វាបានឡើងទៅអង្គុយលើភ្លៅគាត់ គឺវាគ្រាន់តែអង្គុយប៉ុណ្ណោះ។

ក្រោយមក ម្តាយរបស់ក្មេងប្រុសនេះ ក៏បានសួរវាថា តើវាបាននិយាយអ្វីទៅកាន់អ្នកជិតខាងដែលកំពុងមានទុក្ខនេះ។ ក្មេងនេះក៏បានឆ្លើយថា "កូនមិនបាននិយាយអ្វីទេ កូនគ្រាន់តែជួយយំគាត់ប៉ុណ្ណោះ"។

ជួនកាល នោះជាការល្អបំផុតដែលយើងអាចធ្វើ សម្រាប់អ្នកដែលកំពុងមានទុក្ខព្រួយ។ ជាញឹកញាប់ ការដែលយើងព្យាយាមនិយាយពាក្យដ៏ឆ្លាតវ័យ ដើម្បីជួយដល់អ្នកដែលកំពុងកើតទុក្ខ មិនសូវមានតម្លៃ ដូចការអង្គុយនៅក្បែរគាត់ ដោយកាន់ដៃគាត់ ហើយយំជាមួយនឹងគាត់ប៉ុន្មានទេ។

ក្នុងចំណោមមធ្យោបាយជាច្រើន ដែលយើងអាចប្រើ ដើម្បីជួយដល់បងប្អូនរួមជំនឿរបស់យើង យើងអាច "យំជាមួយនឹងអ្នកណាដែលយំ"(រ៉ូម ១២:១៥)។ ព្រះយេស៊ូវបានបកស្រាយអំពីគោលការណ៍នេះ ពេលដែលទ្រង់បានយាងទៅសួរសុខទុក្ខនាងម៉ារា និងម៉ាថា បន្ទាប់ពីលោកឡាសាបានស្លាប់។ ដោយបានជ្រាបអំពីជម្រៅនៃសេចក្តីទុក្ខរបស់នាងម៉ារី ចំពោះការស្លាប់របស់ឡាសា ដែលជាប្អូនប្រុសរបស់នាង ទ្រង់ក៏បានរួមចំណែកនៅក្នុងទុក្ខសោករបស់ពួកគេ ដោយព្រះកន្សែង(យ៉ូហាន ១១:៣៥)។ អ្នកដែលបានឃើញហេតុការណ៍នេះ បានធ្វើការកត់សំគាល់ ហើយនិយាយថា "មើល លោកស្រឡាញ់គាត់ណាស់ហ្ន៎!"(យ៉ូហាន ១១:៣៦)

ជួនកាល "ការជួយយំ" គឺជាការប្រសើរបំផុតដែលយើងអាចធ្វើ សម្រាប់អ្នកដែលកំពុងធ្វើដំណើរតាមផ្លូវដែលមានទុក្ខព្រួយ និងឯកកោបំផុតនៅក្នុងជីវិត។ ព្រះយេស៊ូវបានបង្ហាញឲ្យយើងដឹងថា ការរួមចំណែកនៅក្នុងការសម្រក់ទឹកភ្នែកជាមួយនរណាម្នាក់ គឺជាការសំខាន់ណាស់។ នៅថ្ងៃនេះ តើមាននរណាម្នាក់ ត្រូវការទឹកភ្នែករបស់អ្នកទេ? – Dave Branon

*ការសម្រក់ទឹកភ្នែកអស់ពីចិត្ត បង្ហាញពីសេចក្តីស្រឡាញ់របស់យើង*
*នៅពេលដែលពាក្យសម្តីមិនអាចបង្ហាញសេចក្តីស្រឡាញ់បាន*
*ទឹកភ្នែកនោះនិយាយថា "ខ្ញុំចង់ចែករំលែងការឈឺចាប់របស់អ្នក*
*ចិត្តរបស់ខ្ញុំចង់ជួយអ្នក"។ - D. De Haan*

**ការរំលែកទុក្ខ កាត់សេចក្តីទុក្ខចេញពាក់កណ្តាល**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ យ៉ូហាន ១១:១៧-១៩,៣០-៣៦

១៧ កាលព្រះយេស៊ូវយាងទៅដល់ហើយ នោះ
បានឮថា ឡាសារនៅក្នុងផ្នូរអស់៤ថ្ងៃហើយ
១៨ រីឯភូមិបេថានី នោះនៅជិតក្រុងយេរូសា
ឡិម ប្រហែលជា៣គីឡូម៉ែត្រទេ ១៩ ហើយ
មានពួកសាសន៍យូដាជាច្រើនបានមកដើម្បី
ជួយកំសាន្តទុក្ខនាងម៉ាថា និងម៉ារា ពីដំណើរ
ប្អូនស្លាប់។

៣០ ឯព្រះយេស៊ូវ ទ្រង់មិនទាន់យាងចូលក្នុង
ភូមិនៅឡើយ គឺទ្រង់គង់នៅត្រង់កន្លែងដែល
ម៉ាថាបានជួបនោះ ៣១ កាលពួកសាសន៍យូដា
ដែលនៅក្នុងផ្ទះ កំពុងតែជួយកំសាន្តចិត្តនាង
ម៉ារា បានឃើញថា នាងក្រោកឡើងចេញទៅ
ជាប្រញាប់ដូច្នេះ គេក៏តាមនាងទៅ ដោយ
និយាយគ្នាថា នាងគិតទៅយំឯផ្នូរហើយ។
៣២ នាង ម៉ារាក៏ទៅដល់កន្លែង ដែលព្រះយេស៊ូ
វគង់នៅ កាលបានឃើញទ្រង់ នោះនាងក្រាប
នៅទៀបព្រះបាទទូលថា ព្រះអម្ចាស់អើយ បើ
ទ្រង់បានគង់នៅទីនេះ នោះប្អូនខ្ញុំម្ចាស់មិន
បានស្លាប់ទេ ៣៣ កាលព្រះយេស៊ូវឃើញនាង
យំ ព្រមទាំងពួកសាសន៍យូដា ដែលមកជា
មួយនឹងនាងផង នោះទ្រង់មានសេចក្តីរំជួល
ទាំងក្តាញ់ក្នុងព្រះហឫទ័យ ៣៤ ហើយមានព្រះ
បន្ទូលសួរថា អ្នករាល់គ្នាបានយករូបបុគ្គលទៅ
ទុកឯណា គេទូលឆ្លើយថា ព្រះអម្ចាស់ សូម
យាងទៅទតមើល ៣៥ ព្រះយេស៊ូវក៏ទ្រង់ព្រះ
កន្សែង ៣៦ ដូច្នេះ ពួកសាសន៍យូដានិយាយថា
មើល លោកស្រឡាញ់គាត់ណាស់ហ្ន៎

### ការស្វែងយល់

ខ.៣៣ បានពិពណ៌នាថា ព្រះយេស៊ូវមានសេចក្តីរំជួល ទាំងក្តុកក្តួលក្នុងព្រះហឫទ័យ ពេលទ្រង់ទតឃើញអ្នកទាំងនោះកំពុងទួញសោក។ យើងអាចសួរថា ហេតុអ្វីទ្រង់ព្រះកន្សែង នៅពេលដែលទ្រង់បានជ្រាបថា ក្នុងពេលដ៏ខ្លីខាងមុខ ទ្រង់នឹងប្រោសឡាសារឲ្យរស់ឡើងវិញ។ ទ្រង់ប្រហែលជាទួញសោក ចំពោះលទ្ធផលដ៏អាក្រក់ ដែលអំពើបាបបានបណ្តាលឡើង និងឥទ្ធិពលដែលសេចក្តីស្លាប់មាន មកលើជីវិតនៃមនុស្សគ្រប់គ្នា ដែលជៀសមិនរួចពីសេចក្តីស្លាប់។

សប្ដាហ៍ទី៣ ថ្ងៃអង្គារ

# ពេលថ្ងៃស្អែក ដែលមិនទាន់បានបើកមើលជាមុន

សូមអាន
ម៉ាថាយ ៦:២៥-៣៤

ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ ។
- ២កូរិនថូស ៥:៧

ជាញឹកញាប់ យើងប្រាថ្នាចង់ដឹងជាមុន អំពីការអ្វីដែលនឹងកើតឡើងក្នុងពេលឆាប់ៗខាងមុខ នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងអាចត្រៀមខ្លួន ប្រឈមមុខនឹងវា គ្រប់គ្រង ឬជៀសចេញពីវា។ មានអ្នកប្រាជ្ញម្នាក់បាននិយាយថា "យើងមិនដឹងថា មានអ្វីខ្លះដែលហៀបនឹងកើតឡើងទេ តែព្រះទ្រង់អាចដឹង"។ តើយើងមានអារម្មណ៍ល្អ និងជឿជាក់ជាងមុនប៉ុណ្ណា នៅពេលបានឮពាក្យនេះ! ថ្មីៗនេះ អេមីលី(Emily) ដែលជាកូនស្រីរបស់ខ្ញុំ ដែលមានអាយុ១០ឆ្នាំ បានស្ងោពងមាន់ជាមួយគ្នា សម្រាប់អាហារពេលព្រឹក។ ពេលដែលយើងសម្លឹងមើលទៅទឹកដែលកំពុងពុះ និងចង់ដឹង ថាតើយើងត្រូវស្ងោវាយូរប៉ុណ្ណា ទើបបានឆ្អិន អេមីលីក៏បាននិយាយថា "គួរឲ្យស្ដាយណាស់ ដែលយើងមិនអាចបើកស៊ុតទាំងនោះ មើលខាងក្នុង ដើម្បីឲ្យដឹងថាតើវាឆ្អិនហើយឬនៅ"។ ខ្ញុំយល់ស្រប់នឹងមតិរបស់នាង តែបើយើងធ្វើដូចនេះ ស៊ុតទាំងនោះនឹងខូចជាមិនខាន ដូចនេះ យើងត្រូវពឹងផ្អែកទៅលើការស្មានរបស់យើង ដោយគ្មានការធានាអំពីលទ្ធផលឡើយ។

យើងក៏បានចាប់ផ្ដើមជជែកគ្នាអំពីរឿងផ្សេងៗទៀត ដែលយើងចង់ដឹងតែមិនអាចដឹងនៅពេលនេះបាន ដូចជារឿងថ្ងៃស្អែកជាដើម។ យើងក៏បាននិយាយថា គួរឲ្យស្ដាយខ្លាំងណាស់ ដែលយើងមិនអាចដឹងជាមុន ថាតើថ្ងៃស្អែកនឹងបានដូចដែលយើងចង់បានឬក៏អត់។ ប៉ុន្តែ ការលូកដៃចូលក្នុងពេលថ្ងៃស្អែក មុនពេលកំណត់ មិនខុសពីការបើកមើលពងមាន់ស្ងោ ដែលមិនទាន់ឆ្អិនឡើយ គឺវាអាចធ្វើឲ្យខូចពេលថ្ងៃនេះ និងថ្ងៃស្អែក។

ដោយសារព្រះយេស៊ូវបានសន្យាថា ទ្រង់នឹងថែរក្សាយើងជារៀងរាល់ថ្ងៃ គឺទាំងនៅក្នុងថ្ងៃស្អែកផង នោះយើងអាចរស់នៅ ដោយសេចក្តីជំនឿ មួយថ្ងៃម្ដងៗ(ម៉ាថាយ ៦:៣៣-៣៤)។

ខ្ញុំនិងអេមេលី ក៏បានសម្រេចចិត្តថ្វាយពេលថ្ងៃស្អែកដាច់ ទៅក្នុងព្រះហស្តព្រះ។ តើអ្នកបានថ្វាយហើយឬនៅ? – Joanie Yoder

*ទោះខ្ញុំមិនដឹងថា មានអ្វីដែលកំពុងរង់ចាំខ្ញុំ*
*តើមានអ្វីខ្លះនឹងកើតឡើងក្នុងពេលអនាគតក៏ដោយ*
*ក៏ខ្ញុំនៅតែដឹងថា ព្រះអម្ចាស់ទ្រង់ស្មោះត្រង់*
*ដ្បិតកាលពីមុន ខ្ញុំបានឃើញទ្រង់ស្មោះត្រង់ជានិច្ច។ - Anon*

---

**អ្នកគ្រាន់តែកំពុងធ្វើឲ្យខ្លួនមានបញ្ហាហើយ**
**ពេលដែលអ្នកព្រួយបារម្ភអំពីថ្ងៃស្អែកនោះ។**

# បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ម៉ាថាយ ៦:២៥-៣៤

២៥ ដោយហេតុនេះបានជា ខ្ញុំប្រាប់អ្នករាល់គ្នា
ថា កុំឲ្យខ្វល់ខ្វាយនឹងជីវិតដែលនឹងបរិភោគអ្វី
ឬនឹងរូបកាយ ដែលនឹងស្លៀកពាក់អ្វីនោះ
ឡើយ ឯជីវិត តើមិនវិសេសជាងចំណីអាហារ
ហើយរូបកាយ តើមិនវិសេសជាងសំលៀកបំពា
ក់ទេឬអី ២៦ ចូរពិចារណាពីសត្វ ស្លាបនៅលើ
អាកាស វាមិនសាបព្រោះ មិនច្រូតកាត់ ឬ
ប្រមូលដាក់ក្នុងជង្រុកផង តែព្រះវរបិតានៃអ្នក
ដែលគង់នៅស្ថានសួគ៌ ទ្រង់ចិញ្ចឹមវា ឯអ្នក
រាល់គ្នា តើគ្មានដំឡៃលើសជាងសត្វទាំងនោះ
ទេឬអី ២៧ ចុះនៅក្នុងពួកអ្នករាល់គ្នា តើមាន
អ្នកឯណាដែលអាចនឹងបន្ថែមកំពស់ខ្លួន១
ហត្ថ ដោយសារសេចក្តីខ្វល់ខ្វាយបានឬទេ
២៨ ហើយពីដំណើរ សំលៀកបំពាក់ តើអ្នករាល់
គ្នាខំខ្វល់ខ្វាយធ្វើអ្វី ចូររំពឹងគិតតែពីផ្កាឈូក
នៅក្នុងបឹង ដែលវាដុះជាយ៉ាងដូចម្តេច គឺវាមិន
នឿយហត់នឹងធ្វើការ ឬស្រាវរវៃទេ ២៩ តែខ្ញុំ
ប្រាប់អ្នក រាល់គ្នាថា សូម្បីតែហ្លួងសាឡូម៉ូន
ក្នុងគ្រាដែលមានគ្រប់ទាំងសេចក្តីរុងរឿងរបស់
ទ្រង់ នោះទ្រង់មិនបានតែងអង្គ ដូចជាផ្កា១
នោះផង ៣០ រីឯតិណជាតិ ដែលដុះនៅវាលក្នុង
ថ្ងៃនេះ ហើយថ្ងៃស្អែកត្រូវគេដុតនៅជើងក្រាន
បើព្រះទ្រង់តុបតែងស្មៅយ៉ាងដូច្នោះ នោះឱ
មនុស្សមានជំនឿតិចអើយ តើទ្រង់មិនតុបតែង
ឲ្យអ្នករាល់គ្នា លើសជាងទៅទៀតទេឬអី
៣១ ដូច្នេះ កុំឲ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី
ឬស្លៀកពាក់អ្វីនោះឡើយ ៣២ ដ្បិតគឺជា
សាសន៍ដទៃ ទេតើ ដែលខំស្វែងរករបស់ទាំង
នោះវិញ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់
នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នា
ត្រូវការនឹងរបស់ទាំងនោះដែរ ៣៣ ចូរស្វែងរក
នគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើប
គ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នក
រាល់គ្នាថែមទៀតផង ៣៤ ដូច្នេះ កុំឲ្យខ្វល់ខ្វាយ
នឹងថ្ងៃស្អែកឡើយ ពីព្រោះថ្ងៃស្អែកនឹង
ខ្វល់ខ្វាយ ចំពោះការរបស់ថ្ងៃនោះឯង សេចក្តី
លំបាកនៅថ្ងៃណា នោះគឺល្មមត្រឹមថ្ងៃនោះ
ហើយ។

## ការស្វែងយល់

បទគម្ពីរដ៏អស្ចារ្យនេះ គឺជាផ្នែកមួយ នៃសេចក្តីបង្រៀនដ៏ល្បីល្បាញបំផុត នៅក្នុងប្រវត្តិសាស្ត្រ គឺសេចក្តីបង្រៀននៅលើទួល។ ព្រះយេស៊ូវបានចាប់ផ្តើមមានបន្ទូលជាសេចក្តីបង្រៀននេះ ដោយការពិពណ៌នាអំពីជីវិតដែលមានពរ(ម៉ាថាយ ៥:១-១០) ហើយនៅចុងបញ្ចប់នៃសេចក្តីបង្រៀននេះ ទ្រង់បានត្រាសហៅ ឲ្យយើងកសាងជីវិតរបស់យើង នៅលើមូលដ្ឋានគ្រឹះខាងវិញ្ញាណដ៏ពិត (៧:២៤-២៧)។ នៅក្នុងផ្នែកកណ្តាលនៃសេចក្តីបង្រៀននេះ(ម៉ាថាយ ៦) យើងអាចឃើញលទ្ធផលជាក់ស្តែងក្នុងផ្នែកទាំងពីរនោះ ពោលគឺជីវិតដែលមានពរ ដែលសង់នៅលើគ្រឹះដ៏រឹងមាំ មិនត្រូវពោរពេញដោយការព្រួយបារម្ភឡើយ។ ព្រះទ្រង់តែងតែអាចផ្គត់ផ្គង់សេចក្តីត្រូវការរបស់យើង យ៉ាងគ្រប់គ្រាន់ជានិច្ច។

សប្តាហ៍ទី៣ ថ្ងៃពុធ

# ថ្ងៃចុងក្រោយរបស់អ្នក

សូមអាន
១ថែស្សាឡូនិច ៥:១-១១

ដូច្នេះ ត្រូវឲ្យយើងចាំយាម ហើយដឹងខ្លួន មិនត្រូវឲ្យដេកលក់ ដូចជាមនុស្សឯទៀតទេ ។ - ១ថែស្សាឡូនិច ៥:៦

តើអ្នកគិតយ៉ាងណា បើអ្នកបានដឹងនៅពេលព្រឹកនេះថា ថ្ងៃនេះគឺជាថ្ងៃចុងក្រោយរបស់អ្នក នៅលើផែនដីនេះ? តើអ្នកនឹងចំណាយពេលដ៏តិចតួច ដែលកំពុងតែខើចទៅៗនោះយ៉ាងដូចម្តេច? តើអ្នកចង់ទៅជួបនរណាខ្លះ? តើអាកប្បកិរិយារបស់អ្នក នឹងមានការខុសប្លែកពីធម្មតាឬទេ?

មានមនុស្សម្នាក់បាននិយាយយ៉ាងឆ្លាតវៃថា "អ្នកគួរតែចាត់ទុកថ្ងៃនីមួយៗ ហាក់ដូចជាថ្ងៃចុងក្រោយ ព្រោះក្នុងចំណោមថ្ងៃទាំងនោះ នឹងមានថ្ងៃមួយ ដែលជាថ្ងៃចុងក្រោយរបស់អ្នក"។ យើងមិនអាចគេចផុតពីថ្ងៃនោះបានទេ។ ទោះបីជាជីវិតខាងសាច់ឈាមរបស់យើង ត្រូវបញ្ចប់ដោយគ្រោះថ្នាក់ ដោយជម្ងឺ ដោយភាពចាស់ជរា ឬដោយការយាងមកវិញនៃព្រះអម្ចាស់នៃយើងក៏ដោយ ក៏ក្នុងចំណោមថ្ងៃទាំងនោះ មានថ្ងៃមួយដែលជាថ្ងៃចុងក្រោយរបស់យើង។ ហេតុនេះហើយបានជាយើងត្រូវមានការប្រុងប្រយ័ត្នបំផុត ចំពោះអ្វីដែលយើងនិយាយ និងអ្វីដែលយើងធ្វើ។ យើងគួរតែដោះស្រាយបញ្ហាដែលយើងមិនបានអើពើជាយូរមកហើយ ដោយបង្ហាញចេញនូវ សេចក្តីស្រឡាញ់ និងការថ្លែងអំណរគុណ ដល់អ្នកដទៃ ដោយស្វែងរកការផ្សះផ្សាគ្នា ជាមួយមិត្តភក្រដែលបានបែកបាក់គ្នា ឬដោយផ្សាយដំណឹងល្អជាមួយអ្នកជិតខាងជាដើម។ ប្រហែលជា អ្នកកំពុងរង់ចាំទទួលជឿព្រះយេស៊ូវជាព្រះអម្ចាស់ និងព្រះសង្គ្រោះ នៅថ្ងៃក្រោយដែលសមគួរជាងថ្ងៃនេះ។ ប៉ុន្តែ ថ្ងៃនោះប្រហែលជាមិនមកដល់ទេ ព្រោះថ្ងៃចុងក្រោយរបស់អ្នក អាចមកដល់ ដោយមិនបានដឹងជាមុន ដូចនេះ សូមស្តាប់តាមពាក្យលើកទឹកចិត្តរបស់សាវ័កប៉ុលថា : "មើលឥឡូវនេះជាវេលាដែលគាប់ព្រះហឫទ័យទ្រង់ មើល ថ្ងៃនេះជាថ្ងៃសង្គ្រោះហើយ"(២កូរិនថូស ៦:២)។ តើជារៀងរាល់ថ្ងៃ អ្នកកំពុងរស់នៅ ហាក់ដូចជាថ្ងៃនេះជាថ្ងៃចុងក្រោយឬទេ? – Vernon Grounds

*ចូរពិចារណាអំពីសេចក្តីនេះចុះ*
*បើថ្ងៃនេះជាថ្ងៃចុងក្រោយរបស់អ្នក នៅលើលោកិយនេះ*
*តើកិច្ចការសំខាន់បំផុតទាំងប្រាំ ដែលអ្នកនឹងធ្វើ មានអ្វីខ្លះ?*
*តើអ្នកនឹងស្វែងរកព្រះឬទេ?*

**តើអ្នកនឹងកែប្រែអ្វីខ្លះ**
**បើថ្ងៃនេះជាថ្ងៃចុងក្រោយរបស់អ្នក?**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១ថែស្សាឡូនិច ៥:១-១១

១ បងប្អូនអើយ ឯគ្រង់ពេលវេលា នោះមិនបាច់
ឲ្យខ្ញុំសរសេរប្រាប់មកអ្នករាល់គ្នាទេ ២ ដ្បិតអ្នក
រាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់
នឹងមកដល់ ដូចជាចោរមកនៅពេលយប់
៣ ដ្បិតកាលណាគេកំពុងតែ និយាយថា មាន
សេចក្តីសុខសាន្ត មានសេចក្តីរៀបរយហើយ
នោះលោតែមានសេចក្តីហិនវិនាសមកលើគេ
ភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយ
គេចមិនរួចឡើយ ៤ តែបងប្អូនអើយ អ្នករាល់
គ្នាមិនមែននៅក្នុងសេចក្តីងងឹត ឲ្យថ្ងៃនោះបាន
មកដល់អ្នករាល់គ្នា ដូចជាចោរនោះទេ ៥ អ្នក
រាល់គ្នាសុទ្ធតែជាពួកនៃពន្លឺ ហើយជាពួកនៃថ្ងៃ
យើងមិនមែនជាពួកនៃយប់ ឬនៃសេចក្តីងងឹត
ឡើយ ៦ ដូច្នេះ ត្រូវឲ្យយើងចាំយាម ហើយដឹង
ខ្លួន មិនត្រូវឲ្យដេកលក់ ដូចជាមនុស្សឯទៀត
ទេ ៧ ដ្បិតពួកអ្នកដែលដេកលក់ នោះគេតែង
ដេកនៅពេលយប់ ហើយពួកអ្នកដែលស្រវឹង
ស្រា ក៏តែងស្រវឹងនៅពេលយប់ដែរ ៨ តែយើង
ដែលជាពួកនៃ ថ្ងៃ យើងត្រូវដឹងខ្លួន ទាំង
ប្រដាប់កាយដោយសេចក្តីជំនឿ នឹងសេចក្តី
ស្រឡាញ់ ទុកជាប្រដាប់បាំងដើមទ្រូង ហើយ
សេចក្តីសង្ឃឹមរបស់ផងសេចក្តីសង្គ្រោះ ទុកជា
មួកសឹក ៩ ដ្បិតព្រះទ្រង់មិនបាន តម្រូវយើង
ទុកសំរាប់សេចក្តីក្រោធទេ គឺសំរាប់ឲ្យបានសេ
ចក្តីសង្គ្រោះវិញ ដោយសារព្រះយេស៊ូវគ្រីស្ទ
ជាព្រះអម្ចាស់នៃយើង ដែលទ្រង់សុគតជំនួស
យើង ១០ ដើម្បីឲ្យយើងរាល់គ្នាបានរស់នៅជា
មួយនឹងទ្រង់ ទោះបើចាំយាមឬដេកលក់ក្តី
១១ ដូច្នេះ ចូរកំសាន្ត ហើយស្អាងចិត្តគ្នា ទៅ
វិញទៅមក ដូចជាអ្នករាល់គ្នាកំពុងតែធ្វើហើយ
នោះដែរ។

### ការស្វែងយល់

ក្នុងបទគម្ពីរខាងលើនេះ សាវ័កប៉ុលបាននិយាយជាពាក្យប្រៀបប្រដូច ដោយធៀបពន្លឺជាមួយនឹងសេចក្តីងងឹត ដើម្បីបកស្រាយអំពីការរស់នៅខាងវិញ្ញាណ។ មានការប្រដូចបែបដូចនេះ ក្នុងព្រះគម្ពីរយ៉ូហាន ជំពូក ១ ដែលតាមបទគម្ពីរនេះ យើងដឹងថា ពន្លឺនៃព្រះគ្រីស្ទក៏បានភ្លឺមកក្នុងភាពងងឹត នៃលោកិយ ដែលវង្វេង។ ការដែលគួរឲ្យសោកស្តាយនោះ គឺថា ភាពងងឹតមិនអាចយល់ដល់ពន្លឺបានឡើយ(យ៉ូហាន ១:៥)។ រហូតមកដល់សព្វថ្ងៃនេះ មនុស្សដែលបាត់បង់ នៅក្នុងភាពងងឹត កំពុងព្យាយាមយល់ដល់ពន្លឺនៃព្រះគ្រីស្ទ។ ហេតុនេះហើយ បានជាសាវ័កប៉ុលចង់រំឭកអ្នកអានសំបុត្ររបស់គាត់ អំពីបញ្ហាដ៏សំខាន់ទាំងនេះ។

សប្តាហ៍ទី៣ ថ្ងៃព្រហស្បតិ៍

# អាថ៌កំបាំងមួយ ដែលបានបើកសម្តែង

សូមអាន
១កូរិនថូស ១៥:៥១-៥៨

បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ បើមាន នោះទូលបង្គំនឹងរង់ចាំអស់រវាងសង្គ្រាមវេទនារបស់ទូលបង្គំ ដរាបដល់កំណត់ដែលទូលបង្គំបានរំដោះចេញទៅ។
- យ៉ូប ១៤:១៤

បន្ទាប់ពីយើងស្លាប់ទៅ តើមានអ្វីកើតឡើងចំពោះយើង? អាថ៌កំបាំងនេះមានភាពគួរឲ្យចាប់អារម្មណ៍ចំពោះមនុស្សនៅគ្រប់សម័យកាលទាំងអស់។ អ្នកស្រាវជ្រាវខ្លះបានធ្វើការអះអាងយ៉ាងប្រុងប្រយ័ត្នថា ពួកគេជិតរកឃើញចម្លើយនោះហើយ។ ពួកគេបានធ្វើការសិក្សាលើរបាយការណ៍ ដែលគេទទួលពីការសម្ភាសពួកអ្នកដែលបានអះអាងថា បានពិសោធនឹងការជិតផុតដង្ហើមស្លាប់ ដែលបាននាំឲ្យពួកគេឆ្លងកាត់ពេលវេលា និងពិភពថ្មី។ អ្នកវិភាគខ្លះបានគិតថា បើគេនៅតែស្រាវជ្រាវជាបន្ថែមទៀត ថ្ងៃណាមួយ គេនឹងអាចបកស្រាយអាថ៌កំបាំងនៃសេចក្តីស្លាប់ជាមិនខាន។

តើយើងត្រូវទន្ទឹងរង់ចាំ យ៉ាងអន្ទះអន្ទែង ដល់ពេលដែលពួកគេរកឃើញចម្លើយនោះឬ? យើងមិនអាចរង់ចាំបានទេ! ព្រះទ្រង់បានបើកសម្តែងនៅក្នុងព្រះគម្ពីរ ឲ្យយើងបានដឹងថា មានអ្វីកើតឡើង បន្ទាប់ពីយើងស្លាប់ហើយ។

បើយើងបានទទួលជឿព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ ជាព្រះសង្គ្រោះ នោះយើងដឹងថា យើងនឹង "បានទៅនៅជាមួយព្រះអម្ចាស់" បន្ទាប់ពីយើងបានស្លាប់ (២កូរិនថូស ៥:៨)។ សាវ័កប៉ុលបានមានប្រសាសន៍ថា ដោយសារព្រះគ្រីស្ទបានសុគតជួសបាបយើង ហើយបានមានព្រះជន្មឡើងវិញ នោះ"សេចក្តីជ័យជំនះបានលេបសេចក្តីស្លាប់បាត់ហើយ"(១កូរិនថូស ១៥:៥៤)។ តែអ្នកដែលបានបដិសេធព្រះគ្រីស្ទ នឹងត្រូវប្រឈមមុខនឹងការជំនុំជម្រះដ៏សហ័សរបស់ព្រះ និងត្រូវជាប់ក្នុងស្ថាននរកអស់កល្បជានិច្ច(វិវរណៈ ២០:១១-១៥)។

អ្នកស្រាវជ្រាវដែលឆ្លាតវ័យ គឺជាអ្នកដែលស្រាវជ្រាវនៅក្នុងព្រះគម្ពីរ ដើម្បីស្វែងរកឲ្យដឹងថា មានអ្វីនឹងកើតឡើងចំពោះយើង បន្ទាប់ពីយើងបានស្លាប់។ ការស្វែងរកនេះ នាំឲ្យយើងរកបានចម្លើយរបស់ព្រះ ចំពោះសំណួរដ៏សំខាន់បំផុត ក្នុងគ្រប់សម័យកាលទាំងអស់។ ផ្នូររបស់ព្រះគ្រីស្ទ ដែលបាននៅទទេរ គឺបានធានាដល់យើងថា អាថ៌កំបាំងនេះត្រូវបានបើកសម្តែងរួចហើយ។ - Vernon Grounds

*ទ្រង់មានព្រះជន្មរស់ ហើយប្រទានឲ្យខ្ញុំមានដង្ហើមដកជារៀងរាល់ថ្ងៃ*
*ទ្រង់មានព្រះជន្មរស់ ហើយខ្ញុំនឹងឈ្នះសេចក្តីស្លាប់*
*ទ្រង់មានព្រះជន្មរស់ ហើយបានរៀបចំអនាគតឲ្យខ្ញុំ*
*ទ្រង់មានព្រះជន្មរស់ ដើម្បីនាំខ្ញុំទៅកាន់ទីកន្លែងនោះ ដោយសុវត្ថិភាព។ - Medley*

**ដោយព្រោះទ្រង់រស់**
**សេចក្តីស្លាប់មិនមែនជាសោកនាដកម្មទេ តែជាជ័យជម្នះរបស់យើង។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១កូរិនថូស ១៥:៥១-៥៨

៥១ នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្ដីអាថ៌កំបាំង
គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ
៥២ តែទាំងអស់គ្នានឹង បានផ្លាស់ប្រែទៅក្នុង១
រំពេចវិញ គឺក្នុង១ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុង
កាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹង
ឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ
មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹង
បានផ្លាស់ប្រែទៅ ៥៣ ដ្បិតត្រូវតែរូបកាយ ដ៏
ពុករលួយនេះ បានប្រដាប់ដោយសេចក្ដីមិន
ពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់
នេះ ត្រូវតែបានប្រដាប់ដោយសេចក្ដីមិនចេះ
ស្លាប់វិញដែរ ៥៤ កាលណារូបកាយពុករលួយ
នេះ បានប្រដាប់ដោយសេចក្ដីមិនពុករលួយ
ហើយរូបកាយដែលតែងតែស្លាប់នេះ បាន
ប្រដាប់ដោយសេចក្ដីមិនចេះស្លាប់វិញ នោះ
ទើបនឹងបានសំរេចតាមពាក្យ ដែលចែងទុក
មកថា «សេចក្ដីជ័យជំនះបានលេបសេចក្ដី
ស្លាប់បាត់ហើយ» ៥៥ «ឱសេចក្ដីស្លាប់អើយ
ទ្រនិចឯងនៅឯណា សេចក្ដីស្លាប់អើយ ជ័យជំ
នះរបស់ឯងនៅឯណា» ៥៦ រីឯទ្រនិចនៃសេច
ក្ដីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់
បាប គឺជាក្រឹត្យវិន័យ ៥៧ តែអរព្រះគុណដល់
ព្រះអង្គ ពីព្រោះទ្រង់ប្រទានឲ្យយើងរាល់គ្នា
មានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជា
ព្រះអម្ចាស់នៃយើង ៥៨ បានជាបងប្អូន ស្ងួនភ្ងា
អើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ
ទាំងធ្វើការព្រះអម្ចាស់ ឲ្យបរិបូរជាដរាបចុះ
ដោយដឹងថា ការដែលអ្នករាល់គ្នាខំប្រឹងធ្វើក្នុង
ព្រះអម្ចាស់ នោះមិនមែនឥតប្រយោជន៍ទេ។

## ការស្វែងយល់

មានប្រធានបទតិចតួចទេ ដែលនាំឲ្យចិត្តរបស់យើងមានការភ័យខ្លាច និងថប់បារម្ភខ្លាំងជាងប្រធានបទអំពីសេចក្ដីស្លាប់។ ភាគច្រើននៃការថប់បារម្ភនោះ គឺបណ្ដាលមកពីការមិនបានដឹងច្បាស់ តែសាវ័កប៉ុលបានប្រាប់យើងយ៉ាងច្បាស់ ក្នុងបទគម្ពីរខាងលើថា យើងមិនចាំបាច់ត្រូវមានអារម្មណ៍ភ័យខ្លាចចំពោះសេចក្ដីស្លាប់ឡើយ។ យើងអាចមានទំនុកចិត្តទាំងស្រុង ព្រោះព្រះយេស៊ូវទ្រង់បានឈ្នះសេចក្ដីស្លាប់ ដោយមានព្រះជន្មឡើងវិញ ហើយប្រទាននូវលទ្ធផលនៃជ័យជម្នះនោះ ដល់យើង បើយើងទុកចិត្តទ្រង់ ដោយជំនឿ។

សប្ដាហ៍ទី ៣ ថ្ងៃសុក្រ

# ឥស្សូតាខ ដែល បញ្ជាក់ ដោយផ្នូរ ដែលនៅទទេ

សូមអាន
១កូរិនថូស ១៥:១-៨

ដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ ។ -១កូរិនថូស ១៥:៤

នៅថ្ងៃបន្ទាប់ពីបដិវត្តន៍ជនជាតិបារាំងបានបញ្ចប់ មានបុរសម្នាក់បានព្យាយាមបង្កើតសាសនាថ្មីមួយ ដោយជឿថា សាសនាថ្មីនោះល្អជាងជំនឿលើព្រះគ្រីស្ទ។ ប៉ុន្តែ គាត់ត្រូវខកចិត្ត ចំពោះបរាជ័យរបស់ខ្លួន។ គាត់បានបង្ហាញនូវភាពនឿយណាយរបស់ខ្លួន ដល់អ្នកដឹកនាំក្នុងព្រះវិហារម្នាក់ ហើយបានសួរថា តើគាត់ត្រូវធ្វើយ៉ាងដូចម្ដេច។

អ្នកដឹកនាំរូបនេះក៏បានឆ្លើយតបថា ការបង្កើតសាសនាថ្មី គឺមិនមែនជាកិច្ចការដែលងាយស្រួលទេ គឺវាពិបាកខ្លាំងណាស់ បានជាគាត់មិនដឹងថា គួរឲ្យយោបលដូចម្ដេចទេ។ ប៉ុន្តែ មួយសន្ទុះក្រោយមក គាត់ក៏បានមានប្រសាសន៍ថា "មានផែនការមួយ ដែលអ្នកអាចយកមកពិចារណា។ គឺហេតុអ្វី បានជាអ្នកមិនទៅឲ្យគេចាប់ឆ្កាង ហើយរស់ឡើងវិញនៅថ្ងៃទីបីទៅ?"

ផ្នូរដែលនៅទទេ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំ នៃជំនឿរបស់គ្រីស្ទបរិស័ទ។ ព្រះគម្ពីរសញ្ញាថ្មីបានប្រកាសថា ការសុគតរបស់ព្រះគ្រីស្ទបានសងថ្លៃលោះបាបយើងហើយ។ តើធ្វើដូចម្ដេចឲ្យគេអាចដឹងថា ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង គឺជាទីសព្វព្រះទ័យដល់ព្រះ? ដែលយើងគិតយ៉ាងណា អំពីការសុគតរបស់ព្រះគ្រីស្ទ នោះគឺមិនសំខាន់ទេ ហើយដែលព្រះគិតយ៉ាងណាអំពីការសុគតនេះ ទើបពិតជាសំខាន់។

ការដែលព្រះទ្រង់ឲ្យព្រះគ្រីស្ទមានព្រះជន្មឡើងវិញ គឺបានបង្ហាញថា ទ្រង់បានពេញព្រះទ័យនឹងការលះបង់ព្រះជន្មរបស់ព្រះគ្រីស្ទហើយ។ ការមានព្រះជន្មឡើងវិញនេះ គឺជាសញ្ញាបញ្ជាក់ថា ព្រះទ្រង់បានសព្វព្រះទ័យទាំងស្រុងមែន។ បើគ្មានការមានព្រះជន្មឡើងវិញទេ ជំនឿលើព្រះគ្រីស្ទមិនសូវមានប្រយោជន៍អ្វីសម្រាប់លោកិយទេ។ ប៉ុន្តែ សេចក្ដីពិតដែលព្រះគ្រីស្ទបានសុគត ហើយមានព្រះជន្មឡើងវិញ "ជាព្រះចេស្ដានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ"(រ៉ូម ១:១៦)។ - Haddon Robinson

*សូមពិចារណាអំពីសេចក្ដីនេះចុះ*
*អ្នកខ្លះនិយាយថា ជំនឿលើព្រះគ្រីស្ទគឺជាទំនាក់ទំនង*
*គឺមិនមែនជាសាសនាទេ។ តើអ្នកមានទំនាក់ទំនងនេះ ហើយឬនៅ?*

---

**ដោយសារផ្នូរទទេរបស់ព្រះគ្រីស្ទ**
**នោះយើងអាចមានសេចក្ដីសង្ឃឹមយ៉ាងពោរពេញ**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១កូរិនថូស ១៥:១-៨

១ បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងពី
ដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ជា
ដំណឹងដែលអ្នករាល់គ្នាបានទទួល ក៏ឈរជាប់
ក្នុងនោះផង ២ អ្នករាល់គ្នាកំពុងតែ បានស
ង្គ្រោះ ដោយសារដំណឹងល្អនោះផង គឺបើសិន
ជាកាន់ខ្ជាប់តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែង
ប្រាប់មក លើកតែអ្នករាល់គ្នាបានជឿ ដោយ
ឥតបើគិត ៣ ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មក
អ្នករាល់គ្នា តាមសេចក្តីដែលខ្ញុំបានទទួលដែរ
គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាប
របស់យើងរាល់គ្នា តាមបទគម្ពីរ ៤ ហើយថា
ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះ
ទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ
៥ ហើយថា ទ្រង់បានលេចមកឲ្យកេផាស
ឃើញ រួចដល់ពួក១២នាក់ដែរ ៦ ក្រោយទៀត
ទ្រង់លេចមកឲ្យពួកបងប្អូនជាង៥០០នាក់
ឃើញតែម្តង ជាពួកដែលមានគ្នាច្រើនរស់នៅ
ដរាបដល់សព្វថ្ងៃនេះ តែមានខ្លះបានដេកលក់
ទៅហើយ ៧ ក្រោយទៀត ទ្រង់លេចមកឲ្យយ៉ា
កុបឃើញ ក៏ឲ្យពួកសាវ័កទាំងអស់គ្នាឃើញ
ដែរ ៨ រួចទ្រង់បានលេចមកឲ្យខ្ញុំឃើញ ជាខាង
ក្រោយគេបង្អស់ ដូចជាលេចមកដល់កូនកើត
មុនកំណត់ដែរ។

## ការស្វែងយល់

សូមគត់សំគាល់ថា សាវ័កប៉ុលចង់ឲ្យយើងដឹងថា ការមានព្រះជន្មឡើងវិញ គឺមិនមែនជាភាពអរូបីផ្ទៃក ទស្សនៈវិជ្ជា ឬទ្រឹស្តីនៃទេវវិជ្ជាឡើយ តែជាហេតុការណ៍ដ៏ពិតនៃប្រវត្តិសាស្ត្រ ដែលមានសាក្សីផ្សេងៗជាច្រើនបានធ្វើបន្ទាល់។ សាក្សីទាំងនេះមានចំនួនរាប់រយនាក់ ហើយក្នុងនោះមានសាវ័កដ៏អាម៉ាសម្នាក់(គឺលោកពេត្រុស) និងបងប្អូនប្រុសរបស់ព្រះយេស៊ូវដែលមានចិត្តសង្ស័យ (យ៉ាកុប) ហើយអ្នកដែលស្អប់ព្រះគ្រីស្ទ និងបានបៀតបៀនគ្រីស្ទបរិស័ទ(គឺសាវ័កប៉ុល) ក៏បានឃើញព្រះគ្រីស្ទផងដែរ។ ដោយសារព្រះគ្រីស្ទបានមានព្រះជន្មឡើងវិញ នោះជីវិតរបស់ពួកគេក៏បានផ្លាស់ប្រែជារៀងរហូត។

ថ្ងៃសៅរ៍ពិសេស/ ទំព័រពិសេសសម្រាប់ថ្ងៃអាទិត្យ

# មូលហេតុទាំង១០យ៉ាង ដែលត្រូវជឿថា ព្រះបានមកយកកំណើតជាមនុស្ស

## ១. ចាប់កំណើតនៅក្នុងផ្ទៃស្រ្តីព្រហ្មចារី

បើនាងម៉ារាបានប្រាប់ពីការពិត នោះបុត្រតូចរបស់នាង មិនមានឪពុកជាមនុស្សទេ។ ទេវតាបានប្រាប់នាងថា នាងនឹងប្រសូត្របានបុត្រាមួយ ដោយព្រះវិញ្ញាណនៃព្រះនឹងយាងមកសណ្ឋិតលើនាង។ បុត្រនោះត្រូវថ្វាយព្រះនាមថា យេស៊ូវ ដែលហៅថា ព្រះរាជបុត្រានៃព្រះ( លូកា ១:២៦-៣៥)។ បើនាងម៉ារាបាននិយាយកុហក់ នោះយប់ដែលព្រះយេស៊ូវប្រសូត្រមិនមែនជាយប់បរិសុទ្ធទេ ហើយសេចក្តីពិតក៏គ្មានដែរ។ បើបុត្រារបស់នាង មានជីវិតរស់នៅដូចជាមនុស្សដទៃទៀត នោះការអះអាងរបស់នាង អំពីការប្រសូត្រពីស្រ្តីព្រហ្មចារី គឺជារឿងប្រឌិត ដែលគេងាយនឹងច្រានចោល បំផុត។

## ២. មានហោរានៅគ្រាសញ្ញាចាស់ បានថ្លែងទំនាយអំពីព្រះដែលយកកំណើតជាមនុស្ស

រយៈពេលប្រាំពីររយឆ្នាំ មុនពេលព្រះយេស៊ូវប្រសូត្រ ហោរាអេសាយ បានថ្លែងទំនាយយ៉ាងដូចនេះថា "ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើងហើយ ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព"( អេសាយ ៩:៦)។ លោកហោរាអេសាយក៏បានថ្លែងទំនាយផងដែរថា "ព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់១មកអ្នករាល់គ្នា ដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល"( អេសាយ ៧:១៤)។ ពាក្យអេម៉ាញូអែល គឺមានន័យថា "ព្រះគង់ជាមួយយើង"។

## ៣. ទេវតាបានប្រកាសអំពីការប្រសូត្ររបស់ព្រះយេស៊ូវ

ទេវតាបានប្រកាសដល់ពួកអ្នកគង្វាលដែលជាសាសន៍យូដា ដែលកំពុងភ័យខ្លាច ឲ្យបានដឹងអំពីការប្រសូត្ររបស់ព្រះមែស៊ី ដែលពួកអ៊ីស្រាអែលបានរង់ចាំជាយូរមកហើយ( លូកា ២:៨-១៤)។ "ទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសំរាប់បណ្តាជនទាំងអស់គ្នា ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ហើយនេះជាទីសំគាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរស១រុំនឹងសំពត់ផ្តេកនៅក្នុងស្នូក"។

(ខ.១១-១២)

## ៤. សញ្ញាដែលបានលេចឡើង នៅលើមេឃ

មានពួកអ្នកប្រាជ្ញមួយក្រុម បានធ្វើដំណើរមកពីទិសខាងកើត តាមផ្កាយមួយ រហូតដល់ក្រុងបេ-ថ្លេហិម ដែលនៅទីនោះ ពួកគេក៏បានចូលគាល់ព្រះមែស៊ី ដែលគេបានទន្ទឹងរង់ចាំជាយូរមកហើយ។ អស់រយៈពេលរាប់រយឆ្នាំ មុនពេលទ្រង់ប្រសូត្រ ពួកហោរាសម័យសញ្ញាចាស់បានថ្លែងអំពី "ផ្កាយមួយ" និង "ដំបងមួយ" ដែលនឹងលេចចេញពីសាសន៍អ៊ីស្រាអែល(ជនគណនា ២៤:១៧) ដែលជាអ្នកដឹកនាំម្នាក់ នៃសាសន៍អ៊ីស្រាអែល ដែលចេញពីក្រុងបេថ្លេហិម និងជាអ្នកដឹកនាំ "ដែលបានប្រសូត្រមក ទ្រង់មានតាំងពីដើម តាំងពីអស់កល្បជានិច្ច"(មីកា ៥:២)។

## ៥. ការយាងមកក្នុងពេលដ៏ត្រឹមត្រូវ

បើអ្នកប្រាជ្ញទាំងនោះ(ដែលបានមកថ្វាយបង្គំព្រះយេស៊ូវ បន្ទាប់ពីទ្រង់បានប្រសូត្រ) បានធ្វើដំណើរមកពីតំបន់បាប៊ីឡូន នោះពួកគេអាចដឹងអំពីទំនាយរបស់ហោរាជនជាតិយូដាម្នាក់ ដែលមានឈ្មោះថា ដានីយ៉ែល។ កាលពី៤០០ឆ្នាំមុន ពេលដែលលោកដានីយ៉ែលកំពុងជាប់ជាឈ្លើយនៅចក្រភពបាប៊ីឡូន គាត់បានទទួលការបើកសម្តែងពីព្រះ(ដានីយ៉ែល ៦:១៣-១៤ ៩:២៤-២៧) ដែលអនុញ្ញាតឲ្យមានការគណនារយៈពេល នៃការយាងមកនៃព្រះមែស៊ី ក្នុងចំណោមសាសន៍យូដា។

## ៦. ព្រះយេស៊ូវបានអះអាងថា ទ្រង់មានភាពស្មើនឹងព្រះ

ព្រះយេស៊ូវបានអះអាងជាច្រើនដង ថាទ្រង់និងព្រះ គឺតែមួយទេ។ ព្រះយេស៊ូវមានបន្ទូលថា "មុនដែលលោកអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ"(យ៉ូហាន ៨:៥៨)។ ""(ក្នុង និក្ខមនំ ៣:១៤ ព្រះមានបន្ទូលថា "អញជាព្រះដ៏ជាព្រះ" ដើម្បីឲ្យលោកម៉ូសេបានស្គាល់អត្តសញ្ញាណរបស់ទ្រង់)។ " ខ្ញុំហើយ និងព្រះវរបិតា គឺតែ១ព្រះអង្គទេ"(យ៉ូហាន ១០:៣០)។ "បើអ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះបានស្គាល់ព្រះវរបិតាដែរ អំពីនេះទៅមុខ អ្នករាល់គ្នាក៏ស្គាល់ ហើយបានឃើញទ្រង់ផង" (យ៉ូហាន ១៤:៧)។ តាមព្រះបន្ទូលព្រះយេស៊ូវ ត្រង់ចំណុចនេះ បើយើងស្រឡាញ់ទ្រង់ នោះយើងក៏ស្រឡាញ់ព្រះវរបិតាដែរ ឬបើយើងស្អប់ទ្រង់ នោះយើងក៏ស្អប់ព្រះវរបិតាដែរ ហើយបើយើងទទួលទ្រង់ នោះក៏ទទួលព្រះវរបិតាដែរ ឬបើយើងបដិសេធទ្រង់ នោះយើងក៏បដិសេធព្រះវរបិតាដែលគង់នៅនគរស្ថានសួគ៌ដែរ។

## ៧. មិត្តសំឡាញ់ទ្រង់បានថ្វាយបង្គំទ្រង់

ពេលដែលលោកថូម៉ាស ដែលជាសិស្សរបស់ព្រះយេស៊ូវ បានឃើញទ្រង់ បន្ទាប់ពីទ្រង់មានព្រះជន្មឡើងវិញ គាត់បានប្រកាសថា "ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ"(យ៉ូ

ហាន ២០:២៨)។ សាវ័កយ៉ូហានបានចែងថា "កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក គ្រប់របស់ទាំងអស់បាន កើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ ... ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត"(យ៉ូហាន ១:១-៣,១៤)។

## ៨. សត្រូវរបស់ព្រះយេស៊ូវបានចោទទ្រង់ ថាបានប្រមាថព្រះ

ពួកអ្នកដឹកនាំសាសនា មានការខឹងសម្បា ពេលបានដឹងថា បុរសម្នាក់ដែលបានចោទពួកគេថា ជាអ្នកដឹកនាំដែលមានពុតនិងខ្វាក់ បានអះអាងថា ខ្លួនអាចអត់ទោសបាប ហើយនិយាយថា ព្រះជាព្រះបិតារបស់ខ្លួន ហើយថែមទាំងថា ខ្លួនហើយនិងព្រះ គឺតែមួយទេ។ ពួកអ្នកដឹកនាំសាសនាទាំងនោះ បានរើសថ្ម បម្រុងនឹងចោលព្រះយេស៊ូវ ដោយនិយាយថា "យើងចោលអ្នកនឹងថ្ម មិនមែនដោយព្រោះការល្អណាទេ គឺដោយព្រោះពាក្យប្រមាថដល់ព្រះ ហើយពីព្រោះអ្នក ដែលជាមនុស្ស បានតាំងខ្លួនឡើងជាព្រះវិញប៉ុណ្ណោះ"។

## ៩. ការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើ បានបញ្ជាក់ថា ការអះអាងរបស់ទ្រង់គឺជាការពិត

ព្រះយេស៊ូវបានធ្វើការអស្ចារ្យ និងធ្វើទីសំគាល់ ដើម្បីលើកទឹកចិត្តមនុស្សប្រុសស្រី ឲ្យជឿលើទ្រង់។ ទ្រង់បានដើរលើទឹក បានប្រោសមនុស្សមានជម្ងឺឲ្យជា ហើយថែមទាំងបានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញទៀត។ សាវ័កយ៉ូហានបានចែងថា "ព្រះយេស៊ូវក៏ធ្វើទីសំគាល់ជាច្រើនទៀត នៅមុខពួកសិស្សទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ បានចែងទុកតែប៉ុណ្ណោះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ"(យ៉ូហាន ២០:៣០-៣១)។

## ១០. ការយាងចេញរបស់ទ្រង់ មានភាពអស្ចារ្យជាងការយាងមកដល់

មានមនុស្សជាច្រើនបានអះអាងថា ខ្លួនជាព្រះ។ តែមានតែមនុស្សម្នាក់គត់ ដែលបានស្ម័គ្រចិត្តសុគត ដើម្បីលោះបាបរបស់អ្នកដទៃ។ មានតែទ្រង់ទេដែលមានព្រះជន្មឡើងវិញ ដើម្បីបញ្ជាក់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ។ បន្ទាប់ពីព្រះយេស៊ូវបានស្ម័គ្រព្រះទ័យលះបង់ព្រះជន្មទ្រង់ នៅលើឈើឆ្កាង ទ្រង់បានមានព្រះជន្មឡើងវិញ ហើយបានបង្ហាញព្រះអង្គទ្រង់ដល់ពួកសិស្សដែលជិតស្និទ្ធបំផុតរបស់ទ្រង់ និងដល់មនុស្សជាងប្រាំរយនាក់ អស់រយៈពេល៤០ថ្ងៃ (១កូរិនថូស ១៥:៥-៨)។ ពួកសាក្សីទាំងនេះមានការជឿជាក់យ៉ាងមុតមាំថា ទ្រង់ពិតជាបានរស់ឡើងវិញមែន ដូចនេះ ហើយបានជាពួកគេព្រមរងទុក្ខ និងស្លាប់ ដើម្បីប្រកាសថា ទ្រង់បាន

រស់ឡើងវិញហើយ។ បន្ទាប់មក នៅលើភ្នំដើមអូលីវ ទ្រង់បានប្រទាននូវព្រះបន្ទូលចុងក្រោយដល់ពួកគេ ហើយក៏ត្រូវបានលើកឡើងទៅឯពពក។ ការយាងទៅវិញរបស់ទ្រង់ មានភាពអស្ចារ្យជាងការយាងមកយកកំណើត ហើយការនេះបាននាំឲ្យយើងមានការយល់ដឹងកាន់តែច្បាស់អំពីការប្រកាសរបស់ទេវតាថា "ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់"(លូកា ២:១១)។

## មិនមែនមានតែអ្នកទេដែលមានបញ្ហានេះ

មិនមែនមានតែអ្នកទេ ដែលមានអារម្មណ៍ច្របូកច្របល់ នៅពេលអ្នកគិតអំពីភស្តុតាងដែលបញ្ជាក់អំពីព្រះជន្មរបស់ព្រះយេស៊ូវនោះ។ អ្នកប្រហែលជាចង់ជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ប៉ុន្តែអ្នកមិនបានដឹងច្បាស់អំពីទំនាក់ទំនង ដែលអ្នកមានជាមួយនឹងទ្រង់ទេ។ បើសិនអ្នកមានបញ្ហានេះមែន សូមដឹងច្បាស់ថា : បើអ្នកទទួលទ្រង់ នោះទ្រង់ក៏នឹងទទួលអ្នកដែរ។ បើអ្នកទទួលការអត់ទោសបាប ជីវិតអស់កល្បជានិច្ច និងការទទួលជាកូន នៅក្នុងគ្រួសាររបស់ព្រះ នោះទ្រង់បានក្លាយជាព្រះសង្គ្រោះ គ្រូបង្រៀន និងព្រះអម្ចាស់របស់អ្នក។ នេះជាអំណោយទានដ៏អស្ចារ្យបំផុត ដែលព្រះទ្រង់បានបង់ថ្លៃដោយផ្ទាល់ សម្រាប់អ្នក។

**សម្រាប់ការអានបន្ថែមសូមមើលសៀវភៅ :**
ហេតុអ្វីបានជាការជឿលើព្រះគ្រីស្ទ មានអត្ថន័យ។

សប្ដាហ៍ទី៤ ថ្ងៃច័ន្ទ

## គ្មានសេចក្ដីស្រឡាញ់ដែលអស្ចារ្យជាងនេះ

សូមអាន
ម៉ាកុស ១២:២៨-៣៤

គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិតជំនួសពួកសំឡាញ់របស់ខ្លួននោះទេ ។ -យ៉ូហាន ១៥:១៣

អ្នកមិនអាចបង្ហាញសេចក្ដីស្រឡាញ់ ចំពោះអ្នកដទៃឲ្យបានច្រើនជាងលោកចេមស៍ ហារីសុន(James Harrison) ឡើយ។ គាត់បានបង្ហាញសេចក្ដីស្រឡាញ់ដល់អ្នកដែលគាត់មិនដែលស្គាល់។

លោកហារីសុន ដែលជាសមាជិកក្រុមចម្រៀងនៃសកល វិទ្យាល័យបាទីស្ទ វ៉ស៊ីថា(Oauchita)កំពុងធ្វើដំណើរត្រឡប់មកផ្ទះវិញពីទ្វីបអឺរ៉ុប ជាមួយនឹងមិត្តរួមក្រុមចម្រៀងរបស់គាត់។ ពេលដែលយន្តហោះរបស់ពួកគេ កំពុងចុះចតនៅតំបន់លីទ-ធលរ៉ក់(Little Rock) នៅរដ្ឋអាខិនសាស់(Arkansas) វាក៏បានជួបនឹងភ្លៀងធ្លាក់និងខ្យល់បក់ខ្លាំង។ យន្តហោះនេះក៏បានរអិលអូសកង់ធ្លាក់ចេញពីផ្លូវចុះចត ហើយក៏ទង្គិចនឹងបង្គោលភ្លើងហ្វា បណ្ដាលឲ្យសំបកតួខ្លួនរបស់វាត្រូវរបើកចេញ។ ពេលដែលភាពវឹកវរបានកើតមាន ហើយអណ្ដាតភ្លើងក៏បានឆេះឡើង នៅក្នុងយន្តហោះដែល បានជួបគ្រោះថ្នាក់មួយគ្រឿងនេះ លោកហារីសុនក៏បានចាប់ផ្ដើមជួយអ្នកដទៃ។ គាត់បានទាញអ្នកដំណើរចេញពីយន្តហោះ ហើយរត់មកជួយអ្នកផ្សេងទៀតម្ដងម្នាក់ៗ។ ក្នុងដំណើរចុងក្រោយរបស់គាត់ ចូលទៅក្នុងបំណែកយន្តហោះនេះ គាត់ក៏បានពល់ផ្សែង ហើយបាត់បង់ជីវិតនៅខាងក្នុងនោះ។

នៅក្នុងពិធីបុណ្យសពរបស់គាត់ អ្នកដឹកនាំក្រុមចម្រៀងបានដកស្រង់បទគម្ពីរយ៉ូហាន ១៥:១៣ "គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ"។ ក្នុងបទគម្ពីរនេះ ព្រះយេស៊ូវពិតជាកំពុងមានបន្ទូលអំពីការសុគតរបស់ទ្រង់ ជួសយើងរាល់គ្នា ហើយអ្នកដឹកនាំក្រុមចម្រៀងរូបនេះ បានលើកឡើងអំពីតម្លៃនៃការលះបង់ដ៏ខ្លាំងបំផុតនេះ។

យើងប្រហែលជាមិនដែលមានឱកាសបានទទួលការត្រាសហៅ ឲ្យធ្វើការលះបង់ ដូចលោកហារីសុន នៅក្នុងសោកនាដកម្មនោះទេ។ តែជារៀងរាល់ថ្ងៃ យើងមានឱកាសលះបង់ភាពស្រណុកស្រួលរបស់ខ្លួន ដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់យើងដល់អ្នកដទៃ(ម៉ាកុស ១២:៣១)។ តើយើងត្រូវបង្ហាញសេចក្ដីស្រឡាញ់ច្រើនប៉ុណ្ណា? – Dave Branon

*សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ កើនឡើងនៅក្នុងយើងកាន់តែខ្លាំង*
*សេចក្ដីសប្បុរសរបស់ទ្រង់ក៏ហូរហៀកាន់តែខ្លាំង*
*ហើយពេលយើងជួបនឹងការល្បួងលដ៏លំបាក*
*នោះយើងនឹងបានបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់។ - Hess*

---

**នៅក្នុងពិភពលោក ដែល "មិនអាចកាត់បន្ថយការយកចិត្តទុកដាក់"**
**ព្រះគ្រីស្ទសព្វព្រះទ័យឲ្យយើងយកចិត្តទុកដាក់កាន់តែខ្លាំង**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ម៉ាកុស ១២:២៨-៣៤

២៨ នោះមានអាចារ្យម្នាក់ ចូលមកឮជជែកគ្នា
ក៏យល់ឃើញថា ទ្រង់បានឆ្លើយត្រូវចំ រួចគាត់
ទូលសួរទ្រង់ថា ក្នុងបញ្ញត្តទាំងប៉ុន្មាន តើមាន
បទណាសំខាន់ជាងគេទាំងអស់ ២៩ ព្រះយេស៊ូ
វមាន ព្រះបន្ទូលឆ្លើយថា ឯបញ្ញត្តដែលសំខាន់
ជាងគេ នោះគឺថា «ចូរស្តាប់ចុះ អ៊ីស្រាអែល
អើយ ព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំ ទ្រង់ជា
ព្រះអម្ចាស់តែ១ព្រះអង្គទ្រង់ ៣០ ហើយឯងត្រូវ
ស្រឡាញ់ ដល់ព្រះអម្ចាស់ ជាព្រះនៃឯង ឲ្យ
អស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត
ហើយអស់អំពីកំឡាំងនៃឯង» នោះហើយជា
បញ្ញត្តទី១ ៣១ ឯបញ្ញត្តទី២ ក៏បែបដូចគ្នា គឺថា
«ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»
គ្មានបញ្ញត្តណាទៀតធំជាងបទទាំង២នេះទេ
៣២ អាចារ្យនោះក៏ទូល ទ្រង់ថា មែនហើយ
លោកគ្រូ លោកមានប្រសាសន៍ត្រូវណាស់ថា
មានព្រះតែ១ ហើយក្រៅពីទ្រង់ គ្មានព្រះណា
ទៀតសោះ ៣៣ ហើយដែលស្រឡាញ់ទ្រង់
អស់ពីចិត្ត អស់ពីប្រាជ្ញា អស់ពីព្រលឹង និង
អស់ពីកំឡាំង ហើយដែលស្រឡាញ់អ្នកជិត
ខាងដូចខ្លួនឯង នោះវិសេសលើសជាងអស់
ទាំងដង្វាយដុត និងយញ្ញបូជាទាំងប៉ុន្មានទៅ
ទៀត ៣៤ កាលព្រះយេស៊ូវបានឃើញ ថា គាត់
ឆ្លើយដោយប្រាជ្ញា នោះក៏មានព្រះបន្ទូលទៅ
គាត់ថា អ្នកមិនឆ្ងាយពីនរគព្រះទេ រួចគ្មានអ្នក
ណាហ៊ានទូលសួរទ្រង់ទៀតឡើយ។

### ការស្វែងយល់

ការត្រាសហៅឲ្យស្រឡាញ់ព្រះ អស់ពីចិត្ត ព្រលឹង គំនិត និងកំឡាំងរបស់អ្នក គឺជាការត្រាស់ហៅឲ្យស្រឡាញ់ទ្រង់ ឲ្យអស់ពីអ្វីៗក្នុងជីវិតរបស់អ្នក។ ទោះបីជាមានការពន្យល់ន័យផ្សេងពីគ្នាដោយ ក៏គេអាចនិយាយបានម្យ៉ាងទៀតថា ចូរស្រឡាញ់ព្រះ ឲ្យអស់សេចក្តីស្រឡាញ់របស់យើង(ចិត្ត) ឲ្យអស់ពីជីវិត(ព្រលឹង) ឲ្យអស់ពីការគិត(គំនិត) និងអស់ពីថាមពល(កំឡាំង)របស់យើង។ ផ្នែកសំខាន់ៗទាំងបួននេះ ពិតជាជាតុផ្សំនៃអត្តសញ្ញាណរបស់យើង ហើយនាំឲ្យយើងយល់ អំពីរបៀបស្រឡាញ់ព្រះ ឲ្យបានពោរពេញ និងទាំងស្រុង។

សប្ដាហ៍ទី៤ ថ្ងៃអង្គារ

# កិច្ចការដែលនឹងមិនវិនាសដោយសារភ្លើង

សូមអាន
១កូរិនថូស ៣:៩-១៥

ភ្លើងនឹងសាកមើលការដែលនិមួយៗ ធ្វើ ឲ្យដឹងជាយ៉ាងណា។
-១កូរិនថូស ៣:១៣

ឪពុកក្មេករបស់ខ្ញុំបានចំណាយពេល ដើម្បីជួយប្រជាជននៅក្នុងវិស័យសុខាភិបាលសាធារណៈ អស់រយៈពេល៣០ឆ្នាំ។ ពេលដែលគាត់បានលាចាកលោក ទៅនគរស្ថានសួគ៌ ក្នុងជន្មាយុ៧៦ឆ្នាំ គាត់បានបន្សល់ទុកនូវឯកសារមួយទូ និងរង្វាន់ជាច្រើនពាសពេញលើជញ្ជាំងមួយ។ ដល់ពេញដែលយើងត្រូវសម្អាតទូដែលគាត់បានប្រើនៅក្នុង"កិច្ចការ"របស់គាត់ យើងក៏បានរក្សាទុករូបថតទាំងឡាយរបស់គ្រួសារ និងវត្ថុអនុស្សាវរីយ៍បន្តិចបន្តួច ហើយក្រៅពីនោះ យើងត្រូវយកចេញពីទូនោះទាំងអស់។ ខ្ញុំមានភារៈកិច្ចយកឯកសារទាំងនោះទៅបំផ្លាញចោល។ ខ្ញុំក៏បានជញ្ជូនឯកសារទាំងនោះ កាត់តាមជង្រុក ទៅកាន់ទីវាលមួយកន្លែង ហើយខ្ញុំក៏បានចាក់ប្រេងម៉ាស៊ូតដុតឯកសារដែលមានដូចជា ឯកសារគម្រោងចាស់ៗ ស្លាយសម្រាប់ធ្វើបទបង្ហាញ ប័ណ្ណសរសើរ សំបុត្រឆ្លើយឆ្លង។ ខ្ញុំបានឈរមើលឯកសារទាំងឆេះគ្មានសល់។

ពេលនោះ ខ្ញុំក៏បានទទួលនូវបទពិសោធន៍ ដែលធ្វើឲ្យខ្ញុំមានការប្រុងប្រយ័ត្ន ពេលដែលខ្ញុំគិតថា ថ្ងៃណាមួយ ពេលដែលខ្ញុំឈរនៅចំពោះព្រះ "កិច្ចការ"ទាំងអស់ដែលខ្ញុំបានធ្វើ នឹងត្រូវប្រឈមមុខនឹងភ្លើងដូចនេះផងដែរ។ មានតែរបស់អ្វីដែលអាចធន់នឹងភ្លើងប៉ុណ្ណោះ ដែលមានតម្លៃដ៏អស់កល្បជានិច្ច។ ការមើលសំបុត្រ និងក្រដាសគម្រោងទាំងនោះឆេះ រហូតដល់ក្លាយជាផេះ បាននាំឲ្យខ្ញុំមានការយល់ដឹងជាថ្មី អំពីបទគម្ពីរ ១កូរិនថូស ៣:១៣។ សាវ័កប៉ុលបានមានប្រសាសន៍ថា "ការដែលអ្នករាល់គ្នាធ្វើ នឹងលេចមកឲ្យឃើញ ដ្បិតថ្ងៃនោះនឹងបង្ហាញពីការនោះយ៉ាងច្បាស់លាស់ ព្រោះការនោះនឹងសំដែងចេញមកដោយសារភ្លើង ហើយភ្លើងនឹងសាកមើលការដែលនិមួយៗ ធ្វើឲ្យដឹងជាយ៉ាងណា"។

ការងារយើងធ្វើថ្ងៃនេះ នឹងត្រូវជួបនឹងភ្លើងដុតបញ្ចេះនៅថ្ងៃក្រោយ។

បទពិសោធន៍នៅក្នុងវាលស្មៅ នៅពេលរសៀលថ្ងៃនោះ បានធ្វើឲ្យខ្ញុំមានការប្រុងប្រយ័ត្នកាន់តែខ្លាំង និងមានការគិតកាន់តែល្អិតល្អន់ អំពីឱកាសបណ្ដោះអាសន្ន ដែលខ្ញុំត្រូវឆក់យកដើម្បីធ្វើកិច្ចការ ដែលមិនវិនាសដោយសារភ្លើង។ - David McCasland

*យើងគួរមានការព្រួយបារម្ភយ៉ាងខ្លាំង*
*ពេលបានដឹងថា កិច្ចការរបស់យើង នឹងត្រូវជួបការជំនុំជម្រះ*
*ប៉ុន្តែ បើយើងបានសម្រេចកិច្ចការថ្វាយព្រះគ្រីស្ទ*
*នោះកិច្ចការទាំងនោះ នឹងស្ថិតស្ថេរនៅ គឺមិនវិនាសដោយសារភ្លើងទេ។ - Hess*

---

**ចូររស់នៅក្នុងថ្ងៃនេះ ហាក់ដូចជា**
**អ្នកនឹងឈរនៅចំពោះព្រះ នៅថ្ងៃស្អែកចុះ**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ១កូរិនថូស ៣:៩-១៥

៩ ដ្បិតយើង រាល់គ្នាជាអ្នកធ្វើការជាមួយនឹង
ព្រះ ឯអ្នករាល់គ្នាជាស្រែដែលព្រះទ្រង់ភ្ជួរ
ហើយជាផ្ទះដែលព្រះទ្រង់ធ្វើ។

១០ ខ្ញុំ បានដាំជើងជញ្ជាំង ដូចជាមេជាងផ្ទះដ៏
ចំណាន តាមព្រះគុណដែលព្រះបានប្រទាន
មកខ្ញុំ មានម្នាក់ទៀតជាអ្នកសង់ពីលើ ប៉ុន្តែ
ត្រូវឲ្យមនុស្សប្រយ័ត្នរៀងខ្លួន អំពីបែបណា
ដែលសង់ពីលើជើងនោះ ១១ ដ្បិតគ្មានអ្នក
ណាអាននឹងដាំជើងជញ្ជាំងណាផ្សេងទៀត
ក្រៅពីជើងដែលបានដាំរួចហើយនោះបានទេ
គឺជាព្រះយេស៊ូវ គ្រីស្ទ ១២ បើអ្នកណាយក
មាស ប្រាក់ ត្បូង ឈើ ស្បូវ ឬស្លឹក ដើម្បីនឹង
ធ្វើពីលើជើងជញ្ជាំងនេះ ១៣ នោះការដែល
អ្នករាល់ គ្នាធ្វើ នឹងលេចមកឲ្យឃើញ ដ្បិតថ្ងៃ
នោះនឹងបង្ហាញពីការនោះយ៉ាងច្បាស់លាស់
ព្រោះការនោះនឹងសំដែងចេញមកដោយសារ
ភ្លើង ហើយភ្លើងនឹងសាកមើលការដែលនិមួ
យៗ ធ្វើ ឲ្យដឹងជាយ៉ាងណា ១៤ បើការដែល
អ្នកណាសង់ឡើងបានជាប់នៅ អ្នកនោះនឹង
បានរង្វាន់ ១៥ បើការដែលអ្នកណាធ្វើត្រូវឆេះ
អ្នកនោះនឹងត្រូវខាតវិញ តែខ្លួនអ្នកនោះនឹង
បានរួច បែបដូចជាដើរកាត់ភ្លើង។

## ការស្វែងយល់

ពួកជំនុំក្រុងកូរិនថូស មានទីតាំងនៅក្នុងទីក្រុងមួយរបស់នគរក្រិក នៅសម័យបុរាណ ដែលមានភាពល្បីល្បាញផ្នែកភោគទ្រព្យដ៏ច្រើនក្រៃលែង ។ ក្រុងនោះជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលចំណុចកណ្តាលនៃការធ្វើជំនួញ និងការដឹកជញ្ជូន ។ ដោយសារភាពសម្បូរសប្បាយ និងការរីកលូតលាសនៃទីក្រុងកូរិនថូស នោះបណ្តាជនដែលសាវ័កប៉ុលបានសរសេរសំបុត្រផ្ញើទៅនេះ ត្រូវគិតឲ្យបានល្អិតល្អន់អំពីការពិពណ៌នាអំពីសំណង់អាគារ និងគ្រឹះរបស់វា ។ ពួកគេមានបទពិសោធន៍ជាក់ស្តែង ជាមួយនឹងតម្លៃនៃលោហៈធាតុមានតម្លៃជាច្រើន ដែលមិនវិនាសដោយសារភ្លើង ដូចឈើ ស្បូវ និងចម្បើងឡើយ ។

សប្ដាហ៍ទី៤ ថ្ងៃពុធ

## នៅមានវគ្គបន្ត

សូមអាន
ហេព្រើ ១១:៨-១៦

ដ្បិតនៅស្ថាននេះ យើងរាល់គ្នាគ្មានទីក្រុងណា ដែលស្ថិតនៅជាប់ជានិច្ចទេ តែយើងកំពុងតែស្វែងរកក្រុងនោះដែលត្រូវមក។ - ហេព្រើ ១៣:១៤

តើលោកអ្នកចូលចិត្តមើលរឿង ដែលនៅមានវគ្គបន្តឬទេ? ឧបមាថា អ្នកកំពុងអានអត្ថបទមួយ ក្នុងទស្សនាវត្តី ឬទស្សនាកម្មវិធីទូរស្សន៍ អស់រយៈពេលកន្លះម៉ោង ហើយអ្នកក៏បានមើលដល់វគ្គ ដែលអ្នកក្លាហានលោតចូលក្នុងទឹក ដើម្បីជួយសង្គ្រោះសង្សារបស់ខ្លួន ដែលកំពុងលង់ទឹក ។ បន្ទាប់មក លោកអ្នកស្រាប់តែមានអារម្មណ៍អន្ទះសារ ពេលបានឃើញពាក្យ "សូមរង់ចាំទស្សនា(ឬអាន) វគ្គបន្ត"។ តើអ្នកមានការខកចិត្តប៉ុណ្ណា! ខ្ញុំមានការឆ្លើយតបខុសពីនេះ ចំពោះការឆ្លាក់អក្សរ នៅលើថ្មមុខផ្នូររបស់បងប្អូនរួមជំនឿម្នាក់ ដែលគេបានចារថា "នៅមានវគ្គបន្តទៀត នៅស្ថានលើ"។

ជាការពិតណាស់ ជីវិតរបស់យើងក្នុងលោកិយនេះ គឺគ្រាន់តែជាជំពូកទីមួយ នៃសៀវភៅជីវិតរបស់យើងប៉ុណ្ណោះ ។ ទោះបីជាជំពូកនោះវែងឬខ្លីក៏ដោយ ក៏ជំពូកនោះមិនមែនជាជំពូកចុងក្រោយទេ តែនៅមានវគ្គបន្តទៀត។ សម្រាប់អ្នកជឿព្រះ ជំពូកនៃជីវិតរបស់យើង មានវគ្គបន្តទៀតនៅនគរស្ថានសួគ៌ជាមួយព្រះអម្ចាស់ ។ បន្ទាប់ពីជំពូកទីមួយចប់ហើយ លោកអ្នកមិនចាំបាច់រង់ចាំមើលជំពូកទីពីរ នៅអាទិត្យក្រោយទេ ។ ជំពូកទីពីរនឹងបន្តពីជំពូកទីមួយភ្លាមៗ ដោយគ្មានការរំខានអ្វីឡើយ ។ ការបន្តចូរជំពូកថ្មីនេះ គឺកើតមានភ្លាមៗ ព្រោះ "កាលណាយើងចេញពីរូបកាយនេះទៅ នោះយើងនឹងនៅជាមួយនឹងព្រះអម្ចាស់"(២កូរិនថូស ៥:៨)។

តើជំពូកទីពីរនៃជីវិតរបស់អ្នកមានលក្ខណៈដូចម្ដេច? មិនយូរមិនឆាប់ វានឹងត្រូវបាននិពន្ធឡើង នៅក្នុងនគរស្ថានសួគ៌ ឬក្នុងស្ថាននរក ។ សូមចាំថា ពេលដែលអ្នកស្លាប់ មិនមែនជាពេលចុងក្រោយរបស់អ្នកទេ ។ រឿងនៃជីវិតរបស់អ្នកនឹង "នៅមានវគ្គបន្ត"ទៀត ប៉ុន្តែ តើបន្តនៅកន្លែងមួយណា? – M. R. De Haan

*ថ្ងៃបណ្ដោះអាសន្ននៃជីវិត នឹងត្រូវអស់ក្នុងពេលដ៏ឆាប់ខាងមុខ*
*នៅពេលដែលសេចក្ដីស្លាប់បញ្ចប់អ្វីគ្រប់យ៉ាង ដែលមានពីមុន*
*តែជីវិតក្នុងព្រះគ្រីស្ទនៅតែបន្តជានិច្ច*
*សម្រាប់អ្នកដែលរស់នៅតាមបំណងព្រះទ័យទ្រង់ ។ - D. De Haan*

**សេចក្ដីស្លាប់គឺជាជំពូកចុងក្រោយនៃពេលវេលា**
**តែជាជំពូកទីមួយ នៃពេលដ៏អស់កល្បជានិច្ច ។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ហេព្រើ ១១:៨-១៦

៨ ដោយសារ សេចក្តីជំនឿ កាលព្រះបានហៅ
លោកអ័ប្រាហាំ នោះលោកក៏បានស្តាប់បង្គាប់
លោកចេញទៅឯកន្លែង ដែលត្រូវទទួលជា
មរដក គឺចេញទៅឥតមានដឹងជាទៅឯណាទេ
៩ ដោយសារសេចក្តីជំនឿ នោះលោកបានស្នា
ក់នៅក្នុងស្រុក ដែលទ្រង់បានសន្យាឲ្យ ដូចជា
នៅប្រទេសដទៃ ក៏នៅតែក្នុងត្រសាល ជាមួយ
នឹងអ៊ីសាក ហើយនិងយ៉ាកុប ជាអ្នកគ្រងសេច
ក្តីសន្យាដដែល ទុកជាមរដកជាមួយគ្នា ១០ ពី
ព្រោះលោករង់ចាំក្រុង១ ដែលមានឫសជញ្ជាំង
ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់។
១១ ដោយសារ សេចក្តីជំនឿ នោះនាងសារ៉ាក៏
ទទួលអំណាច ឲ្យមានគភ៌បង្កើតកូនបាន
ហើយនាងបង្កើតកូនមក ក្នុងកាលដែលហួស
អាយុហើយ ពីព្រោះនាងបានរាប់ព្រះដែល
សន្យានោះ ទុកជាស្មោះត្រង់ ១២ ដូច្នេះ ក៏មាន
មនុស្ស១ហ្វូង ដូចផ្កាយនៅលើមេឃ ហើយ
ដូចខ្សាច់នៅមាត់សមុទ្រ ដែលរាប់មិនចេះអស់
បានកើតមកអំពីមនុស្សតែម្នាក់ ដែលអ្នកនោះ
ក៏ទុកដូចជាស្លាប់ហើយដែរ។
១៣ ពួក អ្នកទាំងនោះបានស្លាប់ក្នុងសេចក្តី
ជំនឿ ឥតទទួលសេចក្តីដែលបានសន្យាទាំង
ប៉ុន្មានទេ តែគេបានឃើញពីចំងាយ ហើយក៏
ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជា
អ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដី
ប៉ុណ្ណោះ ១៤ ពួកអ្នកដែលនិយាយដូច្នោះ នោះ
សំដែងថា គេជាអ្នករកស្រុកសំរាប់ខ្លួនគេពិត
១៥ ហើយបើសិនជាគេរឭកស្រុក ដែលគេទើប
នឹងចេញមកនោះ នោះគេនឹងមានឱកាសត្រ
ឡប់ទៅវិញបាន ១៦ តែឥឡូវនេះ គេសង្វាត
ចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌
វិញ បានជាព្រះទ្រង់គ្មានសេចក្តីខ្មាស ដោយ
គេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់
បានរៀបចំទីក្រុង១ឲ្យគេហើយ។

## ការស្វែងយល់

ជួនកាល គេហៅបទគម្ពីរហេព្រើ ជំពូក១១ ថា "សាលនៃសេចក្តីជំនឿ" ព្រោះបទគម្ពីរនេះបកស្រាយអំពីរបៀបដែលគ្រីស្ទបរិស័ទនៅសម័យដើមមួយចំនួន បានរស់នៅ ដោយជំនឿលើព្រះ។ ខ.៨-១៦ បានលើកឡើងអំពីជីវិតរបស់លោកអ័ប្រាហាំ និងនាងសារ៉ា។ លោកអ័ប្រាហាំបានស្តាប់បង្គាប់ព្រះអម្ចាស់ ពេលដែលទ្រង់នាំគាត់ទៅកាន់ទឹកដីថ្មី ហើយភរិយារបស់គាត់ គឺនាងសារ៉ាបានទុកចិត្តលើព្រះបន្ទូលសន្យារបស់ព្រះ ថានាងនឹងបានកូនប្រុសមួយ។

សប្តាហ៍ទី៤ ថ្ងៃព្រហស្បត្តិ៍

## លេបថ្នាំ

សូមអាន
អេសាយ ៥៥:១-៦

ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ។ - រ៉ូម ១០:១៣

ឧបមាថា អ្នកបានទៅមន្ទីពេទ្យយ៉ាងប្រញាប់ប្រញាល់ ហើយនៅទីនោះ គ្រូពេទ្យបានពិនិត្យមើលសុខភាពអ្នក ហើយក៏មានប្រសាសន៍ថា អ្នកមានជម្ងឺធ្ងន់ណាស់។ គាត់ថា អ្នកនឹងស្លាប់ជាមិនខាន បើសិនជាអ្នកមិនបានទទួលការព្យាបាលឲ្យបានត្រឹមត្រូវទេនោះ។ បន្ទាប់មកគាត់ក៏បានចេញវេជ្ជបញ្ជា ហើយប្រាប់អ្នកថា "បើអ្នកញ៉ាំថ្នាំនេះ ខ្ញុំសូមធានាថា អ្នកនឹងមានសុខភាពល្អឡើងវិញជាមិនខាន"។

ឥឡូវនេះ តើអ្នកគួរធ្វើអ្វី? តើអ្នកគួរតែបន្តដេកនៅលើគ្រែអ្នកជម្ងឺ ដោយគ្រាន់តែជឿថា វេជ្ជបណ្ឌិតនោះបានពិនិត្យ ជម្ងឺយ៉ាងត្រឹមត្រូវ ហើយវេជ្ជបញ្ជារបស់គាត់ ពិតជានឹងធ្វើឲ្យអ្នកមានសុខភាពល្អឡើងវិញមែនឬ?

ទេ បើគ្រាន់តែដេកជឿនោះ នោះគឺមិនទាន់គ្រប់គ្រាន់ទេ។ ដើម្បីមានជីវិតរស់តទៅទៀត អ្នកត្រូវលេបថ្នាំ។ សេចក្តីសង្គ្រោះក៏យ៉ាងដូចនេះដែរ។ អ្នកអាចជឿលើគ្រប់ទាំងសេចក្តីដែលព្រះគម្ពីរបានចែងអំពីព្រះគ្រីស្ទ គឺជឿថា ទ្រង់បានសុគតដើម្បីលោះបាបអ្នក ហើយមានព្រះជន្មរស់ឡើងវិញ។ តែបើអ្នកបដិសេធមិនព្រម "ទទួលទ្រង់"ទេ (មានន័យថា បើអ្នកមិនជឿលើទ្រង់ និងលើកិច្ចការដែលទ្រង់បានធ្វើនៅឈើឆ្កាងជំនួសអ្នកទេ) នោះអ្នកនៅតែវង្វេងដដែល គឺមិនខុសពីការបដិសេធព្រះយេស៊ូវ ដោយបើកចំហរ និងដោយគ្មានការខ្មាសអៀនទេ។

សេចក្តីជំនឿដែលនាំឲ្យបានសេចក្តីសង្គ្រោះ គឺមិនគ្រាន់តែជាការទទួលស្គាល់ថា សេចក្តីដែលបានចែងពីព្រះយេស៊ូវ គឺជាសេចក្តីពិតប៉ុណ្ណោះទេ។ វាក៏ជាការទទួលការលោះបាបពីព្រះដោយផ្ទាល់ៗខ្លួន។ វាជាការអនុញ្ញាតឲ្យព្រះសម្រេចជោគវាសនានៃវិញ្ញាណរបស់អ្នក អស់កល្បជានិច្ច។ វាជាការនិយាយថា "ឲ្យព្រះអម្ចាស់យេស៊ូវអើយ សូមសង្គ្រោះទូលបង្គំ។ ទូលបង្គំជឿថា ទ្រង់អាចសង្គ្រោះទូលបង្គំ ហើយទ្រង់នឹងជួយសង្គ្រោះទូលបង្គំ"។ នោះហើយជាការ "លេបថ្នាំ"ឲ្យជាពីជម្ងឺ ដែលប្រៀបបាននឹងការទទួលព្រះយេស៊ូវជាម្ចាស់គ្រងរាជ្យលើចិត្ត ដើម្បីឲ្យបានសង្គ្រោះនោះ។ តើអ្នកបានទទួលទ្រង់ហើយឬនៅ? បើមិនទាន់ទទួលទេ សូមទទួលទ្រង់នៅពេលនេះចុះ។ - Richard De Haan

*សូមពិចារណាអំពីសេចក្តីនេះចុះ*
*តើអ្នកបានលេបថ្នាំ ដែលព្យាបាលជម្ងឺនៃអំពើបាប នៅក្នុងលោកិយហើយឬនៅ?*
*មានតែការប្រោសលោះរបស់ព្រះទេ ដែលមានប្រសិទ្ធិភាព។*
*តែមានមូលហេតុអ្វីដែលអ្នកមិនគួរទូលសូមឲ្យព្រះយេស៊ូវជួយសង្គ្រោះអ្នកទេ?*

**សេចក្តីជំនឿគឺមិនគ្រាន់តែជាការជឿថា ព្រះយេស៊ូវអាចសង្គ្រោះប៉ុណ្ណោះទេ**
**តែជាការទូលសូមឲ្យទ្រង់ជួយអ្នក។**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ អេសាយ ៥៥:១-៦

១ ហើយ អស់អ្នកដែលស្រេកអើយ ចូរមកឯទី
ទឹកចុះ ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ
ហើយបរិភោគទៅ អើ ចូរមកទិញស្រាទំពាំង
បាយជូរ និងទឹកដោះគោឥតបង់លុយ ឥតថ្លៃ
ទេ ២ ហេតុអ្វីបានជាចាយ ប្រាក់ឲ្យ បានតែ
របស់ដែលមិនមែនជាអាហារ ហើយបង់កំ
ឡាំង ឲ្យបានតែរបស់ដែលមិនស្កប់ចិត្តដូច្នេះ
ចូរស្តាប់តាមអញឲ្យអស់ពីចិត្តចុះ នោះឯងនឹង
បានបរិភោគយ៉ាងឆ្ងាញ់ ដើម្បីឲ្យព្រលឹងឯង
បានស្កប់ស្កល់ ដោយម្ហូបយ៉ាងថ្លៃវិសេស ៣ ចូរ
ឱនត្រចៀក ហើយមកឯអញ ចូរស្តាប់ចុះ នោះ
ព្រលឹងឯងនឹងបានរស់នៅ ហើយអញនឹងតាំង
សេចក្តីសញ្ញានឹងឯងរាល់គ្នា ជាសញ្ញាដ៏នៅ
អស់កល្បជានិច្ច គឺជាសេចក្តីមេត្តាករុណា
ស្មោះត្រង់ ដែលបានផ្តល់ដល់ដាវីឌ ៤ មើល
អញបានតាំងដាវីឌទុកជាទីបន្ទាល់ដល់ប្រជា
ជាតិទាំងឡាយ គឺជាអ្នកនាំមុខ ហើយជាអ្នក
បង្គាប់ដល់គេ ៥ មើល ឯងនឹងហៅសាសន៍១
ដែលឯងមិនបានស្គាល់ ហើយសាសន៍១ដែល
មិនបានស្គាល់ឯង គេនឹងរត់មកឯឯង ដោយ
ព្រោះព្រះយេហូវ៉ាជាព្រះនៃឯង គឺជាព្រះដ៏
បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ដ្បិតទ្រង់បាន
លើកដំកើងឯងហើយ។
៦ ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាច
នឹងរកទ្រង់ឃើញ ហើយអំពាវនាវដល់ទ្រង់
ក្នុងកាលដែលទ្រង់គង់នៅជិតចុះ។

## ការស្វែងយល់

លោកប្លែស៍ បាស្កាល់(១៦២៣-១៦៦២) ដែលជារូបវិទូ និងទស្សនវិទូជនជាតិបារាំង បាននិយាយថា នៅក្នុងចិត្តរបស់មនុស្សម្នាក់ៗ គឺមានភាពចន្លោះទទេ ដែលព្រះបានបង្កើតមក ហើយមានតែព្រះទេដែលអាចបំពេញភាពចម្លោះទទេនោះបាន។ ពាក្យរបស់គាត់ពិតជាត្រឹមត្រូវតាមបទគម្ពីរខាងលើ។ ភាពមានតែការស្គាល់ព្រះអទិករ ដែលបានបង្កើត និងស្រឡាញ់យើងប៉ុណ្ណោះ ដែលអាចបំបាត់ភាពស្រេកឃ្លាននៅក្នុងចិត្តមនុស្សបាន។ ហេតុនេះហើយ បានជាព្រះយេស៊ូវបានមានបន្ទូលថា "មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត"(ម៉ាថាយ ៥:៦)។

សប្ដាហ៍ទី៤ ថ្ងៃសុក្រ

## មានសម្រាប់អ្នក ពេលដែលអ្នកត្រូវការវា

សូមអាន
ហេព្រើ ៩:១១-២២

ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់។
- ១យ៉ូហាន ១:៧

ពេលដែលខ្ញុំបានទៅបរិច្ចាកឈាម កាលពីពេលកន្លងទៅគិលានុបដ្ឋាយិកាម្នាក់បានឲ្យខ្ញុំអានកាតមួយសន្លឹក នៅពេលដែលឈាមពណ៌ក្រហមដ៏មានតម្លៃរបស់ខ្ញុំ កំពុងហូរចេញពីសសៃឈាមរបស់ខ្ញុំ។ ការនេះបានបង្ហាញអំពីភាគរយនៃអ្នក ដែលមានប្រភេទឈាមខុសគ្នា។ ភាគរយនោះមានដូចខាងក្រោមនេះ៖

- ឈាម O Positive ……………37.4%
- ឈាម A Positive……………35.7%
- ឈាម A Negative……………6.3%
- ឈាម B Negative……………1.5%

ប្រភេទឈាមដែលគេកម្រមានបំផុត គឺ AB Negative ដែលក្នុងចំណោមមនុស្ស១៦៧នាក់ មានតែម្នាក់ប៉ុណ្ណោះដែលមានឈាមប្រភេទនេះ ឬ០.៦%នៃចំនួនមនុស្សសរុបមានឈាមប្រភេទនេះ។ បន្ទាប់មក ខ្ញុំក៏ឃើញពាក្យដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងកាតនេះ ដែលគេបានសរសេរថា "ប្រភេទឈាមដែលកម្របំផុត គឺជាប្រភេទឈាម ដែលអ្នករកមិនបាន ពេលអ្នកត្រូវការវា"។

ពាក្យនេះបានរំឭកខ្ញុំ អំពីការបរិច្ចាកឈាមមួយប្រភេទ ដែលជាទង្វើដ៏សប្បុរស ដែលតែងតែត្រូវបានផ្ដល់ឲ្យជានិច្ចដល់អ្នកដែលសូម។ បទគម្ពីរ១យ៉ូហាន ១:៧ បានចែងថា "ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់"។ មានតែការសុគតនៃព្រះយេស៊ូវ ដោយការខ្ចាយព្រះលោហិតរបស់ទ្រង់ទេ ដែលបានបំពេញតាមការតម្រូវរបស់ព្រះ ដោយបង់ថ្លៃលោះបាបយើង(ហេព្រើ ៩:១២,២២)។ ឥឡូវនេះ អ្នកណាដែលស្រែកអំពាវរកព្រះ ដោយសេចក្ដីជំនឿ ដោយប្រែចិត្តចេញពីអំពើបាប ហើយទូលសូមឲ្យទ្រង់អត់ទោសបាបឲ្យ នោះព្រះនឹងឆ្លើយតបចំពោះការអធិស្ឋានទូលសូមសេចក្ដីសង្គ្រោះរបស់អ្នកនោះ។

ខ្ញុំសូមអរព្រះគុណព្រះយេស៊ូវយ៉ាងខ្លាំង ដែលបានស្ម័គ្រចិត្តសុគតនៅលើឈើឆ្កាង ដោយប្រទានព្រះលោហិតទ្រង់ដល់ខ្ញុំ ដើម្បីឲ្យខ្ញុំបានទទួលការអត់ទោសបាប តាមសេចក្ដីត្រូវការរបស់ខ្ញុំ។ តើអ្នកមិនអរព្រះគុណទ្រង់ផងដែរទេឬ? – Dave Egner

*ឱព្រះអម្ចាស់អើយ ទូលបង្គំជឿថា ព្រះលោហិតដ៏ថ្លៃវិសេសនៃទ្រង់*
*ដែលនៅឯបល្ល័ង្កនៃសេចក្ដីមេត្តាករុណារបស់ទ្រង់*
*តែងតែបានធ្វើសម្រាប់មនុស្សមានបាបដែលបានទូលអង្វរ*
*គឺបានធ្វើសម្រាប់វិញ្ញាណទូលបង្គំ និងសម្រាប់គេគ្រប់គ្នាផង។ -Von Zinzendorf*

---

**ព្រះយេស៊ូវទទួលអំពើបាបយើង ហើយប្រទានសេចក្ដីសង្គ្រោះដល់យើង**

## បទគម្ពីរសម្រាប់អាន ក្នុងថ្ងៃនេះ ហេព្រើ ៩:១១-១២,១៥-២២

១១ ប៉ុន្តែ កាលព្រះគ្រីស្ទបានយាងមក ធ្វើជាសំ
ដេចសង្ឃ ខាងឯសេចក្តីល្អដែលត្រូវមក គឺធ្វើ
ដោយសាររោងឧបោសថដ៏វិសេសជាង ហើយ
គ្រប់លក្ខណ៍ជាង ដែលមិនបានធ្វើដោយដៃ គឺ
ថាមិនមែនជារបស់ផងលោកីយ៍នេះទេ
១២ នោះទ្រង់បានយាងចូល ទៅក្នុងទីបរិសុទ្ធ
បំផុត១ដងជាសំរេច ទាំងបានសេចក្តីប្រោស
លោះ នៅអស់កល្បជានិច្ច មិនមែនដោយយក
ឈាមពពែឈ្មោល ឬឈាមកូនគោទេ គឺដោយ
យកព្រះលោហិតនៃអង្គទ្រង់វិញ។
១៥ ដោយហេតុនោះបានជា ទ្រង់ជាអ្នកកណ្តា
លនៃសញ្ញាថ្មី ដើម្បីឲ្យពួកអ្នកដែលទ្រង់ហៅ
បានទទួលសេចក្តីសន្យា ទុកជាមរដកដ៏នៅ
អស់កល្បជានិច្ច ដោយទ្រង់សុគត ប្រយោជន៍
នឹងប្រោសលោះគេ ឲ្យរួចពីការរំលង ដែលគេ
ប្រព្រឹត្តពីកាលនៅក្រោមសញ្ញាចាស់នៅឡើយ
១៦ ដ្បិតដែលមានសំបុត្រសញ្ញាចែកមរដក
នោះត្រូវដល់ម្ចាស់សំបុត្រស្លាប់ទៅសិន ទើប
ចែកបាន ១៧ ពីព្រោះសំបុត្រសញ្ញានោះមាន
ប្រយោជន៍តែកាលណាម្ចាស់បានស្លាប់ទៅ
ហើយទេ កាលម្ចាស់កំពុងរស់នៅឡើយ នោះ
គ្មានអំណាចសោះ ១៨ ដូច្នេះ សេចក្តីសញ្ញា
ចាស់ក៏មិនបានតាំងឡើង ដោយឥតឈាមដែរ
១៩ ពីព្រោះ កាលលោកម៉ូសេបានមានប្រសា-
សន៍ ប្រាប់ពីបញ្ញត្តទាំងប៉ុន្មាន តាមក្រឹត្យវិន័យ
ដល់ប្រជាជនទាំងឡាយហើយ នោះលោកក៏
យកឈាមកូនគោ និងឈាមពពែ ព្រមទាំង
ទឹក និងរោមចៀមជ្រលក់ក្រហម ហើយនិង
មែកហ៊ីសុប មកប្រោះលើគម្ពីរនោះឯង ព្រម
ទាំងលើប្រជាជនទាំងអស់ដែរ ២០ ដោយមាន
ប្រសា-សន៍ថា «នេះជាឈាមនៃសញ្ញា ដែល
ព្រះទ្រង់បង្គាប់មកអ្នករាល់គ្នា» ២១ លោកក៏
ប្រោះឈាមទៅលើរោងឧបោសថ និងគ្រឿង
ប្រដាប់ដែលសំរាប់ការងារទាំងប៉ុន្មានបែប
ដូច្នោះដែរ ២២ ហើយតាមក្រឹត្យវិន័យ សឹងតែ
គ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម
បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឲ្យបាន
រួចពីបាបឡើយ។

## ការស្វែងយល់

អ្នកប្រហែលជាមិនដែលបានឃើញ ពាក្យ *មតកសាសន៍* និងពាក្យ *អ្នកធ្វើមតកសាសន៍* ទេ។ មតកសាសន៍គឺពាក្យបណ្តាំ ដែលបង្ហាញពីឆន្ទៈ ឬបំណងចិត្ត មុនពេលស្លាប់ ហើយអ្នកធ្វើមតកសាសន៍ គឺជាអ្នកដែលសម្រេចឲ្យអនុវត្តតាមពាក្យបណ្តាំនោះ នៅពេលខ្លួនបានស្លាប់ទៅ។

ទំព័រពិសេសនៅថ្ងៃអាទិត្យ

## មូលហេតុទាំង១០យ៉ាង ដែលត្រូវមានជំនឿលើព្រះគ្រីស្ទ

### ១. ភាពអាចជឿជាក់បាននៃស្ថាបនិករបស់សេចក្តីជំនឿនេះ

ព្រះគ្រីស្ទមានបន្ទូលថា ទ្រង់បានយាងមកពីនគរស្ថានសួគ៌ ដើម្បីសុគតជំនួសបាបយើងរាល់គ្នា ហើយដើម្បីនាំអ្នកដែលជឿលើទ្រង់ ទៅឯព្រះវរបិតាទ្រង់។ តាមការត្រិះរិះរកហេតុផល យើងអាចដឹងថា បើទ្រង់មិនមែនជាព្រះអម្ចាស់នៃនគរស្ថានសួគ៌ទេ នោះទ្រង់គឺជាមនុស្សកុហក់ ឬមនុស្សវិកលចរិកហើយ។ សិស្សរបស់ទ្រង់បានឃើញការអស្ចារ្យរបស់ទ្រង់ បានស្តាប់ទ្រង់បង្រៀន បានសង្កេតមើលឃើញភាពគ្រប់លក្ខណ៍របស់ទ្រង់ បានឃើញទ្រង់សុគតយ៉ាងវេទនា ហើយក៏បានឃើញទ្រង់ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញផងដែរ។ ពួកគេបានធ្វើការសន្និដ្ឋានថា "យើងខ្ញុំក៏បានជឿ ហើយដឹងថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ពិត"(យ៉ូហាន ៦:៦៩)។

### ២. ភាពអាចពឹងផ្អែកបាននៃព្រះគម្ពីររបស់គ្រីស្ទបរិស័ទ

ព្រះគម្ពីរត្រូវបាននិពន្ធក្នុងអំឡុងពេលជាង១៦០០ឆ្នាំ ដោយអ្នកនិពន្ធ ៤០នាក់ ហើយព្រះគម្ពីរបានពិពណ៌នាអំពីរឿងមួយ ដែលចាប់ផ្តើម ដោយនិយាយអំពីការបង្កើត ហើយបញ្ចប់ទៅវិញ ដោយនិយាយអំពីការដែលនឹងកើតឡើងក្នុងពេលដ៏អស់កល្បជានិច្ច។ គេអាចជឿជាក់លើការកត់ត្រាអំពីប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ក្នុងព្រះគម្ពីរ ព្រោះមានការបញ្ជាក់ ដោយភស្តុតាងផ្នែកបុរាណវត្ថុវិទ្យា។ តាមរយៈក្រាំងសមុទ្រស្លាប់ ដែលគេបានរកឃើញនៅតំបន់គមរ៉ាន (Qumran) យើងក៏អាចដឹងដែរថា ការកត់ចម្លងព្រះគម្ពីរ និងការផ្ទេរព្រះគម្ពីរពីសម័យមួយទៅសម័យមួយ មានភាពត្រឹមត្រូវច្បាស់លាស់។

### ៣. ការពន្យល់ក្នុងជំនឿគ្រីស្ទបរិស័ទ អំពីជីវិត

សាសនាទាំងអស់ សុទ្ធតែបានព្យាយាមពន្យល់អំពីអត្ថន័យ នៃការចាប់កំណើតរបស់យើងនៅក្នុងពិភពលោកនេះ អំពីការដែលយើងស្រេកឃ្លានចង់រស់ឲ្យមានន័យ អំពីបញ្ហានៃការឈឺចាប់ និងអំពីភាពមិនអាចជៀសវាងបាននៃសេចក្តីស្លាប់។ សាសនាទាំងអស់សុទ្ធតែខំព្យាយាមពន្យល់ថា ជីវិតរបស់មនុស្សម្នាក់ៗ ត្រូវបានរៀបចំមកឲ្យស្របតាមការរចនានៃលោកធាតុ (សកលលោក ឬចក្រវាល)។ ប៉ុន្តែ ព្រះគ្រីស្ទទ្រង់បានបើកបង្ហាញឲ្យយើងដឹង អំពីព្រះវរបិតាដែលបានជ្រាប់អំពីសត្វចាបណាមួយ ដែលធ្លាក់ទៅដី ហើយក៏បានជ្រាបអំពីចំនួនសរសៃសក់នៅលើក្បាលរបស់យើងផងដែរ(ម៉ាថាយ ១០:២៩-៣១)។ ទ្រង់ជាព្រះដែលបានបង្ហាញឲ្យយើងដឹង ថាទ្រង់យកព្រះទ័យទុកដាក់យ៉ាងណា ចំពោះស្នាព្រះហស្តរបស់ទ្រង់។ ព្រះគ្រីស្ទបានយកកំណើតជាមនុស្ស ដើម្បីមានអារម្មណ៍ដូចយើងដែរ ហើយបន្ទាប់មក ទ្រង់បានរងទុក្ខ និង

សុគតជំនួសយើងរាល់គ្នា។

## ៤. ការបន្តនៃសេចក្ដីជំនឿរបស់គ្រីស្ទបរិស័ទពីអតីតកាល

អ្នកដែលជឿព្រះគ្រីស្ទ ក៏កំពុងតែទទួលជឿព្រះអទិករ និងព្រះអម្ចាស់ ដែលអ័ដាំ អ័ប្រាហាំ នាងសារ៉ា និងស្ដេចសាឡូម៉ូនបានថ្វាយបង្គំផងដែរ។ ជំនឿរបស់គ្រីស្ទបរិស័ទមិនមែនជាសាសនាដែលព្រះគ្រីស្ទបានបង្កើតថ្មីនោះទេ។ ព្រះគម្ពីរចែងអំពីរឿងតែមួយ ចាប់តាំងពីកណ្ឌលោកុប្បត្តិ រហូតដល់កណ្ឌវិវរណៈ។ គឺរឿងរបស់ទ្រង់ ក៏ដូចជារឿងរបស់យើងរាល់គ្នា(កិច្ចការ ២:២២-៣៩ ១កូរិនថូស ១៥:១-៨)។

"បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងពីដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ... ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្ដីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ ហើយថា ទ្រង់បានលេចមកឲ្យកេផាសឃើញ រួចដល់ពួក១២នាក់ដែរ ក្រោយទៀត ទ្រង់លេចមកឲ្យពួកបងប្អូនជាង៥០០នាក់ឃើញតែម្ដង ជាពួកដែលមានគ្នាច្រើនរស់នៅ ដរាបដល់សព្វថ្ងៃនេះ តែមានខ្លះបានដេកលក់ទៅហើយ"(១កូរិនថូស ១៥:១-៦)

## ៥. ការអះអាងរបស់ជំនឿគ្រីស្ទបរិស័ទ មានមូលដ្ឋានគ្រឹះ

គ្រីស្ទបរិស័ទដំបូង គឺជាសាក្សីដែលបានហ៊ានប្រឈមនឹងសេចក្ដីស្លាប់ ដើម្បីប្រាប់ដល់លោកិយថា ពួកគេបានឃើញបុរសដ៏ស្លូតត្រង់(ព្រះគ្រីស្ទ)ម្នាក់ស្លាប់ ហើយក៏បានមានព្រះជន្មឡើងវិញ នៅថ្ងៃទី៣ ដោយការអស្ចារ្យ(កិច្ចការ ៥:១៧-៤២)។

ពួកគេបានធ្វើបន្ទាល់ថា ព្រះយេស៊ូវត្រូវបានគេចាប់ឆ្កាង នៅក្នុងស្រុកដែលស្ថិតក្រោមការគ្រប់គ្រង របស់លោកប៉ុនទាសពីឡាត់ដែលជាជនជាតិរ៉ូម៉ាំង។ សពទ្រង់ត្រូវគេបញ្ចុះនៅក្នុងផ្នូរដែលគេបានគ្របពីខាងក្រៅ។ គេបានឲ្យពួកទាហាននៅយាមមាត់ផ្នូរ ដើម្បីការពារមិនឲ្យមានអ្នកមកលួចព្រះសពទ្រង់។ តែបីថ្ងៃក្រោយមក ផ្នូរក៏បាននៅទទេ ហើយបន្ទាប់ពីទ្រង់បានមានព្រះជន្មឡើងវិញ ពួកសាក្សីដែលបានឃើញទ្រង់ បានហ៊ានប្រឈមមុននឹងសេចក្ដីស្លាប់ ដើម្បីប្រកាសថា ទ្រង់ជាព្រះដ៏រស់។

## ៦. ជំនឿគ្រីស្ទបរិស័ទ មានអំណាចធ្វើឲ្យជីវិតផ្លាស់ប្រែ

មិនមែនមានតែពួកសាវ័កដំបូងប៉ុណ្ណោះទេ ដែលមានជីវិតផ្លាស់ប្រែភ្លាមៗនោះ។ សាវ័កប៉ុល ដែលធ្លាប់ជាសត្រូវដ៏អាក្រក់បំផុតរបស់ពួកគេ ត្រូវបានធ្វើឲ្យមានជីវិតផ្លាស់ប្រែផងដែរ។ កាលពីមុន គាត់ជាអ្នកសម្លាប់គ្រីស្ទបរិស័ទ តែបានផ្លាស់ប្រែទៅជាអ្នកឈាមមុខម្នាក់ នៅក្នុងចំណោមអ្នកឈាមមុខទាំងឡាយរបស់ពួកគេ(កាឡាទី ១:១១-២៤)។ ក្រោយមក សាវ័កប៉ុលក៏

បានសរសេរអំពីអំណាចដែលជំនឿគ្រីស្ទបរិស័ទអាចធ្វើឲ្យជីវិតផ្លាស់ប្រែ យ៉ាងដូចនេះថា "តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកអ្នកសំរេចកិច្ចដោយខ្លួនឯង ពួកលេងកូនជឹង ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះដៀល និងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ ឯពួកអ្នករាល់គ្នាខ្លះ ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះដែរ តែបានលាងស្អាតហើយ ក៏បានញែកជាបរិសុទ្ធ ហើយរាប់ជាសុចរិតផង ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា"(១កូរិនថូស ៦:៩-១១)។

ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ(១ធីម៉ូថេ ១:១៥)។

## ៧. ការវិភាគតាមជំនឿរបស់គ្រីស្ទបរិស័ទ អំពីនិស្ស័យរបស់មនុស្ស

មានមនុស្សជាច្រើនចង់ជឿថា បញ្ហាដែលយើងមាន គឺមានប្រភពមកពីភាពល្ងង់ខ្លៅ ចំណីអាហារ និងរដ្ឋាភិបាល។ ប៉ុន្តែ ព្រះយេស៊ូវបានបង្ហាញឲ្យយើងដឹងថា បញ្ហាទាំងឡាយ គឺបណ្តាលមកពីអំពើបាប នៅក្នុងចិត្តរបស់យើងទេ។ "ដ្បិតគឺពីក្នុងចិត្ត នោះឯងដែលចេញអស់ទាំងគំនិតអាក្រក់ គឺការកាប់សំឡាប់គេ ផិតគ្នា សហាយស្មន់ លួចប្លន់ ធ្វើបន្ទាល់ក្លែងក្លាយ ហើយនិងជេរប្រមាថ សេចក្តីទាំងនោះ ទើបធ្វើឲ្យមនុស្សស្មោកគ្រោកមែន តែដែលបរិភោគឥតលាងដៃ នោះមិនមែនធ្វើឲ្យស្មោក គ្រោកទេ"(ម៉ាថាយ ១៥:១៩-២០)។

## ៨. ទស្សនៈតាមជំនឿគ្រីស្ទបរិស័ទ អំពីស្នាដៃរបស់មនុស្សជាតិ

មនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត បានសង្ឃឹមថា ខ្លួននឹងបានធ្វើកិច្ចការដែលល្អបំផុត។ យើងបានប្រយុទ្ធនៅក្នុងសង្គ្រាមលោក ដើម្បីបញ្ចប់សង្គ្រាមនោះ។ យើងបានបង្កើតទ្រឹស្តីផ្នែកអប់រំ ដើម្បីជួយឲ្យកុមារមានចំណេះដឹងជ្រៅជ្រះ និងគ្មានអំពើហឹង្សា។ យើងរកឃើញបច្ចេកវិទ្យាដែលនឹងជួយឲ្យការរស់នៅរបស់យើងកាន់តែមានភាពងាយស្រួល។ ទោះបីជាមនុស្សជាតិមានសេចក្តីសង្ឃឹមនិងការប្រឹងប្រែងខ្លាំងប៉ុណ្ណាក៏ដោយ ក៏លោកិយនេះ នៅតែកំពុងធ្វើដំណើរជិតដល់គ្រាចុងក្រោយ តាមបទទំនាយ ដែលមានចែងក្នុងបទគម្ពីរ(ម៉ាថាយ ២៤:៥-៣១ ២ធីម៉ូថេ ៣:១-៥)។

## ៩. ឥទ្ធិពលដែលជំនឿគ្រីស្ទបរិស័ទមានមកលើសង្គម

ជាងឈើមួយរូបដែលមកពីស្រុកណាសារែត បានធ្វើឲ្យពិភពលោកមានការផ្លាស់ប្តូរ។ ប្រតិទិន និងការចុះកាលបរិច្ឆេទនៅក្នុងឯកសារ គឺសុទ្ធតែប្រើប្រព័ន្ធនៃថ្ងៃខែឆ្នាំ ដែលរាប់ចាប់ពី

ថ្ងៃដែលទ្រង់ប្រសូត្រ ដែលនេះជាសាក្សីបញ្ជាក់អំពីការប្រសូត្ររបស់ទ្រង់។ ក្រមសីលធម៌របស់គ្រីស្ទបរិស័ទ បានក្លាយជាមូលដ្ឋានគ្រឹះនៃក្រមសីលធម៌របស់សង្គម ការងារ និងអង្គការមនុស្សធម៌ជាច្រើន។

## ១០. សេចក្តីសង្គ្រោះដែលត្រូវបានផ្តល់ឲ្យ នៅក្នុងជំនឿគ្រីស្ទបរិស័ទ

សេចក្តីជំនឿនៃគ្រីស្ទបរិស័ទបានផ្តល់ឲ្យនូវការអត់ទោសបាប និងការក្លាយជាសមាជិកនៃមហាគ្រួសាររបស់ព្រះ ដោយទទួលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ(រ៉ូម ១០:៩-១៣)។ យើងបានទទួលសេចក្តីសង្គ្រោះ ពីព្រះយេស៊ូវ មិនមែនដោយសារការអ្វីដែលយើងធ្វើថ្វាយទ្រង់នោះទេ ប៉ុន្តែ គឺដោយសារយើងបានទទួលស្គាល់ការអ្វីដែលទ្រង់បានធ្វើសម្រាប់យើង។ សេចក្តីសង្គ្រោះនេះ តម្រូវឲ្យយើងទទួលស្គាល់ថា ខ្លួនមានបាប ហើយទទួលស្គាល់ថា យើងមិនអាចជួយខ្លួនឯងបានទេ(អេភេសូ ២:៨-១០)។

## មិនមែនមានតែអ្នកទេដែលមានបញ្ហានេះ

បើសិនជាអ្នកនៅតែមិនទាន់យល់អំពីហេតុផល ដែលត្រូវជឿលើព្រះគ្រីស្ទ នោះមិនមែនមានតែអ្នកទេដែលមានបញ្ហានេះ។ តែសូមចាំថា ព្រះយេស៊ូវបានអះអាងដល់យើងថា យើងមិនចាំបាច់ត្រូវបំបាត់ចម្ងល់ទាំងនោះ ដោយខ្លួនឯងឡើង។ ទ្រង់បានមានបន្ទូលថា "បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ"(យ៉ូហាន ៧:១៧)។

បើអ្នកពិតជាបានយល់ច្បាស់ អំពីមូលហេតុដែលត្រូវជឿលើព្រះគ្រីស្ទហើយ នោះព្រះគម្ពីរបានសន្យា "អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ"(យ៉ូហាន ១:១២)។ សេចក្តីសង្គ្រោះដែលព្រះយេស៊ូវប្រទាន មិនមែនជារង្វាន់ដែលយើងត្រូវទទួល ដោយសារយើងបានខិតខំធ្វើល្អនោះទេ តែជាអំណោយ សម្រាប់អស់អ្នកដែលបានជឿទ្រង់។

### សម្រាប់ការអានបន្ថែម សូមអាន:

ហេតុអ្វីបានជាព្រះគ្រីស្ទត្រូវតែសុគត?

## ការធ្វើឲ្យមានលក្ខណៈផ្ទាល់ខ្លួន

មនុស្សយើងអាចមានភាពជិតស្និទ្ធចំពោះព្រះគ្រីស្ទ តែទន្ទឹមនឹងនោះ យើងក៏អាចមានជីវិតរស់នៅ ដែលខុសពីបំណងព្រះទ័យទ្រង់យ៉ាងខ្លាំង។ បញ្ហានេះ ក៏បានកើតមាននៅក្នុងចំណោមពួកសិស្សទាំង១២នាក់ដំបូងរបស់ទ្រង់ផងដែរ។ សូម្បីតែនៅក្នុងចំណោមពួកគេ មានមនុស្សម្នាក់ ដែលអាចជាសមាជិកដែលគេបានទុកចិត្តបំផុត(ព្រោះគាត់ជាអ្នកកាន់លុយ) តែគាត់មិនដែលមានទំនាក់ទំនងផ្ទាល់ខ្លួនដ៏ជិតស្និទ្ធ ជាមួយព្រះគ្រីស្ទទេ។ យូដាសមានការយល់ដឹងជាច្រើនអំពីព្រះយេស៊ូវ។ គាត់បានដឹងអំពីទម្លាប់របស់ព្រះយេស៊ូវដែលជាគ្រូរបស់គាត់ គឺបានដឹងច្បាស់ល្អម នឹងអាចនាំសត្រូវរបស់ទ្រង់ ឲ្យមកចាប់ទ្រង់នៅក្នុងកន្លែងជួបគ្នា នៅក្នុងសួនច្បារ។ គាត់បានស្គាល់ព្រះយេស៊ូវច្បាស់ល្អមនឹងអាចក្បត់ទ្រង់ ដោយការថើបជម្រាបសួរ។ តែយូដាសមិនទទួលព្រះយេស៊ូវ ជាព្រះសង្គ្រោះ និងព្រះអម្ចាស់របស់ខ្លួនទេ។ ទោះបីជាគាត់ជាមនុស្សដែលគេបានទុកចិត្ត ដោយឲ្យ "កាន់លុយ"ក៏ដោយ ក៏គាត់មិនដែលមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះ ដូចដែលយើងអាចមានក្នុងពេលបច្ចុប្បន្ន ដោយយកទ្រង់ជាទីមួយនោះឡើយ។

"ការដឹងថាទ្រង់បានសុគត គឺជាការយល់ដឹងតាមប្រវត្តិសាស្ត្រ។

ការជឿថា ទ្រង់បានសុគជួសបាបខ្ញុំ នាំឲ្យយើងបានសេចក្តីសង្គ្រោះ។"

ដើម្បីចាប់ផ្តើមមានទំនាក់ទំនងផ្ទាល់ខ្លួន ជាមួយព្រះយេស៊ូវ ជាបឋម យើងត្រូវកើតជាថ្មី (យ៉ូហាន ៣:៣)។ ពេលដែលយើងមានកំណើតជាថ្មីខាងវិញ្ញាណ នៅក្នុងគ្រួសាររបស់ព្រះ នោះយើងក្លាយជាកូនរបស់ទ្រង់ និងជាសមាជិកនៃនគរខាងវិញ្ញាណរបស់ទ្រង់។

ដើម្បីចាប់ផ្តើមមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយទ្រង់ សូមអនុវត្តជាជំហានៗ ដូចតទៅ:

**ចូរទទួលស្គាល់ថា អ្នកត្រូវការទ្រង់៖** យើងបានមានកំណើតខាងសាច់ឈាម នៅក្នុងលោកិយនេះ តែយើងបានស្លាប់ខាងវិញ្ញាណ ដូចនេះយើងមិនមានគុណភាពនៃជីវិត តាមបំណងព្រះទ័យទ្រង់ទេ។ ព្រះគម្ពីរបានចែងថា "ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ"(រ៉ូម ៣:២៣) "គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង"(រ៉ូម ៣:១០) ហើយ "ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់"(រ៉ូម ៦:២៣)។ ដូចនេះយើងត្រូវការព្រះសង្គ្រោះ។

**ចូរទទួលស្គាល់ការអ្វីដែលព្រះបានធ្វើសម្រាប់អ្នក ៖** ព្រះទ្រង់បានស្រឡាញ់យើងរាល់គ្នាជាខ្លាំងដល់ម្ល៉េះ បានជាទ្រង់ចាត់ព្រះរាជបុត្រាទ្រង់ ឲ្យយាងចុះមកក្នុងលោកិយនេះ ដើម្បីសង្គ្រោះយើង ឲ្យរួចពីសេចក្តីហិនវិនាស នៃអំពើបាប(យ៉ូហាន ១:១-១៤, ៣:១៦)។ ព្រះយេស៊ូវបានសុគតជំនួសយើង ដោយថ្វាយព្រះអង្គទ្រង់ជាយញ្ញបូជាដ៏គ្រប់លក្ខណ៍។ ទ្រង់បានថ្វាយយញ្ញបូជានេះតែម្តងជាសម្រេច ដើម្បីលោះបាបរបស់យើង ទោះបីជាបាបនោះតិចតួច ឬច្រើនយ៉ាងណាក្តី។

**ជឿ និងទទួលនូវអំណោយរបស់ព្រះ ផ្ទាល់ៗខ្លួន** ៖ គ្មាននរណាម្នាក់បានសង្គ្រោះ ដោយសារការធ្វើល្អនោះទេ។ យើងបានសង្គ្រោះដោយសារជំនឿលើព្រះគ្រីស្ទ។ ព្រះគម្ពីរបានចែងថា "ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន"(អេភេសូ ២:៨-៩)។

ដើម្បីទទួលអំណោយមួយនេះ ពីព្រោះយើងអាចអធិស្ឋានទូលសូម តាមបែបផ្សេងៗជាច្រើន។ ការដែលសំខាន់នោះ គឺយើងបានទទួលជឿទ្រង់ខ្លាំងល្មម នឹងអាចអធិស្ឋាន ដោយពាក្យដែលស្រដៀងនឹងលំនាំខាងក្រោមនេះថា ៖ *"ឱព្រះអង្គអើយ ទូលបង្គំដឹងថា ទូលបង្គំបានធ្វើបាបទាស់នឹងទ្រង់។ ទូលបង្គំជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ទ្រង់ ដែលបានសុគតនៅលើឈើឆ្កាង ដើម្បីលោះបាបទូលបង្គំ ហើយទូលបង្គំជឿថា ទ្រង់បានមានព្រះជន្មរស់ឡើងវិញ ដើម្បីធ្វើការបញ្ជាក់។ ពេលនេះ ទូលបង្គំសូមទទួលការអត់ទោសបាប និងជីវិតអស់កល្បជានិច្ចទាំងស្រុងពីទ្រង់។ ទូលបង្គំសូមទទួលព្រះយេស៊ូវជាព្រះអម្ចាស់ និងព្រះសង្គ្រោះ។ អាម៉ែន"*

បើអ្នកពិតជា*បាន*អធិស្ឋានអស់ពីចិត្ត តាមលំនាំខាងលើនេះមែន នោះអ្នកបានចាប់ផ្ដើមមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះហើយ!

---

អត្ថបទនេះត្រូវបានដកស្រង់ចេញពីកូនសៀវភៅ*តើអ្វីជាទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះ?*

© 1988, 1997 អង្គការ RBC